ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2016, 14:58
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤១៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

កញ្ញា ដូរីន ឈិន *(Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេសន៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សួស ធី (2-TCW-816) | ខ្មែរ |
| លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច (2-TCW-916) | ខ្មែរ |

# ឧបសម្ព័ន្ធ


**ការសួរសំណួរទៅសាក្សី ÷ លោក សួស ធី** (2-TCW-816)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៣

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........ ទំព័រ ១៣

**ការសួរសំណួរទៅសាក្សី÷ លោក ភាំង ហ្គេកអ៊ាវ** (2-TCW-916)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៣១

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........ ទំព័រ ៣៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី សួស ធី បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-916។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា នៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមាននៅបន្ទប់សវនាការដោយផ្ទាល់ នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក សួស ធី លោក និងមេធាវីប្រឹក្សាគឺលោក ម៉ម ឫទ្ធា មានវត្តមានរួចហើយ ក្នុងបន្ទប់សវនាការនេះ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀត មានរហស្សនាម 2-TCW-916។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន នៅចំពោះអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ កញ្ញា ជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គ

ជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាព សុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ អង្គុយយូរមិនបាន អង្គុយយូរឈឺកាន់តែខ្លាំងនិងវិលមុខ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៣:៥៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី សួស ធី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្ដីលោកសាក្សី។ ខ្ញុំមិនជាសល់សំណួរច្រើនប៉ុន្មានទេសម្រាប់ព្រឹកនេះ។ ទោះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាជាខ្ញុំមានតែពីរបីប្រធានទៀតក៏ដោយ តែក៏មិនវែងដែរ។ ម្សិលមិញខ្ញុំបានសួរតទល់ជាមួយនឹងលោក ដោយលើកយកសក្ខីកម្មរបស់ ស្រ៊ាង ប្រធានខាងផ្នែកថតរូប ដែលគាត់និយាយថា អ្នកទោស <ដែល>ត្រូវបានគេបញ្ជូនទៅព្រៃសនោះ គឺថា <>ត្រូវបាន<គេ>ថត<រូប>នៅបរិវេណដែលខ្លួនលោកផ្ទាល់នេះ ក៏បានទៅនោះដែរ ហើយកាលពីម្សិលមិញ<លោកបាននិយាយថា> ខ្ញុំសូមដកស្រង់សេចក្តីព្រាងប្រតិចារឹកនៅម៉ោង ១៥:២៥ រសៀល។ លោកបានឆ្លើយថា "ខ្ញុំមិនបានដឹងភាពលម្អិតអំពីដំណើរការនៃការថតរូបនេះទេ ប្រហែល<អ្នកទាំងអស់នោះ ត្រូវបាន>គេ<>ថតរូប<>នៅផ្នែកខាងក្រៅ មុន<ពេលពួកគេត្រូវបានបញ្ជូនទៅធ្វើស្រែ។ ហើយតាមដែលខ្ញុំដឹង អ្នក>ទោសណាដែលត្រូវបានគេថតរូបនៅខាងក្នុងហើយ គឺថា<>គេ<មិនដែល>បញ្ជូនទៅធ្វើស្រែទេ"។ ខ្ញុំសូមសួរបញ្ជាក់លោកជាថ្មីម្តងទៀតទៅតាមការចងចាំរបស់លោកបានល្អបំផុតនោះ ថាអ្នកទោសដែលគេបញ្ជូនទៅព្រៃស ឬក៏ស-២៤ សូមលោកបញ្ជាក់អំពីដំណើរការនេះបន្តិច បានទេ?

[០៩:០៦:២២]

**លោក សួស ធី៖**

**ឆ៖** ចំពោះអ្នកទោសដែលបញ្ជូនទៅស-២៤ គឺរឿងនេះ គឺខ្ញុំអត់បានដឹងទេ ពីព្រោះគេជាផ្នែកខាងក្រៅ គឺខ្ញុំអត់បានដឹង។

**ស៖** លោក<កំពុងតែ>ឆ្លើយថា លោកមិនដឹងអំពីចំណុចលម្អិតទេ។ តើនេះមានន័យថា <វាអាចកើតមានដែរដែលថា> អ្នក<ដែល>ត្រូវបានគេបញ្ជូនមកកន្លែង<>ទទួល <ដែលនៅ>ខាងក្រៅបរិវេណ<ស-២១ គឺត្រូវបាន>គេបញ្ជូនទៅព្រៃស<នៅពេលបន្តមកទៀត។ តើអ៊ីចឹងមែនទេ>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកមិនត្រូវសួរឲ្យសាក្សីឆ្លើយស្មានទេ ពីព្រោះសាក្សីបានឆ្លើយហើយថា គាត់មិនដឹងអំពីចំណុចលម្អិតទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ហ្នឹងគឺអ្វីដែលគាត់ឆ្លើយអ៊ីចឹងមែន ប៉ុន្តែឥឡូវ ខ្ញុំសូមអាននូវអ្វីដែលគាត់បានឆ្លើយទាក់ទងទៅនឹងអ្នកទោសដែលគេបានបញ្ជូនទៅព្រៃស។ ខ្ញុំយោងទៅឯកសារ E3/9320 ជាកិច្ចសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសខ្ញុំយោងទៅ ERN អង់គ្លេស 00337985, ខ្មែរ 00052031, បារាំង 00280259។ ខ្ញុំសូមអានសម្រង់នេះទាំងស្រុងតែម្តង ដើម្បីឲ្យយល់ឲ្យបានច្បាស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថាតើអ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាសួរគាត់ថាដូចម្ដេចខ្លះ។

អ្នកស៊ើបអង្កេតសួរថា៖ "លោកលើកឡើងពីខាងដើមថា គ្មានអ្នកទោសណាម្នាក់ត្រូវបានគេដោះលែងទេ ក៏ប៉ុន្តែ<តើ>មានអ្នកទោសត្រូវបានគេបញ្ជូនទៅគុកដទៃទៀត<ទេ>? ហើយលោកឆ្លើយថា មិនមានករណីណាត្រូវបានគេដោះលែងទេ។ សួរ៖ តើលោកនិយាយថា គេបានបញ្ជូនអ្នកទោសពីទួលស្លែងទៅព្រៃសឬ? ឆ្លើយ៖ អត់ទេ។ បើសិនណាគេចង់បញ្ជូនអ្នកទាំងនោះទៅព្រៃស គេអាចបញ្ជូនទៅបាន តែបើសិនណាជាគេយកមកចូលខាងក្នុងហើយ គឺគេចងបិទមុខ។ <វាជាករណីផ្សេងមួយទៀត។> អ្នកខ្លះត្រូវបានគេបញ្ជូនទៅព្រៃស។ <អង្គភាពរបស់ពួកគេ អាចបញ្ជូនអ្នកទោសទៅទីនោះដោយខ្លួនឯងបាន។> សួរ៖ ខ្ញុំបានជួបអ្នកដែលត្រូវបានគេបញ្ជូនទៅ<ដាក់គុក>ព្រៃស។ ពួកគេប្រាប់ថា មុនពេលគេបញ្ជូនទៅព្រៃស ពួកគេត្រូវបានចងមុខ ហើយក្រោយមកគេនាំខ្លួនមកទួលស្លែង។ ក្រោយពីសួរចម្លើយអស់៣ថ្ងៃ ពួកគាត់ត្រូវបានគេចង<មុខ>ម្ដងទៀត និងបញ្ជូនត្រឡប់ទៅព្រៃសវិញ។ តើលោកដឹងអំពីករណីនេះទេ? លោកឆ្លើយថា៖ ខ្ញុំអត់ដឹងទេ។ ប្រហែល<នោះ>ជាអ្វីដែលកើត<បាន>ឡើង<ពីដំបូង ហើយ>អ្នកទោសមិនត្រូវបានគេសម្លាប់ទេ"។ និងមាន<>បន្តបន្ទាប់មកទៀត។

ដូច្នេះ លោកសាក្សីទោះបីជាលោកឆ្លើយថាលោកមិនដឹងចំណុចលម្អិតក៏ដោយ ត្រង់ចំណុចនេះបញ្ជាក់ថាលោកដឹងថា តើអ្នកទោសអាចនឹងត្រូវគេបញ្ជូនទៅព្រៃសដោយរបៀបណា។ តើត្រឹមត្រូវដែរឬក៏អត់<>?

[០៩:១០:២៦]

**លោក សួស ធី៖**

**ឆ៖** ចំពោះរឿងចម្លើយជាមួយមជ្ឈមណ្ឌលវាយូរហើយ ប៉ុន្តែវាជាការ -- នេះគឺខ្ញុំអត់បានចងចាំច្បាស់លាស់ទេ។ ប៉ុន្តែខ្ញុំចង់បញ្ជាក់ប៉ុណ្ណេះ ខ្ញុំធ្វើការនៅក្នុងខាងក្នុងទេ អ្នកទោសដែលនៅតែបញ្ជូនមកដល់ក្នុងហើយ គឺអត់មានបញ្ជូនទៅៗខាងក្រៅវិញទេ។ ហើយបើតាមការដែលគេទាក់ទងគ្នាខាងក្រៅ គេបញ្ជូនម៉េច គឺគេនៅខាងកងពិសេសខាងក្រៅនោះទេ ហ្នឹងគេមានលទ្ធភាពគេដឹងអីទាំងអស់ តែខ្ញុំដឹងតែអ្នកទោសដែលចូលមកដល់ក្នុង ខាងក្នុងនេះទេ។

**ស៖** ខ្ញុំមិនសុំឱ្យលោកឆ្លើយដោយស្មានៗទេលោកសាក្សី។ ខ្ញុំសូមអានឱ្យលោកស្ដាប់នូវអ្វីដែល ហ៊ឹម ហ៊ុយ បានឆ្លើយចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី០៥ ឧសភា ២០១៦ នៅប្រហែលជាម៉ោង ១០:៤៣ ដល់ ១០:៤៥។ គាត់បាននិយាយអំពីអ្នកទោសដែលបានមកដល់ នៅកន្លែងគេទទួលយកអ្នកទោស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅស-២១។ ហើយនៅមុនម៉ោង ១០:៤៥ គាត់និយាយ៖ “តាហ៊ី <បាន>ចាត់តាំង<>ខ្ញុំ<និងគ្នាខ្ញុំឱ្យ> បំពេញការងារនេះ គឺបញ្ជូនអ្នកទាំងនោះទៅព្រៃស ហើយមានអ្នកទោសមួយក្រុមផ្សេងទៀតគេបញ្ជូនមកទួលស្លែង” បញ្ចប់ការដកស្រង់។ តើលោកយល់ដូចម្តេចដែរនូវអ្វីដែល ហ៊ឹម ហ៊ុយ បានជម្រាបជូនអង្គជំនុំជម្រះនេះ?

**ឆ៖** ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថា អ្នកទោសដែលមកដល់គឺនៅខាងក្រៅ គឺកងពិសេសហ្នឹងគឺអ្នកទទួល។ ដូច្នេះ ចំពោះការគេដែលបញ្ជូនខាងក្រៅទៅណា គឺខ្ញុំអត់បានដឹងទេ គឺខ្ញុំដឹងតែអ្នកទោសដែលចូលមកដល់ខាងក្នុងគឺខ្ញុំអាចដឹង គឺអ្នកទោសដែលចូលមកដល់ក្នុងគឺអត់មានបញ្ជូនទៅណាទេ។ ខ្ញុំសូមបញ្ជាក់ គឺខាងក្នុង ចូលដល់ក្នុងបរិវេណក្នុងគុកតែម្តង មិនមែននៅខាងក្រៅទេ។

**ស៖** ខ្ញុំសូម<ចេញពី>ចំណុចនេះ<សិន ហើយខ្ញុំនឹងត្រឡប់មកប្រធានបទនេះវិញ>។ តើលោកដឹងអំពីគោលការណ៍រក្សាការសម្ងាត់ទេ? ហើយបើលោកដឹង តើគោលការណ៍រក្សាការសម្ងាត់នេះត្រូវបានគេអនុវត្តនៅស-២១ ដែរទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតថា រឿងការណ៍អ្វីទាំងអស់ក្រៅពីភារកិច្ចដែលខ្ញុំធ្វើ គឺខ្ញុំអត់សូវចាប់អារម្មណ៍ទេ។ ដូច្នេះ ការងារទាំងនោះគឺ មិនសូវជាចម្បង គឺគិតយ៉ាងម៉េចខិតខំបំពេញភារកិច្ចខ្លួនឯងកុំឱ្យមានតែកំហុសតែប៉ុណ្ណឹងទេ។

[០៩:១៤:២៥]

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីឯកសារពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍របស់លោក នៅខែសីហា ២០០៣ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7637, ERN ជាភាសាខ្មែរ 00229033, បារាំង 00344703, អង់គ្លេស 00185878។ នេះជាការកត់សម្គាល់ ដែលមិនមែនលោកឆ្លើយចេញពីមាត់របស់លោកទេ <តែវាផ្អែកលើអ្វីដែលលោកប្រាប់អ្នកស៊ើបអង្កេត គឺមាន>ដូចតទៅ៖ “អ្នកទោសដែលចូលមក គឺត្រូវបានគេនាំមក<ពី>ទូទាំងប្រទេស យោងតាមនីតិវិធី ភាពលម្អិតនេះ គឺថា ធី មិនដឹងទេ។ អ្នកទោសដែលគេបញ្ជូនទៅ<ក្រៅជាមួយអង្គភាព>កងការពារ<គឺផ្អែកលើមូលដ្ឋាននៃហត្ថលេខាដែល> ហ៊ី <>ទទួល<ពី ឌុច>។ ធី ក៏មិនមែនជាអ្នកកាន់កាប់បញ្ជីអ្នកទោសនៅកន្លែងឃុំខ្លួនដែរ គឺមានអ្នកផ្សេង។ ចំណុចនេះបញ្ជាក់អំពីភាពធ្ងន់ធ្ងរនៃការងារជាមួយនឹងអ្នកដែលការពារ និងអ្នកសួរចម្លើយ ដែលអ្នកពីរក្រុមនេះគឺមិនឱ្យហូបបាយជាមួយគ្នា មិនឱ្យទំនាក់ទំនងគ្នាទេ។ ផ្នែករបស់ ធី មិនមានសិទ្ធិ<ចូលទៅជិត> ឬក៏ស្គាល់អ្នកទោសបាននោះទេ។” បញ្ចប់ការដកស្រង់។ <អ្វីដែលបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រៀបរាប់នៅទី>នេះពាក់ព័ន្ធទៅនឹងភាពរក្សាការសម្ងាត់នៅស-២១ហើយ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ អានេះជាការត្រឹមត្រូវ។

**ស៖** តាមរយៈការរៀបរាប់អំពីគោលការណ៍រក្សាការសម្ងាត់នេះ ខ្លួនលោកផ្ទាល់បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿងប្រឆាំងទៅនឹង ឌុច នៅ<ទី២៨> ខែកក្កដា ២០០៩ ឯកសារ E3/7466 នៅម៉ោង ១០:៤៨។ ខ្ញុំសូមដកស្រង់៖ "ទាក់ទងទៅនឹងបញ្ជីអ្នក<ទោសនៅ>ស-២១ ខ្ញុំមិនមែនជាអ្នករៀបចំចងក្រងនោះទេ គឺ ម៉េង ជាអ្នកទទួលខុសត្រូវបញ្ជីរួមនៅស-២១ ហើយគាត់មានសិទ្ធិត្រួតត្រាគ្រប់គ្រងបញ្ជីអ្នកជាប់ឃុំឃាំងនៅស-២១ទាំងអស់ រួមទាំងស-២៤ផងដែរ។" បញ្ចប់ការដកស្រង់។

តើនេះគឺជាសម្តីរបស់លោក ដែលបានឆ្លើយជូនតុលាការថា ម៉េង ទេដែលជាអ្នកគ្រប់គ្រងបញ្ជីអ្នកទោសស-២៤ គឺព្រៃស។ តើលោកពិតជាឆ្លើយអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបញ្ជាក់ថា ម៉េង ហ្នឹងគឺជាអ្នកកាន់បញ្ជីរួមទាំងអស់ ក្នុងមន្ទីរស-២១។ ដូច្នេះទាំងបីមន្ទីរហ្នឹង គឺ ម៉េង ជាអ្នកក្តាប់ទាំងអស់។

[០៩:១៨:២០]

**ស៖** កាលពីម្សិលមិញ ខ្ញុំបានបង្ហាញលោកនូវបញ្ជីមួយ ដែលជាបញ្ជីដោះលែងអ្នកទោស ១០០ នាក់ពីកងពល៩២០ ឯកសារ<E3/8648 ហើយខ្ញុំក៏បានបង្ហាញប្រវត្តិរូបពីរដល់លោកដែរ>--

**អ្នកបកប្រែ៖**

លោកប្រធានសុំការអនុញ្ញាត ERN មេធាវីអានញាប់ពេក។

**ប្រធានអង្គជំនុំ៖**

សារឡើងវិញ ERN បកប្រែមិនទាន់ទេ សូមឲ្យយឺតៗ ហើយគួរបញ្ជាក់ពីរដង យើងបានណែនាំរួចហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនទាន់បានលើក ERN ទេ ទើបតែលើកឯកសារ ប៉ុន្តែខ្ញុំជម្រាបជូនពីលេខឯកសារម្តងទៀត លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ម្សិលមិញខ្ញុំបង្ហាញលោកនូវបញ្ជីមួយនៃការដោះលែងអ្នកទោសចំនួន ១០០

នាក់ពីកងពល៩២០ គឺឯកសារ E3/8648។ ខ្ញុំក៏បង្ហាញឱ្យលោកមើលនូវប្រវត្តិរូបពីរច្បាប់ដែលមានចំណារចារថា៖ “បញ្ជូនទៅធ្វើស្រែ”។ លោកមើលទៅហាក់មានភាពច្របូកច្របល់បន្តិចនៅពេលដែលខ្ញុំបង្ហាញ ហើយលោក<ហាក់ដូចជានិយាយ>ថាការដោះលែងនៅស-២១ គឺថាមិនអាចទៅរួចទេ។ លោកយល់ថាអ៊ីចឹង។

សំណួរខ្ញុំសួរដូចតទៅ តើពិតដែរទេ ដែលថាលោកមានការដឹងតិចតួចបំផុតនូវអ្វីដែលកើតមានឡើងនៅស-២១? ក៏ប៉ុន្តែសក្ខីកម្មដើមរបស់លោកក៏បានឆ្លើយផងដែរថា គ្មានអ្នកណាម្នាក់អាចត្រូវបានគេដោះ ឬត្រូវបានគេដោះលែងពីស-២១ទេ។ ការណ៍ដែលលោកឆ្លើយបែបនេះ គឺមិនត្រឹមត្រូវទេ។ តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

[០៩:២០:៤០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំជំទាស់នឹងរបៀបសួរសំណួរចុងក្រោយនេះ ព្រោះថាមេធាវីការពារក្ដី គាត់យល់ឃើញថាមនុស្ស អ្នកទោសទាំងអស់នោះត្រូវបានគេដោះលែង<ដោយផ្អែកលើចំណងជើងរបស់ឯកសារ>។ ការបកស្រាយអំពីពាក្យថា “ដោះលែង” នេះនែ៎ មិនច្បាស់លាស់ដូច្នេះទេ ព្រោះថារហូតដល់ពេលនេះ យើងបានធ្វើការកត់សម្គាល់ទាក់ទងនឹងឯកសារ E3/965 នៅក្នុងសវនាការរួចហើយ ហើយទាក់ទងទៅនឹងឯកសារនៃមនុស្សទាំង១០០នាក់ដែលមកពីកងពល៩២០ ដែលមានឯកសារ E3/8648 នេះគឺថា យើងអាចនិយាយបានថា បុគ្គលទាំងអស់នេះត្រូវបានដោះលែង ហើយត្រូវបានបញ្ជូនមកមន្ទីរស-២១វិញ ហើយសម្លាប់ហើយ ហើយ<យើងបានរកឃើញ>មាន<៤៥នាក់>នៅក្នុងបញ្ជី អូ.ស៊ី.អាយ.ដេផង។ អ៊ីចឹងការដែលលើកឡើងថា អ្នកទាំងអស់នេះត្រូវបានដោះលែងរហូត ហើយចប់នោះ មិនត្រឹមត្រូវទេ។ <សំណួរនេះគួរតែរៀបឡើងវិញ>។ <មនុស្សទាំងអស់នោះត្រូវបានបញ្ជូនទៅស-២១(ឃ)។ នេះជាអ្វីដែលមាននិយាយនៅក្នុងឯកសារ។> អ៊ីចឹងបើ<បើមើល>ទៅ<លើ>មនុស្ស៤៥នាក់ ដែលយើងឃើញថា<ពួកគេ>សុទ្ធតែមកពីមន្ទីរស-២១(ឃ) ទាំងអស់។ អ៊ីចឹងការបកស្រាយ<ពាក្យថា “ដោះលែង”>នេះ ត្រូវតែប្រយ័ត្នប្រយែង ហើយការដែលមកសួរសាក្សីនេះ ដែលៗលើកឡើងថា គាត់មិនដឹង<អ្វីទាំងអស់ ហើយ>គាត់មិន<>ដឹង<ថា មនុស្ស>ទាំងអស់<នោះត្រូវបានគេដោះលែង>ទេ។

<មនុស្សទាំងអស់នេះមិនត្រូវបានដោះលែងទេ> អ៊ីចឹងគួរតែ<យល់នូវពាក្យថា "ដោះលែង" នៅក្នុងអត្ថន័យសញ្ញា>។

[០៩:២២:១៥]

**លោក វ៉ិចទ័រ កូប៉េះ**

គឺខ្ញុំយល់ឃើញថា ការជំទាស់នេះវាមានលក្ខណៈ<ចម្លែកណាស់។ ដំបូងឡើយ សហព្រះរាជអាជ្ញាតវ៉ា ហើយបន្ទាប់មកទៀត> នៅពេលដែលយើងបានលើកយកឯកសារនេះមកសួរ គឺថា<វាគួរតែ>អាចបកស្រាយតាមរបៀបផ្សេង។ <ខ្ញុំមានឯកសារនេះនៅចំពោះមុខខ្ញុំ។> តាមពិតទៅ មជ្ឈមណ្ឌលឯកសារកម្ពុជា និង<ខាងការពារក្តី>យល់ស្របជាមួយគ្នាថា <បញ្ជីនោះនិយាយពីឈ្មោះអ្នកដែល>គេដោះលែងនៅថ្ងៃទី២៦ <ខែវិច្ឆិកា ឆ្នាំ១៩៧៧ ចំនួនយុទ្ធជន១០០នាក់មកពីកងពល៩២០។> មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបោះពុម្ពផ្សាយនូវកូនសៀវភៅរបស់ខ្លួនពីចំណុចនេះផងដែរ ហើយការដែលនិយាយថាមិនត្រូវ -- អ្នកទោសមិនត្រូវបានគេដោះលែងម្នាក់សោះនោះ មិនត្រឹមត្រូវទេ។ ខ្ញុំគឺថាមានសិទ្ធិសួរបញ្ជាក់ ក៏ប៉ុន្តែសាក្សីរូបនេះគឺថាមិនដឹងអ្វីទេ គាត់ៗឆ្លើយថា គាត់មិនដឹងអ្វីទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍**

ចុះបើសាក្សី គាត់ឆ្លើយថា មិនដឹងទៅហើយ ធ្វើម៉េចឲ្យគាត់ដឹង បើគាត់ឆ្លើយថាមិនដឹងទៅហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

លោកស្រីចៅក្រម ហ្វេនស៍ ខ្ញុំយល់ស្របដូចគ្នាចំណុចនេះ។ ប៉ុន្តែ<វានៅមានសល់ទៀត សំណួរនោះមិនទាន់បានឆ្លើយនៅឡើយទេ។> ឥឡូវខ្ញុំសូមសួរបញ្ជាក់ឡើងវិញជាថ្មី។

[០៩:២៣:៣៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសួរយ៉ាងម៉េចសួរទៅ ប៉ុន្តែកុំឲ្យសាក្សី ឆ្លើយវាយតម្លៃលើសេចក្តីសន្និដ្ឋានរបស់លោកជាមេធាវី! សាក្សីមិនមានមុខងារវាយតម្លៃលើសេចក្តីសន្និដ្ឋានលើមេធាវីទេ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំយល់ហើយលោកប្រធាន ក៏ប៉ុន្តែ<ខ្ញុំយល់>ថា<> ខ្ញុំមានសិទ្ធិសួរបែបនេះថា "លោកសាក្សីលោកពិតជាមិនដឹងអ្វីសោះនៅស-២១? <ទោះដឹងក៏ដឹងយ៉ាងតិចតួចប៉ុណ្ណោះ មែនទេ?" សំណួរនេះ គឺ

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាលទ្ធផលចុងក្រោយនៃ>សំណួរជាច្រើនដែលបានសួរកាលពីម្សិលមិញ។ <ហើយខ្ញុំគិតថា ខ្ញុំគួរតែអាចសួរសំណួរចុងក្រោយបាន>។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ ជាសំណួរប្រភេទសំណួរ ដែលអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យប្រើប្រាស់សំណួរបែបនេះទេ។ សាក្សីគ្មានមុខងារអីត្រូវវាយតម្លៃលើសេចក្ដីដ្ឋានរបស់អ្នកមេធាវីការពារក្ដី ឬភាគីពាក់កណ្ដាលទីទេ។ អង្គជំនុំជម្រះទេ ដែលមានគុណវុឌ្ឍិក្នុងការវាយតម្លៃអំពីបន្ទុក និងទម្ងន់នៃភស្ដុតាងពាក់ព័ន្ធនឹងបញ្ហា។ សាក្សីឆ្លើយគ្រប់គ្រាន់ហើយ សមស្របហើយលើបញ្ហាគាត់ដឹងកម្រិតផ្នែកមួយ ដែលគាត់ទទួលខុសត្រូវ ចូលរួមក្នុងការទទួលខុសត្រូវនៅក្នុងការធ្វើបញ្ជី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

<វាជាការប្រសើរណាស់ ដែលដឹងថា មានការអនុញ្ញាតឲ្យសាក្សីឆ្លើយដោយ>ស្មាន<ៗចំពោះអ្វីដែលគាត់មិនដឹងនោះ> ប៉ុន្តែ<នៅពេលដែល>ខ្ញុំ<សួរសំណួរនោះ> បែរទៅជាមិនអនុញ្ញាត<ទៅវិញ។> ក៏ប៉ុន្តែខ្ញុំ<បន្តទៅទៀត>។

**ស៖** ឥឡូវនេះ ខ្ញុំចូលនិយាយអំពីបញ្ហាឋានានុក្រមថា តើអ្នកណាជាអ្នកទទួលខុសត្រូវបញ្ជាឲ្យសម្លាប់<>នៅស-២១។ លោកសាក្សី ខ្ញុំសូមអានឲ្យលោកស្ដាប់នូវអ្វីដែល ឌុច បានឆ្លើយ<ពេលដែលគាត់បានស្ដាប់ចម្លើយលោក> នៅថ្ងៃទី២៨ ខែកក្កដា ២០០៩ គឺឯកសារ E3/7466 នៅម៉ោង១៥:៣៩ ឌុច បានឆ្លើយពាក់ព័ន្ធសក្ខីកម្មរបស់លោក។ ឌុច និយាយថា “<ខ្ញុំពេញចិត្ត>សក្ខីកម្មរបស់គាត់ គឺគាត់បំពេញការងារក្នុងឋានៈជាកម្មាភិបាលថ្នាក់កណ្ដាលមួយរូបនៅស-២១ ទោះបីជាគាត់មិនធ្វើការ និងទាក់ទងជាមួយខ្ញុំដោយផ្ទាល់ក៏ដោយ ហើយខ្ញុំក៏មិន<ចង់ឲ្យ>កម្មាភិបាលថ្នាក់កណ្ដាលណាមួយ<> ទាក់ទងជាមួយខ្ញុំ<ដោយផ្ទាល់នោះ>ដែរ។” បញ្ចប់ការដកស្រង់។

លោកសាក្សី តើត្រឹមត្រូវដែរឬទេ ដែល ឌុច បានឆ្លើយថា “លោកមិនបានទាក់ទងជាមួយគាត់ទេ ហើយគាត់ក៏មិនអនុញ្ញាតឲ្យលោកទាក់ទងជាមួយគាត់ដែរ”។ ត្រឹមត្រូវដែរទេ?

[០៩:២៦:៥២]

**លោក សួស ធី៖**

**ធ៖** បាទ ហ្នឹងត្រឹមត្រូវហើយ។

**ស៖** ម្សិលមិញលោកបានឆ្លើយថា “ហ៊ា គឺជាមេរបស់លោក ហើយលោកមានការប្រាស្រ័យ

ទាក់ទងផ្ទាល់ជាមួយ ហ៊ី"។ តើត្រឹមត្រូវដែរទេ ដែលថាលោកមិនដឹងអ្នកណាជាអ្នក<ទទួលខុសត្រូវចំពោះការ>បញ្ជាឲ្យ<>សម្លាប់<មនុស្ស>?<>

**ឆ៖** ដូចខ្ញុំបានឆ្លើយអ៊ីចឹង គឺថា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសំណួរទាំងអស់នេះសុទ្ធតែជាសំណួរដដែលៗ យើងឃើញ យើងស្តាប់ឮសាក្សីឆ្លើយច្រើនដងហើយថា មានចំណាររបស់ ឌុច នៅលើឯកសារទាក់ទងទៅនឹងអ្នកដែលត្រូវយកទៅសម្លាប់។ ឥឡូវសំណួរសួរថា "អ្នកឯងមិនដឹងអីទេ ទាក់ទងទៅនឹងអ្នកដែលផ្តល់ ចេញបញ្ជា<សម្លាប់>នោះ?" ត្រង់ចំណុចនេះគឺថាមានបញ្ហាច្បាស់លាស់ហើយ ព្រោះថាសាក្សីនេះបានឆ្លើយច្រើនដងហើយ។ ហើយអ៊ីចឹងមិន -- មើលទៅដូចមិនត្រឹមត្រូវទាល់តែសោះដែលមេធាវីការពារក្តីបកស្រាយចម្លើយរបស់សាក្សីរូបនេះថា គាត់<ដឹងថា>ពុំមានទំនាក់ទំនងអ្វីសោះ<រវាង> ឌុច <និងការសម្លាប់មនុស្ស>។ អ៊ីចឹងគឺថា គាត់<បាននិយាយអំពី>ចំណារ។ <គាត់អាចមិនបានជួប ឌុច ប៉ុន្តែ> គាត់ដឹងថា ឌុច ធ្វើចំណារធ្វើអីហើយ។ អ៊ីចឹងវាមានទំនាក់ទំនងហើយ មិនមែនអត់<>សោះនោះទេ។

[០៩:២៨:៣៦]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ម្សិលមិញខ្ញុំបានអានសម្រង់បួន ឬក៏ប្រាំ<ពីក្នុងសក្ខីកម្មរបស់ ឌុច> ក្នុងសម្រង់ទាំងអស់នេះនិយាយដូចៗគ្នា ដែលថា ហ៊ី គឺជាអ្នកសម្រេចឲ្យសម្លាប់អ្នកទោស ហើយ<> ឌុច <គ្រាន់តែជាអ្នកចារតែប៉ុណ្ណោះ បើអ្នកទោសនោះ ត្រូវបានគេ>សួរចម្លើយ<>ចប់សព្វគ្រប់ហើយ។ តែមិនថ្វីទេ ខ្ញុំបន្តទៅមុខទៀតចុះ។ យ៉ាងណាក៏ដោយខ្ញុំដឹងថាលោកកំពុងតែគិតថាយ៉ាងម៉េចនោះហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចូលទៅចំណុចចុងក្រោយរបស់ខ្ញុំលោកសាក្សី។ ម្សិលមិញនោះ យើងបាននិយាយគ្នាខ្លីៗអំពីថ្ងៃចុងក្រោយដែលលោកធ្វើការនៅ<ស-២១> នៅថ្ងៃទី០៧ មករា ៧៩។ ម្សិលមិញលោកបានឆ្លើយថា មិនមានឯកសារណាមួយនៅស-២១ ត្រូវបានបំផ្លាញចោល នៅមុនថ្ងៃ០៧ មករា ៧៩

នោះទេ។ នៅឆ្នាំ២០០៩ លោកក៏បានឆ្លើយ<អំពីរឿងនេះដែរ> គឺឯកសារ E3/7466 នៅម៉ោង១១:០៤ លោកបានឆ្លើយ សូមដកស្រង់៖ “មិនមានផែនការបំផ្លាញឯកសារណាមួយចោលនោះទេ”។ បញ្ចប់ការដកស្រង់។ តើត្រឹមត្រូវដែរទេ ដែលថា មិនមានផែនការណាមួយសម្រេចឲ្យបំផ្លាញឯកសារណាមួយចោលនោះទេ?

**ឆ៖** ខ្ញុំចង់បញ្ជាក់ថា មុនថ្ងៃ០៧ មករា ហ្នឹង គឺថ្នាក់លើខ្ញុំ គឺហ៊ា គេអត់មានបានប្រាប់ថាខ្ញុំមានផែនការ១អីដើម្បីកម្ទេចឯកសារទេ ពីព្រោះខ្ញុំកាលហ្នឹងគឺអត់ដឹងសភាពការណ៍អីទាំងអស់ ហើយ ហ៊ា ក៏អត់មានបញ្ជាអីហ្នឹង។ ដូច្នេះ ឯកសារនៅក្នុងគុកហ្នឹង គឺឯកសារខាងមន្ទីរខ្ញុំ គឺនៅតម្កល់ដដែល អត់មានបំផ្លាញអី។ នេះ ខ្ញុំចង់បញ្ជាក់បន្ថែមទៀតថា នេះមិនមែនជា ដូចថា ឯកសារនៅខាងសួរចម្លើយ ក៏ខ្ញុំអត់បានដឹងដែរ ប៉ុន្តែបើថាឯកសារនៅក្នុងកងការពារដែលខ្ញុំធ្វើបញ្ជីអ្នកទោសនេះ គឺអត់មាន ហ៊ា បញ្ជាថាឲ្យបំផ្លាញទេ គឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:៣១:២០]

**ស៖** ឥឡូវខ្ញុំសូមសួរ តទល់ជាមួយលោក គឺថា ដេវីដ ឆេនដ៍ល័រ ជាអ្នកប្រវត្តិសាស្ត្រ គាត់បានសរសេរសៀវភៅអំពី ស-២១។ ហើយនៅក្នុងសៀវភៅរបស់គាត់ គាត់និយាយថា ប្រហែលថាចម្លើយសារភាព <៤.៣០០> ច្បាប់ គឺថាត្រូវបានគេរកឃើញ គឺឯកសារ E3/1684 ខ្មែរ 001918835, អង់គ្លេស 00192685, បារាំង 00357268។ មានការបោះពុម្ពផ្សាយជាច្រើន ប៉ុន្តែឯកសារ E3/1684 ERN អង់គ្លេស 00192676 មិនមាន ERN ជាភាសាខ្មែរ ជាភាសាបារាំងទេ។ ហើយនៅក្នុងឯកសារនេះ គឺបាននិយាយថា ប្រហែលជាហ្វីល ប្រហែលជា ៦.០០០ ត្រូវបានគេ -- ហ្វីលរូបថតប្រហែលជា ៦.០០០ រូបថតត្រូវបានគេរកឃើញ។ នេះ គឺអ្វីដែលលោកមិនបានដឹង ក៏ប៉ុន្តែអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣, ០០៤ បានស្រាវជ្រាវរាល់ឯកសារនៅស-២១ ទាំងអស់ ហើយនៅក្នុងបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត គឺឯកសារ <E393.2> ថា ប្រហែលជាបុគ្គល ៥.៥១២ នាក់ ត្រូវបានសម្លាប់ចោល។

ខ្ញុំយល់ហើយថាលោកនឹងពិបាកផ្ដល់តួលេខណាស់ ដោយសាររយៈពេលយូរហើយ តើវាអាចត្រឹមត្រូវដែរឬទេ<> ថានៅបរិវេណទួលស្លែងនេះ គឺអ្នកទោស <៥.០០០ ទៅ៦.០០០> នាក់ ត្រូវបានគេឃុំខ្លួន <និងសួរចម្លើយ>នៅទីនោះ ហើយក្រោយមកក៏ត្រូវបានសម្លាប់ចោលនៅម្ដុំបរិវេណទួលស្លែង។ តើលោកដឹងទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៣៣:៤៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន នេះជាការអះអាងដោយគ្មានមូលដ្ឋានទៀតហើយ។ យើងពិនិត្យមើលបញ្ជីនោះ គឺមានតែ ៥.៥០០ នាក់តែប៉ុណ្ណោះដែលមានឈ្មោះ ហើយត្រូវបានសម្លាប់ចោល ហើយមានកាលបរិច្ឆេទត្រឹមត្រូវទៀត។ យើងកំពុងតែវិភាគទៅលើបញ្ជីនេះ ពីព្រោះថា ការិយាល័យសហចៅក្រមស៊ើបអង្កេត <> បានបោះបង់ចោលនូវប្រភពជាច្រើនដែលមិនបង្ហាញនូវកាលបរិច្ឆេទត្រឹមត្រូវ។ នៅពេលដែលយើងពិនិត្យមើល រួចរាល់អស់ហើយនោះ យើងនឹងធ្វើសំណើពាក់ព័ន្ធទៅនឹងបញ្ជីមួយនេះ ដើម្បីបង្ហាញឲ្យឃើញថា មានការសម្លាប់ជាច្រើន ហើយមានចំនួននោះគឺច្រើនជាងហ្នឹងទៅទៀត។ ហើយបើថាមានចម្លើយសារភាព ៤.៣០០នាក់ ត្រូវបានរកឃើញហ្នឹង មិនមែនបានន័យថា មាន ៤.៣០០ នាក់ដែលត្រូវបានឃុំនៅស-២១ ទេ គឺវាអាចលើសពីហ្នឹងច្រើនទៅទៀត។ ដូច្នេះ ការអះអាងរបស់មេធាវីការពារក្ដី<ថាមានមនុស្សតែ៥.០០០ ឬ៦.០០០នាក់ ដែលបានឆ្លងកាត់ ស-២១>នោះ គឺមិនមានមូល-ដ្ឋានត្រឹមត្រូវទេ គាត់មិនអាចលើកឡើងបែបនេះបានទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សាក្សី តើលោកដឹងថា មាន<មនុស្ស>ចំនួនប៉ុន្មាននាក់<ស្លាប់>នៅស-២១ នៅពេល<គុកនេះដំណើរការនោះ>?

បើលោកសាក្សីដឹង លោកឆ្លើយថា លោកដឹង បើមិនដឹង លោកឆ្លើយថា មិនដឹង។ ឆ្លើយតែការពិតមកបានហើយ។

**លោក ស៊ួស ធី៖**

គឺខ្ញុំឆ្លើយ គឺខ្ញុំអត់បានដឹងចំនួនពិតប្រាកដ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

[០៩:៣៥:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោកខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី ស៊ួស ធី។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមលោកគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន ។ ក្នុងឋានៈខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកនៅព្រឹកនេះ។ ខ្ញុំមិនសួរច្រើនទេ។ សំណួរទី១ ខ្ញុំចង់ឲ្យលោកបំភ្លឺពាក់ព័ន្ធទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍។ លោកបាននិយាយអំពីក្រុមគ្រួសាររបស់លោក និង សមាជិកគ្រួសារដែលស្លាប់ ហើយនៅពេលដែលលោកនិយាយអំពីបងប្អូនរបស់លោកដែលនៅរស់នោះ លោកបាន<និយាយថា>បងប្អូនរបស់លោកនៅរស់បីនាក់ គឺលោក ហើយនិងប្អូនស្រីពីរនាក់ ដែលនៅរស់មកដល់សព្វថ្ងៃ។ ខ្ញុំដូចជាមិនសូវយល់អំពីចំនួនបងប្អូនរបស់លោក។ អ៊ីចឹងមានន័យថា បងប្អូនរបស់លោកប្រាំបីនាក់ ហើយប្រាំនាក់ស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសព្វថ្ងៃនេះ នៅរស់បីនាក់ទាំងលោក។ អ៊ីចឹងមែនទេ?

[០៩:៣៧:២៥]

**លោក សួស ធី៖**

**ធ៖** ខ្ញុំសូមបញ្ជាក់បន្ថែមរឿងនេះឲ្យបានច្បាស់ គឺថាជំនាន់កម្ពុជាប្រជាធិបតេយ្យហ្នឹង គឺបងប្អូនខ្ញុំដែលស្លាប់ដោយរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺបីនាក់ ហើយខ្ញុំថា ប្អូនពាក់នេះ អានេះប្អូនថ្លៃទេ ប៉ុន្តែបើបងប្អូនបង្កើតគឺបីនាក់ ហើយដែលខ្ញុំនៅសល់ទាំងអស់វាប្រាំនាក់។ ប៉ុន្តែក្រោយឆ្នាំ១៩៧៩ ប្អូនខ្ញុំពីរនាក់ទៀត គឺបានស្លាប់ទៅទៀត ដូច្នេះខ្ញុំវានៅសល់តែបីនាក់។ ដូច្នេះវា ទាំងអស់វាប្រាំបីនាក់។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈកាលដែលលោកធ្វើការនៅស-២១ គឺនៅទីតាំងគុកប៉េហ្ស៊ី។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិកាលពីថ្ងៃទី០២ ខែមិថុនា គឺនៅម៉ោង០៩:៣៣នាទី នៅពេលដែលគេបង្ហាញប្រវត្តិរូបរបស់លោក លោកបានឆ្លើយថា <កាលបរិច្ឆេទ>ខែវិច្ឆិកា ឆ្នាំ៧៥ <អាចនឹងត្រឹមត្រូវ ទាក់ទងនឹងការ>ដែលលោក<ចាប់ផ្ដើមធ្វើការនៅ>ស-២១ នៅគុកប៉េហ្ស៊ី។ ខ្ញុំដឹងថា លោកមិនចាំថ្ងៃខែឆ្នាំឲ្យប្រាកដទេ ក៏ប៉ុន្តែលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេថា នៅខែ<ធ្នូ> ឆ្នាំ១៩៧៥ គឺលោកធ្វើការនៅគុកប៉េហ្ស៊ី មែនទេ?

**ឆ៖** នេះ គឺបើតាមមើលប្រវត្តិរូបអាហ្នឹងច្បាស់ថា ខែវិច្ឆិកា បើខ្ញុំឲ្យស្មានដែលខ្ញុំដឹង គឺខ្ញុំអត់បានដឹងពិតប្រាកដ។

[០៩:៣៩:៣៧]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ឥឡូវនេះ ខ្ញុំចង់ដឹងថា នៅពេលដែលលោកចាប់ផ្តើមធ្វើការនៅគុកប៉េហ្ស៊ី តើលោកធ្វើការខាងកាន់កាប់បញ្ជី និងធ្វើបញ្ជីតែម្តងមែនទេ នៅពេលដែលលោកទៅដល់គុកប៉េហ្ស៊ីភ្លាមនោះ?

**ឆ៖** ទៅដល់គុកប៉េហ្ស៊ីភ្លាម គឺ ហ៊ា គេឲ្យខ្ញុំធ្វើបញ្ជីភ្លាម។

**ស៖** លោកដឹងទេថា នៅពេលនុ៎ងគឺមានតែលោកម្នាក់ឯងទេ ដែលកាន់កាប់ខាងបញ្ជីហ្នឹងមែនទេ? តើលោកដឹងថាមានអ្នកណាផ្សេង ឬក៏មានផ្នែកណាផ្សេងធ្វើការខាងបញ្ជីហ្នឹងដូចលោកទេ?

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹងគឺថា នៅគុកប៉េហ្ស៊ី ហ្នឹងគឺមាន ម៉េង ជាអ្នកធ្វើបញ្ជីមួយដែរ ហើយកាលខ្ញុំទៅដល់ភ្លាមហ្នឹងគឺមាន ហ៊ា ហ្នឹងគេ ដូចខ្ញុំចាំអត់ច្បាស់ ចាំច្បាស់គឺបញ្ជីហ្នឹងគឺ ហ៊ា គេដឹង គេយកមកឲ្យខ្ញុំបញ្ជីដែលអ្នកទោសដែលមានហ្នឹង យកមកឲ្យខ្ញុំធ្វើសាថ្មីវិញ។

**ស៖** លោកដឹងទេ មុនពេលដែលលោកទៅដល់នោះ អ្នកណាដែលធ្វើការកាន់កាប់ខាងបញ្ជីហ្នឹង?

**ឆ៖** មុនពេលខ្ញុំទៅដល់ ខ្ញុំទៅដល់ភ្លាមហ្នឹងគឺកន្លែងហ្នឹង គឺកន្លែង ហ៊ា ហ្នឹងគឺអត់មានអ្នកណាធ្វើទេ។ ប៉ុន្តែខ្ញុំទៅដល់គឺ ហ៊ា គេបានបញ្ជីអ្នកទោសហ្នឹងយកមកឲ្យខ្ញុំបន្ត ចម្លងដាក់សាថ្មី។

**ស៖** ខ្ញុំនៅតែនិយាយអំពីរយៈកាលដែលលោកនៅគុកប៉េហ្ស៊ីដដែល ខ្ញុំចង់ដឹងថាលោកចាំថានៅគុកប៉េហ្ស៊ី ហ្នឹងមានអ្នកទោសណាត្រូវបានដោះលែងទេ?

**ឆ៖** កាលនៅប៉េហ្ស៊ី ហ្នឹងគឺរយៈពេលខ្លី កាលខ្ញុំនៅកន្លែងហ្នឹង គឺអត់មានអ្នកទោសណាបានដោះលែង។

[០៩:៤២:៣៤]

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅពេលសហព្រះរាជអាជ្ញាសួរលោក គឺឯកសារ E3/7603 ERN ជាភាសាបារាំង 00392492, ERN ជាភាសាខ្មែរ 00145602 និង ERN ជាភាសាអង់គ្លេស 00146798។ សហព្រះរាជអាជ្ញាបានសម្ភាសលោក ហើយសួរលោកអំពីការងារនៅគុកប៉េហ្ស៊ី ពេលនោះលោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “នៅសម័យនោះ អ្នកទោសភាគច្រើនជាកម្មករ ហើយមិន

ត្រូវបានធ្វើទារុណកម្មអ្វីទេ អ្នកខ្លះត្រូវបានដោះលែង។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ នៅ<ក្នុងកិច្ច>សម្ភាសន៍<ជាមួយ>លោកនៅខែតុលា ឆ្នាំ២០០៦ នោះលោកថា អ្នកទោសខ្លះនោះត្រូវបានដោះលែង។ ឥឡូវលោកថាអត់មានទេ។ អ៊ីចឹងលោកព្យាយាមនឹកគិតឡើងវិញទៅមើល?

**ឆ៖** ការងារកន្លងហួសច្រើន ដូច្នេះការចងចាំរបស់ខ្ញុំគឺអត់បានច្បាស់លាស់ទេ។ ប៉ុន្តែបើតាមខ្ញុំដឹង ដែលខ្ញុំនៅកន្លែងគុកហ្នឹង កន្លែងគុកប៉េហ្ស៊ី ហ្នឹងវារួមនៅជាមួយនឹង ម៉េង ដូច្នេះការដោះលែងអីគឺ ខ្ញុំស្មានមិនដឹងទេ អត់បានដឹងពិតប្រាកដ។

**ស៖** ដូច្នេះ លោកចាំមិនច្បាស់ទេយើងយល់ ពីព្រោះថា ពេលវេលាហ្នឹងកន្លងហួសយូរទៅហើយ។ ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏លោកចាំថា កាលពីខែតុលា ឆ្នាំ២០០៦ហ្នឹង លោកបានឆ្លើយបែបហ្នឹងជូនការិយាល័យសហព្រះរាជអាជ្ញានោះ។

**ឆ៖** នេះគឺខ្ញុំ វាមិនច្បាស់ គឺការឆ្លើយ គឺវាកន្លងមក គឺខ្ញុំភ្លេចអស់ដែរ។

[០៩:៤៥:១៣]

**ស៖** នៅថ្ងៃទី០២ ខែមិថុនា នៅពេលដែលសហព្រះរាជអាជ្ញាសួរលោកនៅក្នុងសវនាការ គឺមុនម៉ោង ០៩:៤៣:៥៧ វិនាទី ខ្ញុំសូមដកស្រង់នូវប្រតិចារឹកសវនាការព្រាងជាភាសាបារាំង៖ "អ្នកទោសមិនត្រូវបានដោះលែងទេ ប៉ុន្តែពួកគេ<ត្រូវបានយក>ចេញពីគុក។ ខ្ញុំមិនដឹងថាតើពួកគេចេញទៅណាទេ ពីព្រោះថាវាមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្ញុំទេ។" សូមបញ្ចប់ការដកស្រង់។ លោកថា៖ "វាមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ខ្ញុំទេ។" អ៊ីចឹងលោកដឹងថា តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការសម្រេចបញ្ជូនអ្នកទោសចេញ បើលោកមិនមែនជាអ្នកទទួលខុសត្រូវ? អ៊ីចឹងលោកដឹងទេថា អ្នកណាជាអ្នកទទួលខុសត្រូវលើរឿងនេះ?

**ឆ៖** អ្នកទទួលខុសត្រូវគឺមានតែ ហ៊ី ទេដែលអ្នកទទួលទៅរឿងអ្នកទោសទាំងអស់។

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់ពិភាក្សាជាមួយលោក។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីប្រគល់ឯកសារមួយជូនសាក្សី ដើម្បីសួរសាក្សីអំពីបញ្ជីមួយ ដែលប្រហែលជាគាត់អាចធ្លាប់ឃើញនៅគុក ប៉េហ្ស៊ី គឺឯកសារ E3/965។ ដូច្នេះ សុំមេត្តាលោកប្រធាន អនុញ្ញាតឱ្យប្រគល់ឯកសារនេះជូនសាក្សី និងបញ្ចាំងនៅលើអេក្រង់ គឺឯកសារជាភាសាខ្មែរ <00068840>, ERN ជាភាសាបារាំង 00324630 និងជាភាសាអង់គ្លេស 00316312។ នេះជាឯកសារដែលមានចំណងជើងថា "ប្រវត្តិរូបសង្ខេបរបស់អ្នកទោសនៅអនុសេនាធំ៤៤<ដែលបានដោះលែង>" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ

៧៥។ ហើយនៅទំព័រទី១ យើងឃើញមានកងពល៧០៣ និងវរសេនា<តូច>៩៦។

ដូច្នេះ សូមលោកប្រធានមេត្តាអនុញ្ញាតប្រគល់ឯកសារជាភាសាខ្មែរជូនទៅសាក្សី ដើម្បីឱ្យខ្ញុំបានសួរសំណួរទៅកាន់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយនិងឱ្យខាងសោតទស្សន៍ចាក់ផ្សាយនូវឯកសារនេះលើអេក្រង់ទូរទស្សន៍។

*(ការបង្ហាញឯកសារជារូបភាព)*

[០៩:៤៨:១៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំទុកពេលឱ្យលោកពិនិត្យមើលឯកសារនេះ លោកសាក្សី។ ក៏ប៉ុន្តែខ្ញុំសួរសំណួរដំបូងសិនគឺថា តើលោកធ្លាប់ឃើញប្រវត្តិរូបសង្ខេបរបស់អ្នកទោសដែលត្រូវបានដោះលែងនេះទេ? ហើយនិងសំណួរទី២ ខ្ញុំចង់សួរលោកថា តើលោកស្គាល់<វរសេនាតូច>៩៦ នៃកងពល<តូច>៧០៣ទេ? <នៅទីនេះគេថា កងពលតូច ខ្ញុំមិនច្បាស់ថា ការបកប្រែជាភាសាបារាំងត្រឹមត្រូវឬទេ ព្រោះយើងតែងតែនិយាយអំពីកងពលធំ ៧០៣។> លោកអាចបញ្ជាក់បានទេថា នៅលើឯកសារដំបូងនេះនៃឯកសារទំព័រទី១ហ្នឹង ជាភាសាខ្មែរហ្នឹង គឺគេ<និយាយពី>កងពល<ធំ>៧០៣? <>

**លោក សួស ធី៖**

**ឆ៖** កងពលតូច៧០៣ ខ្ញុំស្គាល់ តែចំពោះវរសេនាតូច៩៦ គឺខ្ញុំអត់បានដឹងទេ អត់បានស្គាល់ច្បាស់ទេ។

**ស៖** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ត្រង់ចំណុចនេះ តើលោកធ្លាប់ឮឈ្មោះ ហ៊ីន ដែលមាននៅក្នុងឯកសារហ្នឹងទេ?

**ឆ៖** កន្លងមកយូរហើយ គឺខ្ញុំអត់ដែរដឹង ឮសួរឈ្មោះ ហ៊ីន នេះទេ បាទ។

**ស៖** ខ្ញុំដឹងថាលោកមិនស្គាល់ឯកសារនេះទេ អ៊ីចឹងខ្ញុំមិនសួរអីវែងឆ្ងាយទៅលើខ្លឹមសារនៃឯក-សារហ្នឹងទេ ក៏ប៉ុន្តែខ្ញុំសួរអំពីទម្រង់ទ្រង់ទ្រាយនៃឯកសារនេះ នៅទំព័រទី២ ជាភាសាខ្មែរ គឺ 00068841, ជាភាសាបារាំង 00324631, ជាភាសាអង់គ្លេស 00316313។ ឯកសារនេះមានចំណងជើងថា "ប្រវត្តិរូបសង្ខេបអ្នក<ទោសដែលបាន>ដោះលែង"។ លោកឃើញហើយមានតារាងមួយដែលមាន

ឈ្មោះ អាយុ នាទី ថ្ងៃចូលបដិវត្តន៍...។ល។ ហើយក្នុងនោះ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកនៅគុកប៉េហ្ស៊ី តើលោកធ្លាប់ធ្វើបញ្ជីប្រហាក់ប្រហែលគ្នាហ្នឹងទេ ឬក៏វាខុសគ្នាទាំងស្រុងទៅនឹងអ្វីដែលលោកធ្លាប់ធ្វើនៅគុក ប៉េហ្ស៊ីនោះ?

**ឆ៖** ខ្ញុំ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺបញ្ជីនេះមិនមែនបញ្ជីខ្ញុំទេ ពីព្រោះខ្ញុំទៅហើយ គឺវាចុងឆ្នាំ វាដូច បើតាមមើលឯកសារដែលប្រវត្តិរូប វាខែ១១ដែរ។ ដូច្នេះបញ្ជីនេះ បញ្ជីគេពីមុនមកទេ។

**ស៖** ខ្ញុំយល់ ថាលោកមិនមែនជាអ្នកធ្វើបញ្ជីហ្នឹងទេ យើងច្បាស់ហើយ ក៏ប៉ុន្តែខ្ញុំមិនសួរអ៊ីចឹងទេ។ ខ្ញុំសួរអំពីទ្រង់ទ្រាយ អំពីទម្រង់នៃបញ្ជី ដែលលោកឃើញនៅនឹងមុខលោកហ្នឹង ថាបញ្ជីដែលមានទ្រង់ទ្រាយបែបហ្នឹងនេះ វាដូចគ្នា ឬក៏ស្រដៀងគ្នាទៅនឹងអ្វីដែលលោកធ្លាប់ធ្វើនៅគុកប៉េហ្ស៊ីទេ?

[០៩:៥២:២៥]

**ឆ៖** ចំពោះដែលខ្ញុំធ្លាប់ធ្វើនៅគុកប៉េហ្ស៊ី គឺថាវាទ្រង់ទ្រាយ ឈ្មោះ អាយុ នាទី ឪពុកម្តាយ វាដូច ប៉ុន្តែដល់អាមូលហេតុនេះ គឺអត់ ខ្ញុំអត់មានសិទ្ធិសួរទេ មូលហេតុដែលជាប់។ អាហ្នឹងវា វាខុសកន្លែងហ្នឹង។

**ស៖** នៅគុកប៉េហ្ស៊ី នៅពេលដែលលោកធ្វើបញ្ជី តើលោកធ្លាប់សរសេរមូលហេតុដែលជាប់ឃុំហ្នឹងទេ?

**ឆ៖** នៅគុកប៉េហ្ស៊ី គឺថា ហ៊ា គេមិនអនុញ្ញាតឲ្យខ្ញុំសួរពីរឿងមូលហេតុនៃការចាប់មកទេ។

**ស៖** ខ្ញុំឈប់សួរលោកពាក់ព័ន្ធនឹងឯកសារនេះហើយ សូមលោកទុកចោលចុះ។ ឥឡូវនេះ ខ្ញុំចង់សួរបន្តពីសំណួររបស់លោកមេធាវី កូប៉េ ពាក់ព័ន្ធទៅនឹងទ្រង់ទ្រាយនៃបញ្ជី ដែលលោកធ្វើ។ ដូច្នេះ ខ្ញុំចង់ដឹងថា នៅគុកប៉េហ្ស៊ី តើលោកមានប្រើប្រាស់សៀវភៅ ឬក៏ឯកសារអ្វី ដើម្បីយកមកបំពេញបន្ថែមសម្រាប់ធ្វើបញ្ជីអ្នកទោសទេ?

**ឆ៖** កាលនៅគុកប៉េហ្ស៊ី គឺខ្ញុំអត់មានសៀវភៅ អត់មានអង្គលីលេខ អត់មានអីដើម្បីបញ្ជីទេ គឺខ្ញុំសរសេរតែដៃទេ សរសេរតែដៃហ្នឹង រាយការណ៍តែអ្នកទោសដែលចូលមក ឲ្យ ហ៊ា, ហ៊ា គេយកទៅឲ្យខាងបញ្ជីសួរចម្លើយ។ មន្ទីរ សារ៉ូម ហ្នឹង គេខាងមន្ទីរកងសួរចម្លើយ។ គឺខាង ម៉េង ហ្នឹង។

**ស៖** ដូច្នេះ ពេលដែលលោកធ្វើបញ្ជីហ្នឹង លោកសរសេរនៅលើក្រដាសមួយសន្លឹកៗមែនទេ?

**ឆ៖** គឺខ្ញុំធ្វើបញ្ជី គឺខ្ញុំសរសេរក្រដាសមួយសន្លឹកៗតែម្តង ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា វា ការចងចាំវាឆ្ងាយពេកទៅ វាដូចចាំមិនសូវបានច្បាស់លាស់។ ប៉ុន្តែគ្រាន់តែខ្ញុំបញ្ជាក់ថា ការធ្វើ ព្រោះបញ្ជីចំនួនអ្នក

ទោសចូលមក គឺខ្ញុំអង្កាល់ហ្នឹងសរសេរតែដៃទេ អត់ទាន់មានអីទេ ព្រោះខ្ញុំអង្គុលីលេខក៏អត់ចេះវ៉ៃ ស្អីក៏អត់ចេះដែរ។

[០៩:៥៥:៤១]

**សៈ** ឥឡូវនេះ ខ្ញុំចូលទៅនិយាយនៅរយៈកាលដែលលោកនៅទួលស្លែង គឺលោកប្តូរពីគុកប៉េហ្ស៊ីមកទួលស្លែង។ ជាបឋម ខ្ញុំចង់សួរលោកអំពីមុខងារ និងសម្ភារៈផ្សេងៗដែលលោកមាន។ <ដូច្នេះយើងអាចនិយាយ>ថា ខុសពីនៅគុកប៉េហ្ស៊ី នៅស-២១។ លោកមានសៀវភៅបញ្ជី ដូចដែលបានបង្ហាញនៅក្នុងខ្សែភាពយន្តឯកសារកាលពីម្សិលមិញនេះ គឺថានៅ ស-២១ ហ្នឹង គឺអត់ដូចនៅគុកប៉េហ្ស៊ីទេ គឺលោកមានសៀវភៅធំមួយសម្រាប់ចងក្រងបញ្ជីអ្នកទោសផ្សេងៗ។ តើអ៊ីចឹងមែនទេ?

**ឆៈ** ការដែលមកដល់គុកទួលស្លែង គឺថាសៀវភៅអីក៏អត់ទាន់មាន ដល់ចុង -- ដល់ក្រោយទេបានទើប ហ៊ី គេប្រាប់ឲ្យខ្ញុំធ្វើ។

**សៈ** លោកចាំទេ នៅចាប់ពីពេលណាទៅដែលលោក<ធ្វើការជាអ្នកចុះ>បញ្ជីអ្នកទោសនោះ?

**ឆៈ** ពេលវេលាគឺខ្ញុំចាំអត់ច្បាស់ទេ។

**សៈ** ពេលដែលលោកឆ្លើយទៅសំណួររបស់សហព្រះរាជអាជ្ញាមិនដឹង ឬក៏ចៅក្រមមិនដឹង ខ្ញុំភ្លេចហើយ។ លោកថា ក្រៅពីបញ្ជីអ្នកទោសចេញ-ចូល លោកក៏ទទួលបន្ទុកក្នុងការសរសេរប្រវត្តិរូបសង្ខេបរបស់បុគ្គលិកនៅក្នុងអង្គភាពរបស់លោកដែរ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** ត្រឹមត្រូវហើយ ពីព្រោះដែលបុគ្គលិកនៅស-២១ អាហ្នឹង គឺ ហ៊ី គេអ្នកក្តាប់។ ដូច្នេះចំនួនអីហ្នឹងគេឲ្យខ្ញុំសរសេរចំនួនតាមក្រុមមានប៉ុន្មាន មកកងហា មកកងរយ មានប៉ុន្មាន ឲ្យរាយការណ៍ទៅលើដែរ។

**សៈ** ដូច្នេះតាមរយៈចម្លើយរបស់លោក គឺគាត់ហ្នឹងហើយជាអ្នកឲ្យលោកធ្វើបញ្ជីប្រវត្តិរូបបុគ្គលិកនោះ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកដឹងទេថា ហេតុអីបានជាគាត់ប្រើឲ្យលោកធ្វើប្រវត្តិរូបសង្ខេបរបស់បុគ្គលិកនោះ?

[០៩:៥៨:៤៨]

**ឆៈ** ព្រោះបុគ្គលិកហ្នឹងវានៅក្រោមការក្តោបក្តាប់របស់ ហ៊ី ហើយការរាយការណ៍អីក៏ដោយគឺ ហ៊ី ហ្នឹងគឺវាពឹងទៅលើអ្នកធ្វើបញ្ជីហ្នឹង ឲ្យខ្ញុំធ្វើ ដោយឲ្យខ្ញុំសរសេរ ឲ្យខ្ញុំជួយ ដើម្បីរាយការណ៍ទៅលើដឹងចំនួនពិតប្រាកដ។ បើបុគ្គលិកនៅផ្នែក -- អានេះនិយាយបុគ្គលិកផ្នែកការពារតែប៉ុណ្ណោះទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរបញ្ជាក់លោកពាក់ព័ន្ធទៅនឹងការពិពណ៌នាអំពីស-២១ ឬទួលស្លែង។ លោកបាននិយាយ រៀបរាប់អំពីបរិវេណទី១ បរិវេណខាងក្រៅ ហើយលោកបាននិយាយថាមានរបងស័ង្កសីហ៊ុមព័ទ្ធ<ខណ្ឌចែកបរិវេណទាំងពីរនេះ>។ ដូច្នេះ ខ្ញុំចង់ដឹងថា ពេលដែលលោកទៅដល់ស-២១ ភ្លាមហ្នឹង គឺរបងស័ង្កសីហ្នឹងមានរួចទៅហើយមែនទេ?

**ឆ៖** ការណ៍នេះគឺខ្ញុំចង់មិនច្បាស់ទេ ប៉ុន្តែបើតាមការដឹងរបស់ខ្ញុំ គឺរបងស័ង្កសីដែលធ្វើនៅពេលដែលគុកផ្លាស់ទៅនោះ ទៅកន្លែងគុកទួលស្លែង ពីប៉េហ្ស៊ីទៅ។

**ស៖** លោកបាននិយាយអំពីកម្លាំងពិសេសដែលទទួលបន្ទុក ទទួលអ្នកទោសដែលបញ្ជូនមកស-២១ ហើយលោកក៏បានឆ្លើយថា កន្លែងធ្វើការរបស់លោកស្ថិតនៅខ្លោងទ្វារវិទ្យាល័យនៅជិតរបងខាងក្នុង។ ដូច្នេះ ខ្ញុំចង់សួរបញ្ជាក់លោកថា ក្នុងពេលបំពេញការងារលោកមិនត្រូវបានអនុញ្ញាតឲ្យចេញខាងក្រៅរបងទេ គឺលោកធ្វើការតែនៅខាងក្នុងរបងវិទ្យាល័យតែប៉ុណ្ណោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដណាស់។

[១០:០១:៤០]

**ស៖** លោកបាននិយាយអំពីកន្លែងធ្វើការរបស់លោក គឺលោកធ្វើការជាមួយ ហ៊ី ហើយពេលខ្លះទៅមានក្មេងម្នាក់ឈ្មោះ ឡាន់ មកជួយលោក។ ដូច្នេះ ក្រៅពី ឡាន់, ហ៊ី ហើយនិងអ្នកនាំអ្នកទោសមកឲ្យលោកសរសេរប្រវត្តិរូប តើមានអ្នកណាផ្សេងទៀតដែលត្រូវបានអនុញ្ញាតឲ្យចូលនៅក្នុងកន្លែងដែលលោកធ្វើការទេ?

**ឆ៖** កន្លែងខ្ញុំធ្វើការ គឺមាន ឡាន់ មាន ហ៊ី ខ្ញុំនិង អ្នកថតរូប។ គឺកន្លែងហ្នឹង កន្លែងធ្វើការជាប្រចាំជាមួយអ្នកទោសដែលកង -- ជាមួយអ្នកកងការពារដែលយកអ្នកទោសយកមកចូលខាងក្នុងហ្នឹង។

**ស៖** ពេលដែលលោកនិយាយថា មានអ្នកថតរូបផងដែរ។ អ៊ីចឹងមានន័យថា អ្នកថតរូបហ្នឹងនៅក្នុងកន្លែងដែលលោកធ្វើការហ្នឹងដែរមែនទេ ពេលដែលអ្នកថតហ្នឹង ថតរូបអ្នកទោសក៏លោកនៅក្នុងហ្នឹងដែរ មែនទេអ៊ីចឹង?

**ឆ៖** អ្នកថតរូប គឺគេពេលព្រឹកបានគេមក ពេលយប់អីគេអត់នៅទេប្រចាំនៅហ្នឹង។ គេនៅកន្លែងផ្ទះរបស់គេឯណោះ។ នៅប្រចាំការ គឺនៅកន្លែងហ្នឹង គឺមានតែខ្ញុំ ហើយនិង ឡាន់ ទេ ហើយចំពោះ ហ៊ី ក៏គេអត់មាននៅប្រចាំការនៅហ្នឹងដែរ គេនៅផ្ទះគេខាងក្រៅដែរ។ ប៉ុន្តែគ្រាន់តែមន្ទីរគេកន្លែងហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ដូច្នេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ទៅនឹងសំណួរមុនរបស់ខ្ញុំ គឺអ្នកថតហ្នឹង គាត់ធ្វើការក្នុងកន្លែងតែមួយជាមួយលោកមែនទេ នៅពេលដែលគេថតរូបអ្នកទោសហ្នឹង?

**ឆ៖** អ្នកថត គឺគេថតនៅជាប់ជាមួយខ្ញុំហ្នឹង គេមានបន្ទប់ថតនៅក្បែរកន្លែងខ្ញុំកត់ហ្នឹង។

[១០:០៥:១៧]

**ស៖** បើអ៊ីចឹងមានន័យថា នៅក្នុងបន្ទប់ដាច់ដោយឡែកពីគ្នាមែនទេ? លោកបន្ទប់មួយ ហើយអ្នកថតហ្នឹង គេមានបន្ទប់របស់គេមួយដែរ អ៊ីចឹងមែនទេ?

**ឆ៖** ចំពោះដែលខ្ញុំកត់អ្នកទោសហ្នឹង គឺខ្ញុំមិនមែនកត់នៅក្នុងបន្ទប់ទេ គឺខ្ញុំនៅចំអាបន្ទប់ដែលគេថតហ្នឹង គឺគេដើរចូលមកដល់បន្ទប់កន្លែងអ្នកថតហ្នឹង គឺខ្ញុំដាក់កៅអីមួយនៅកន្លែងហ្នឹង ខ្ញុំសរសេរកន្លែងហ្នឹង។

**ស៖** អ្នកណាជាអ្នកនាំអ្នកទោសមកបន្ទប់ថតរូប?

**ឆ៖** អ្នកនាំអ្នកទោស គឺអ្នកកងការពារដែលមកពីខាងក្រៅហ្នឹង គេនាំរហូតដល់ចូលទៅដល់កន្លែងអគារ។

**ស៖** ពេលដែលលោកសួរសំណួរខ្លីៗទៅកាន់អ្នកទោស តើអ្នកយាមមានវត្តមាននៅទីនុំងទេ?

**ឆ៖** ចំពោះអ្នកយាមគឺ គេយាមតាមអគារហ្នឹង ប៉ុន្តែនេះចំពោះអ្នកដែលយកអ្នកទោសចូលមកគេនៅហ្នឹង គេអត់មានទៅណាទេ គេនៅការពារអ្នកទោសហ្នឹងរហូត។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកសំណួរដំបូងរបស់ខ្ញុំវិញ។ កន្លែងដែលលោកធ្វើការហ្នឹង ក្រៅពីឡាន់, ហ៊ា តើអ្នកណាខ្លះផ្សេងទៀតដែលត្រូវបានអនុញ្ញាតឲ្យចូលមកកន្លែងដែលលោកធ្វើការហ្នឹងដែរ?

**ឆ៖** អ្នកដែលចូលគឺផ្នែកគ្រប់ទាំងអស់ ឲ្យតែមានភារកិច្ចមកៗចូលកន្លែងហ្នឹង គឺគេមានសិទ្ធិចូលមកកន្លែងខ្ញុំធ្វើបញ្ជីហ្នឹង។

[១០:០៧:១៧]

**ស៖** អ៊ីចឹងហើយបានជាខ្ញុំសួរលោកចង់ដឹងហ្នឹង ថាអ្នកណាខ្លះ? ឥឡូវលោកអាចរៀបរាប់ឲ្យបានច្បាស់បន្តិចទៅមើល អ្នកណាខ្លះដែលមានសិទ្ធិចូលមកក្នុងកន្លែងដែលលោកធ្វើការហ្នឹង?

**ឆ៖** ដូចខ្ញុំបញ្ជាក់អ៊ីចឹងគឺថា អ្នកដែលមានការងារដែលទាក់ទងមកក្នុងកន្លែងមន្ទីរកន្លែងខ្ញុំហ្នឹង គឺ គេមានសិទ្ធិចូលហើយ។ ដូចជា កងសួរចម្លើយៗ គេមកសូមលេខបន្ទប់ លេខនេះតាមអ្នកទោសហ្នឹង គឺ គេមានសិទ្ធិចូលមកដើម្បីសួរហើយ។ កងការពារ ដែលគេជាទូទៅឲ្យតែកងការពារគេមិនប្រកាន់កង

ណាៗ ឲ្យតែមានគេយកអ្នកទោសមក គេមានសិទ្ធិចូលកន្លែងហ្នឹងទាំងអស់។

**ស៖** ចុះលោកផ្ទុយទៅវិញ តើលោកមានសិទ្ធិចូលទៅក្នុងកន្លែងរបស់កងសួរចម្លើយទេ?

**ឆ៖** ចំពោះកន្លែងកងសួរចម្លើយ គឺខ្ញុំអត់មានសិទ្ធិទៅទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញដល់ម៉ោងត្រូវឈប់សម្រាកហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឲ្យសាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៩:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួស ធី បញ្ចប់។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំចោទសំណួរឡើងវិញ ហើយខ្ញុំសួរជិតចប់ហើយ។ ខ្ញុំចង់ដឹងថាតើលោកចាំ

ដែរឬទេ នៅពេលដែលលោកចុះឈ្មោះវៀតណាមដំបូងៗគេបំផុតនៅមន្ទីរស-២១ លោកចាំថាពេលណាដែរឬទេ កាលដែលលោកចុះឈ្មោះហ្នឹង?

**លោក សួស ធី៖**

**ឆ៖** ខ្ញុំចុះឈ្មោះហ្នឹង ឥឡូវគឺការកន្លងហួសយូរហើយ គឺខ្ញុំចាំអត់ច្បាស់ទេ ទាល់តែមើលក្នុងបញ្ជីបានដឹង។

[១០:៣០:៤៣]

**ស៖** ឥឡូវខ្ញុំសូមរំឭកលោកជាមួយនឹងអ្វីដែលលោកបានឆ្លើយនៅក្នុងសំណុំរឿង ឌុច គឺនៅសវនាការសំណុំរឿង០០១ ថ្ងៃទី២៨ កក្កដា ឆ្នាំ២០០៩ គឺឯកសារ E3/7466 នៅម៉ោង ១១:៤២នាទីកាលនោះៗ។ គេសួរសំណួរលោកដូចតទៅនេះ "ឈ្លើយសឹកសង្គ្រាមវៀតណាមត្រូវបានគេនាំមកមន្ទីរស-២១ បើតាមលោកដឹង តើពួកគាត់មកដល់ពេលណា ហើយមានចំនួនប៉ុន្មាននាក់ដែរ?" ចម្លើយរបស់លោកដូចតទៅនេះ៖ "ដូចដែលខ្ញុំបានជម្រាបស្ដាប់ហើយ គឺថាឈ្លើយសឹកវៀតណាមមកដល់មន្ទីរស-២១ មិនទៀងទាត់ទេ យើងចុះឈ្មោះជាទូទៅឲ្យតែពេលមានពួកគេមកដល់ ហើយខ្ញុំមិនចាំថាចំនួនប៉ុន្មាននាក់នោះទេ ចាប់បានប៉ុន្មាននាក់ ហើយបញ្ជូនមកប៉ុន្មាននាក់នៅមន្ទីរស-២១នោះទេ។ ខ្ញុំគិតតែពីធ្វើការងារខ្ញុំឲ្យចប់ក្នុង១ថ្ងៃៗតែប៉ុណ្ណោះ"។ សំណួរបន្ទាប់ទៀត ដែលគេសួរទៅលោកដែរនោះ គេសួរថា៖ "តើ<លោកអាចប្រាប់បានទេថា តើឈ្លើយសឹកវៀតណាមហ្នឹងបានចាប់ផ្ដើមមកដល់នៅ>ឆ្នាំ៧៦ <ហើយតើមានឈ្លើយសឹកវៀតណាមមកដល់នៅឆ្នាំ>៧៧ <ឬ៧៨ដែរឬទេ>?" ចម្លើយរបស់លោកដូចតទៅនេះ៖ "នៅឆ្នាំ១៩៧៦-៧៧ មិនមានឈ្លើយសឹកវៀតណាមទេ គឺនៅពេលដែលមានជម្លោះរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជាកើតឡើងហើយទេ បានមានឈ្លើយសឹកវៀតណាមគេយកមកមន្ទីរស-២១"។ នេះជាចម្លើយរបស់លោកនៅក្នុងសំណុំរឿង០០១។ តើធ្វើឲ្យលោកនឹកឃើញដែរឬទេថានៅពេលដែលមានជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមហើយនេះ បានមានឈ្លើយសឹកវៀតណាមគេយកចូលមកមន្ទីរស-២១?

**ឆ៖** នេះខ្ញុំនឹកឃើញថា នៅពេលដែលមានជម្លោះ ទើបបានមានឈ្លើយសឹកវៀតណាមចូលមកក្នុងគុកហ្នឹង។

**ស៖** ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងជម្លោះនេះ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៣៣:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមអភ័យទោសលោកស្រីមេធាវី ដើម្បីបញ្ជាក់ហ្នឹង តើលោក<ស្រី>អាចសុំឱ្យសាក្សីបញ្ជាក់បានដែរឬទេ ពាក្យដែលគាត់និយាយថា ឈ្លើយសឹកនេះ។ តើចំពោះសាក្សីរូបនេះពាក្យថា "ឈ្លើយសឹក"មានន័យថាម៉េច?

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី លោកឮបទអន្តរាគមន៍របស់លោកចៅក្រម ឡាវែន៍ ហើយ ដូចដែលលោកបានប្រើ អង្គាល់នៅសំណុំរឿង០០១នោះ លោកប្រើពាក្យ "ឈ្លើយសឹក"។ អ៊ីចឹងនៅពេលដែលលោកប្រើពាក្យថា "ឈ្លើយសឹក"នេះ គឺលោកសំដៅទៅលើអ្វីដែរ?

**លោក សួស ធី៖**

**ធ៖** នេះពាក្យដែល ថា "ឈ្លើយសឹក" គឺចំពោះទាហានវៀតណាម ដែលទាហានកម្ពុជាប្រជាធិបតេយ្យហ្នឹងចាប់បានមកពីតាមព្រំដែន។

**ស៖** ខ្ញុំអត់មានឯកសារយោងទេ នេះគ្រាន់តែជាសំណួរបន្ត។ បើសិនជាខ្ញុំច្រឡំសូមកែខ្ញុំផង។ លោកបាននិយាយអំពីវត្តមានវៀតណាមស៊ីវិល <ឬ>យោធានៅស-២១ ហើយនិងលោកនិយាយអំពីរបៀបចុះឈ្មោះពួកគេនៅក្នុងបញ្ជីរបស់លោក។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំចង់ដឹងថាតើវៀតណាមស៊ីវិលហើយនិងយោធានេះ មកដល់មន្ទីរស-២១ នៅពេលដែលមានជម្លោះប្រដាប់អាវុធហើយ ឬក៏ពួកគេអ្នកដែលមកដល់ហ្នឹងគឺថា មានពីរក្រុមផ្សេងគ្នា អ្នកខ្លះមកមុនពេលជម្លោះ អ្នកខ្លះមកក្រោយពេលជម្លោះ?

**ធ៖** នេះចំពោះការក្តាប់របស់ខ្ញុំគឺវាមិនបានច្បាស់លាស់។ ដូច្នេះថ្ងៃខែដែលប្រជាជនវៀតណាមដែលចាប់បាននៅយកមកហ្នឹង គឺខ្ញុំអត់បានដឹងច្បាស់ពិតប្រាកដទេ ដូច្នេះ ពីព្រោះកន្លងមកយូរ វាយូរហើយ។ ហើយចំពោះដែល ៗឈ្លើយសឹក ដែលកងទ័ពវៀតណាមដែលកងទ័ពកម្ពុជាប្រជាធិបតេយ្យចាប់បាននោះ គឺអាហ្នឹងវាពេលមានជម្លោះ។

**ស៖** សំណួរដែលខ្ញុំចង់សួរបន្តនោះ ខ្ញុំចង់ដឹងថា តើលោកនៅចាំដែរឬទេថា ជនស៊ីវិលនោះមកក្នុងពេលជាមួយយោធាវៀតណាមដែរ គេចាប់មកហ្នឹងក្នុងពេលជាមួយគ្នា ឬក៏ចាប់ពេលខុសគ្នាទេ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាប់ជនស៊ីវិលនោះ ពេលផ្សេង ចាប់យោធាពេលផ្សេង?

**ឆ៖** ជនស៊ីវិល គឺមិនមកជាមួយយោធា គេគឺមកផ្សេងគ្នា។

**ស៖** តើលោកនៅចាំដែរឬទេ ថាតើពួកគាត់នោះមកដល់ គេចាប់មកមន្ទីរស-២១នៅពេលណាដែរ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ហើយ គឺពេលវេលា គឺកន្លងមកវាយូរហើយ គឺខ្ញុំអត់បានចាំច្បាស់ទេ។ ទាល់តែមើលបញ្ជីបានដឹង ថាពេលវេលាដែលគេចាប់យកមក បានដឹងពិតប្រាកដ។

[១០:៣៧:២០]

**ស៖** ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងការមកដល់នៃពួកវៀតណាម ហើយនិងជម្លោះ។ ខ្ញុំសួរលោកថា តើនៅពេលដែលលោករៀនសូត្រនោះ ខ្ញុំយល់ថាលោកមិនបានចូលរៀនសូត្រច្រើនទេ។ ប៉ុន្តែនៅពេលដែលលោកចូលរៀនសូត្របន្តិចបន្តួចហ្នឹង តើលោកមានធ្លាប់ឮគេនិយាយអំពីដំណើរការជម្លោះ ឬក៏សង្គ្រាមប្រឆាំងនឹងវៀតណាមដែរឬទេ? ក៏ដូចជាស្ថានភាពនៅលើសមរភូមិផងដែរ ពេលដែលលោកចូលរៀនសូត្រ វគ្គរៀនសូត្រហ្នឹង គឺគេមាននិយាយពីបញ្ហាទាំងអស់ហ្នឹងទេ?

**ឆ៖** ដូចដែលខ្ញុំបានជម្រាបអ៊ីចឹង ពេលវេលាវាកន្លងយូរហើយ ដូច្នេះការចាប់អារម្មណ៍របស់ខ្ញុំក្នុងការដែលគេពន្យល់ គឺមិនសូវជាចាប់អារម្មណ៍ប៉ុន្មានទេ ដូច្នេះខ្ញុំដឹងច្បាស់ប្រាកដ គឺគេដែលនិយាយអ្វីខាងក្រៅមិនសូវចាប់អារម្មណ៍ គឺចាប់អារម្មណ៍បំផុតភារកិច្ចរបស់ខ្លួន ហើយបម្រើខាងការងារ ក្នុងមន្ទីរស-២១នេះ។

**ស៖** ជាសំណួរចុងក្រោយ ដើម្បីរំឭកដល់ការចងចាំរបស់លោក តើលោកនៅចាំដែរឬទេថា តើទោះថាជាស៊ីវិល ជនជាតិស៊ីវិលវៀតណាមក៏ដោយ លោក -- ខ្ញុំយល់ហើយថា លោកគ្រាន់តែចោទសំណួរសង្ខេបៗប៉ុណ្ណោះ នៅពេលដែលមានអ្នកទោសមកដល់ ក៏ប៉ុន្តែនៅពេលដែលលោកជួបជនស៊ីវិលវៀតណាម ឬក៏យោធាវៀតណាមនោះ តើលោកចាំថា តើអ្នកទោសទាំងអស់នោះ ដែលគេបញ្ជូនមកមន្ទីរស-២១ ស៊ីវិលក៏ដោយ យោធាក៏ដោយនោះ មកដល់មុនពេលមានជម្លោះ ឬក៏ក្រោយពេលមានជម្លោះ?

**ឆ៖** នេះគឺខ្ញុំអត់បានចាំច្បាស់ទេ ចំពោះអ្នកទោសវៀតណាមដែលចូលមក គឺមិនដឹងជាមុនពេលជម្លោះ ឬក្រោយពេលជម្លោះ ប៉ុន្តែបើសិនជាឈ្លើយសឹក អាហ្នឹងគឺនៅក្នុងពេលជម្លោះហើយ។

[១០:៤០:០៧]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសូមរំឭកការចងចាំរបស់លោក អាននូវអ្វីដែលលោកបាននិយាយនៅសំណុំរឿង០០១ នៅសវនាការថ្ងៃ<២៧> កក្កដា ឆ្នាំ២០០៩ ឯកសារ E3/7465 ប្រហែលជាម៉ោង ១៤:៤៥នាទី កាលនោះនៅខែកក្កដា គេសួរសំណួរលោកដូចតទៅនេះ គឺថា៖ “តើមានទាហានវៀតណាម ឬក៏វៀតណាមស៊ីវិលនៅក្នុងពេលជម្លោះប្រដាប់អាវុធដែរឬទេ?” ចម្លើយរបស់លោក លោកជឿថាលោកពេលសង្គ្រាមនោះទទួលបានទាំងស៊ីវិល ទាំងយោធាវៀតណាម។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើពេលខ្ញុំអានជូនលោកស្ដាប់ហើយនេះ លោកនឹកឃើញដែរឬទេ ថាក្រុមទាំងអស់ គឺថាមានទាំងស៊ីវិលទាំងយោធានោះ មកមន្ទីរ -- គេនាំយកមកមន្ទីរស-២១ នៅពេលមានជម្លោះជាមួយនឹងវៀតណាម ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំគិតថាសំណួរហ្នឹងច្រំដែល លោកប្រធាន គឺថាគាត់ព្យាយាមសួរច្រើនដងហើយ។ ហើយសាក្សីគាត់ឆ្លើយច្បាស់ហើយ គាត់ថាគាត់មិនចាំទេ គាត់មិនដឹងថា <ជនស៊ីវិលវៀតណាមបានមកដល់>មុន ឬក៏ក្រោយជម្លោះនោះទេ។ ហើយការដកស្រង់ចម្លើយគាត់កាលពីឆ្នាំ២០០៩ នោះដូចជាមិនជួយគាត់ប៉ុន្មានទេ សាក្សីនេះប៉ុន្មានទេ ព្រោះថាគាត់បាននិយាយហើយថា ទាំងស៊ីវិល ថាជនស៊ីវិលហើយនិងយោធាហ្នឹងគាត់ទទួលបានពេលក្រោយមានជម្លោះហើយ ក៏ប៉ុន្តែនេះមិនបានបញ្ជាក់ ឬក៏បង្ហាញឲ្យច្បាស់ថា មុនពេលសង្គ្រាមនោះមាន១ជម្លោះនោះ មិនមានអ្នកទោសវៀតណាមមកនោះទេ។ <ខ្ញុំមិនឃើញថារបៀបសួរនេះ អាចផ្ដល់ព័ត៌មានបន្ថែមទៀតទេ ដោយសារសាក្សីបានឆ្លើយច្បាស់លាស់ហើយ។ ដូច្នេះខ្ញុំគិតថា សំណួរនេះច្រំដែល ហើយខ្ញុំជំទាស់នឹងការតាំងសំណួរនេះ>។

[១០:៤២:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំ<មិន>គិតថាសំណួររបស់ខ្ញុំនេះ<>មិនអាចទទួលយកបាន<នោះ>ទេ។ <ខ្ញុំសូមរំឭកថាក្នុងការសួរផ្ទៀងផ្ទាត់ ជាពិសេស>នៅពេលដែលចោទសំណួរទៅសាក្សី១ គាត់ថាគាត់មានបញ្ហាក្នុងការចងចាំ អ៊ីចឹងអ្វីដែលយើងត្រូវធ្វើនោះ យើងត្រូវតែសួរគាត់ឲ្យ -- ផ្ញាំគាត់ទៅនឹងចម្លើយពីមុន១មករបស់គាត់។ <>បើសិនជាព្រះរាជអាជ្ញា<យល់ថា សំណួរនេះមិនបានជួយអ្វីដល់សាក្សីទេ នោះវាមិនសំខាន់ទេ។ សំខាន់គឺថា តើវាអាចជួយឲ្យសាក្សីនឹកឃើញឬអត់តែប៉ុណ្ណឹង។ មិនថា គាត់ឆ្លើយយល់

ស្រប ឬបដិសេធឡើយ។ ដូច្នេះ ខ្ញុំដូចជាមិនឃើញថា ការសួរផ្ទុញគាត់ ដោយប្រើចម្លើយពីមុនរបស់គាត់ មិនអាចទទួលយកបាននោះទេ។ ដូច្នេះសូមអនុញ្ញាតឱ្យខ្ញុំសួរគាត់។ បើគាត់មិនចាំទេ ក៏មិនអីដែរ។ ប៉ុន្តែ>ខ្ញុំអាចសួរសំណួរបែបនេះបានដើម្បីឱ្យគាត់នឹកឃើញអំពីអ្វី ដែលគាត់បានឆ្លើយពីមុនៗមកវិញ។

**ប្រធានអង្គជំនុំ៖**

បាទ អាចឆ្លើយបានសាក្សី ឆ្លើយតបនឹងសំណួរនេះ បើសិនបើលោកយល់សំណួរ ហើយលោកចាំសំណួរ។

អញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

[១០:៤៣:២៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំគិតថាប្រហែលជាត្រូវសួរសំណួរហ្នឹងឱ្យច្បាស់ជាងមុនបន្តិច។ <ដូច្នេះ ចំណុចសំខាន់នៅទីនេះគឺយើងនិយាយអំពី>បញ្ហាជម្លោះ<>។ អ៊ីចឹងចំពោះសាក្សីនេះ ដែលត្រូវឱ្យគាត់ដឹងកាលបរិច្ឆេទឱ្យច្បាស់ ថាគាត់និយាយសំដៅលើកាលបរិច្ឆេទណាដែរ? <តើយើងអាចចាត់ទុកថា មាន>ជម្លោះ<>លាតសន្ធឹងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យតែម្តង <ឬមួយក៏គាត់សំដៅទៅលើជម្លោះជាក់លាក់ដែលបានកើតឡើង?> អ៊ីចឹងសូមឱ្យបញ្ជាក់ពេលវេលាហ្នឹងឱ្យច្បាស់លាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

ក្នុងសំណួរមុនៗរបស់ខ្ញុំហ្នឹង យើងបាននិយាយអំពីកាលបរិច្ឆេទអស់ហើយ ព្រោះថាមានឆ្នាំ ៧៦, ៧៧, ៧៨ ហើយៗសាក្សីគាត់ឆ្លើយថា គាត់មិនចាំពីកាលបរិច្ឆេទច្បាស់លាស់ទេ។ <បញ្ហាកាលបរិច្ឆេទនេះ យើងបានពិភាក្សាជាមួយសាក្សីរួចហើយ ហើយ>ខ្ញុំបាន<សួរសំណួរពាក់ព័ន្ធនឹងបញ្ហា>នេះជាមួយគាត់ហើយ។ អ៊ីចឹងឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីកាលបរិច្ឆេទនេះម្តងទៀត សាកល្បងម្តងទៀត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីនៅពេលដែលលោកនិយាយ ឆ្លើយនៅអង្គាល់សំណុំរឿង០០១ នោះ លោកនិយាយថា នៅពេលសង្គ្រាម យើងបានទទួលទាំងស៊ីវិល ទាំងយោធាវៀតណាម។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកអាចកំណត់កាលបរិច្ឆេទនៃការជម្លោះសង្គ្រាមនេះបានដែរឬទេ ចាប់ផ្តើមពីពេលណា? <តើលោកចាំទេ តើ>ជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមហ្នឹង<ចាប់ផ្តើមនៅពេលណា>?

[១០:៤៤:៤៥]

**លោក សួស ធី៖**

**ឆ៖** ជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមហ្នឹង គឺខ្ញុំវាមិនបានចាំច្បាស់ ចាប់ពីខែណាអី ណា ខែណាទេ។ ប៉ុន្តែខ្ញុំដឹងតែច្បាស់ គឺនៅពេលគេមានឈ្លើយសឹក អាហ្នឹងបានខ្ញុំថាជម្លោះជាមួយនឹង វៀតណាម។ ហើយចំពោះដែលជនស៊ីវិលវៀតណាម ដែលចាប់បានហ្នឹងគឺវាៗ មិនដែលមកជាមួយនឹង ឈ្លើយសឹកទេ គឺមកផ្សេងពីគ្នា។ មកពីផ្សេងពីគ្នា ដូច្នេះ វាមិនមកជាមួយគ្នា ជាមួយនឹងឈ្លើយទេ។

**ស៖** នៅពេលដែលលោកនិយាយថា <ពួកគេត្រូវបាន>គេនាំមក<ក្នុងពេលខុសគ្នា តើពួកគេ ត្រូវបាននាំមក>មុន<> ឬក៏ក្រោយ<>?

**ឆ៖** នេះខ្ញុំសន្និដ្ឋានថ្ងៃខែ វាមិនច្បាស់ទេ ប៉ុន្តែបើតាមខ្ញុំដឹង វាមិនច្បាស់ បើសិនជាថ្ងៃដែលគេ សរសេរក្នុងបញ្ជី អាហ្នឹងបានវាពិតប្រាកដ ចំពោះដែលប្រជាជនវៀតណាមដែលចាប់មកហ្នឹង។ ហើយ ឈ្លើយសឹក ក៏វាមានថ្ងៃខែចុះក្នុងបញ្ជីដែរ។ ដូច្នេះទាល់តែមើលក្នុងបញ្ជីបានដឹងថា មុនប្រដាប់អាវុធ មុន ដែលការឈ្លោះគ្នា ឬក៏ក្រោយ អាហ្នឹងទាល់តែមើលក្នុងបញ្ជី បានដឹងច្បាស់ពិតប្រាកដ។

**ស៖** ខ្ញុំនឹងពិនិត្យមើលនៅពេលក្រោយ គ្រាន់ខ្ញុំ ឥឡូវនេះខ្ញុំគ្រាន់តែចង់ដឹងថា តើលោកដឹងអ្វីខ្លះ ឲ្យច្បាស់លាស់នោះទេ។ តែឥឡូវខ្ញុំចង់សួរលោកទាក់ទងនឹងចំណុចមួយទៀតដែរ សួរដោយខ្លីទេ។ ចៅក្រម ឡាវែន៍ គាត់បានបញ្ចាំងខ្សែភាពយន្ត កុនមួយឲ្យលោកមើល ហើយលោកថាឃើញមានរូប ប៉ុល ពត។ ហើយលោកថា ធ្លាប់មើលជាច្រើនដងដែរ បើតាមខ្ញុំយល់ ឃើញរូប ប៉ុល ពត តាមរូបថត។ ខ្ញុំសួរលោកថា តើលោកបានឃើញរូប ប៉ុល ពត នេះនៅក្នុងរូបភាពទាំងអស់ហ្នឹង កុនអីហ្នឹង នៅពេល ណាដែរ?

[១០:៤៧:២៦]

**ឆ៖** គឺខ្ញុំបានឃើញរូប ប៉ុល ពត នៅពេលដែលគេបញ្ចាំងមើល ប៉ុន្តែមិនដឹងជាកន្លែងណា ពីព្រោះកន្លងមក យូរហើយ គឺខ្ញុំមិនបានដឹងពិតប្រាកដ។

**ស៖** បើលោកអត់ចាំកាលបរិច្ឆេទទេ លោកចាំកន្លែងណាដែរទេ ឃើញរូបហ្នឹងនៅកន្លែងណា ដែរ ហើយក្នុងឱកាសអីដែរ បើមិនចាំកាលបរិច្ឆេទក៏អត់ទៅចុះ?

**ឆ៖** ខ្ញុំមិននិយាយពីរឿងកាលបរិច្ឆេទ ប៉ុន្តែការដែលមើលហ្នឹង ពីព្រោះខ្ញុំវាភ្លេចដែរទៅ មិនដឹង ជាមើល គេបញ្ចាំងនៅកន្លែងណាពិតប្រាកដ ព្រោះខ្ញុំវាអត់សូវចាប់អារម្មណ៍។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ខ្ញុំមិននិយាយពីរូបថតទេ ខ្ញុំនិយាយពីកុនហ្នឹង។ ពេលដែលលោកឆ្លើយទៅលោកថៅក្រម ឡាវែន៍ នោះ លោកបានឆ្លើយអំពីកុនហ្នឹងកាលនុំង។ <> តើ<លោកចាំទេ>កាល<លោកមើលកុន> នោះលោកធ្វើការនៅ ប៉េហ្ស៊ី នៅឡើយទេ ឬក៏លោកធ្វើការនៅមន្ទីរស-២១ហើយ ឬក៏នៅកន្លែងណាផ្សេង?

**ឆៈ** ដូចខ្ញុំជម្រាបអ៊ីចឹងថា កុនហ្នឹងគឺបញ្ចាំង ខ្ញុំបានបញ្ជាក់ហើយថា ការកន្លងដែលវាហួស គឺខ្ញុំមិនបានជាចាំពិតប្រាកដ មិនដឹងជាបញ្ចាំងនៅកន្លែងណាពិតប្រាកដ។ ដូច្នេះខ្ញុំគ្រាន់តែថា មិនដឹងពិតប្រាកដ មិនដឹងជាកន្លែងណា វាអត់ចាប់អារម្មណ៍។

**សៈ** តើកាលលោកបានមើលកុនហ្នឹង គឺនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** គឺនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:៤៩:៤៦]

**សៈ** តើនៅពេលនោះៗ លោកដឹងថា ប៉ុល ពត ហ្នឹង គាត់មានមុខតំណែងអីដែរឬទេ?

**ឆៈ** គេផ្សាយតាមវិទ្យុថា ប៉ុល ពត ហ្នឹងជានាយករដ្ឋមន្ត្រី។ នេះខ្ញុំដឹងប៉ុណ្ណឹង។

**សៈ** ខ្ញុំមានចំណុចមួយទៀត ចង់លើកឡើង។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ គឺគេឃុំខ្លួនលោក។ លោកអាចបញ្ជាក់បានដែរឬទេថា អ្នកណាជាអ្នកចាប់លោកក្រោយពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំហើយនោះ អ្នកណាចាប់លោកឃុំឃាំង?

**ឆៈ** ក្រោយរបបកម្ពុជាប្រជាធិបេយ្យ គឺនៅឆ្នាំ១៩៨៤ហ្នឹង គឺគេចាប់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងជាកម្លាំងណាទៅចាប់ពិតប្រាកដទេ។

**សៈ** នៅពេលដែលគេសួរសំណួរលោក ដើម្បីឲ្យដឹងថាតើគេឃុំខ្លួនលោកនៅឯណានោះ លោកបានបញ្ជាក់ថា លោកមិនដឹងថា នៅប្រទេសកម្ពុជា ឬក៏នៅប្រទេសវៀតណាមទេ។ អ៊ីចឹងខ្ញុំសូមយោងទៅនឹងសេចក្តីសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9320, ERN ជាភាសាបារាំង00280501, ERN ជាភាសាខ្មែរគឺ00052003, ERN ជាភាសាអង់គ្លេសគឺ 00909161។ តើហេតុអីក៏លោកមន្ទិលសង្ស័យលើកន្លែងដែលគេដាក់គុកលោក?

**ឆៈ** ព្រោះខ្ញុំមិនបានដឹងច្បាស់លាស់ ពីព្រោះពេលគេចាប់ខ្ញុំដាក់ឡាន គឺគេចងមុខអស់ហើយ។ ចងមុខអស់ហើយ យកមកដល់ក្នុងគុកគឺ គុកហ្នឹងគឺបិទជិតទាំងអស់ អត់មានបង្អួច អត់មានអីទាំងអស់ គឺជិតស្លុង គឺដល់តែបើកភ្លើងបានមើលឃើញ។ ដូច្នេះខ្ញុំអត់បានដឹងទីតាំងកន្លែងណាពិតប្រាកដទេ។

[១០:៥៣:០០]

**ស៖** ឯកសារដដែល គឺERN ជាភាសាបារាំង 00280502, ជាភាសាខ្មែរ 00052004, ជាភាសាអង់គ្លេស <00909161 ដល់ 62>។ លោកបានឆ្លើយថា លោកមិនច្បាស់ -- ឥឡូវខ្ញុំដកស្រង់អ្វីដែលលោកនិយាយតែម្តង។ សំណួរដែលគេសួរលោកនោះ អង្គាល់នោះដូចតទៅនេះ <>៖ "<តើលោកគិតថា >គុកហ្នឹង មិននៅប្រទេសខ្មែរទេ? <>លោកឆ្លើយថា៖ ប្រហែលជាមិននៅស្រុកខ្មែរទេ។ ហើយគេសួរលោកបន្តទៀត៖ "ថាហេតុអីបានលោកប៉ាននអះអាងថា មិនមែននៅប្រទេសខ្មែរ"? ចម្លើយរបស់លោក៖ "ពីព្រោះឃើញមានអ្នកយាមវៀតណាម។" សូមបញ្ចប់ការដកស្រង់។ តើលោកនឹកឃើញទេថា កាលនោះលោកធ្លាប់ឮ<ឆ្មាំគុក>វៀតណាមនិយាយ <>ហើយអ៊ីចឹងលោកគិតថា លោកមិនមែនជាប់គុកនៅប្រទេសកម្ពុជាទេ?

**ឆ៖** មុនដំបូងគឺខ្ញុំ -- គេអត់ទាន់ឲ្យនេះ ពីព្រោះនៅក្នុងគុកហ្នឹង ខ្ញុំអត់បានដឹង នៅប្រហែលជាមិនដឹងជាប៉ុន្មានខែទេ បានគេបញ្ជូនៗទៅនុ៎ង គឺខ្ញុំអត់ដឹងថា ចាប់អារម្មណ៍ថាទៅកន្លែងណាទេ។ តែដល់ខ្ញុំឮសូរសំឡេងគ្រឹលទៅ ខ្ញុំថា អ្ហ៎ច្បាស់ឡើងរថក្រោះ បាទឡើងលើរថក្រោះ ប៉ុន្តែដល់នេះ ទៅបានដឹងថា យន្តហោះ។ ពេលដែលខ្ញុំដឹងថា នៅវៀតណាម គឺនៅពេលដែលខ្ញុំទៅដល់នោះ ប៉ុន្តែទៅដល់នោះ គេចងមុខទាំងអស់ អត់មានបានដឹងថា កន្លែងណាកន្លែងណីទេ ប៉ុន្តែគុកហ្នឹងក៏វាគុកងងឹតដែរ គេអត់មានមើលឃើញអីទាំងអស់។ ប៉ុន្តែនៅពេលដែលគេអធ្យាស្រ័យខ្ញុំមកឲ្យចេញធ្វើការខាងក្រៅហ្នឹង គឺខ្ញុំ អ្នកយាមគឺច្រើន ភាគច្រើនតែវៀតណាម។ ហើយនៅពេលដែលចេញមកវិញដែលគេនេះមកវិញហ្នឹង គឺខ្ញុំគេបញ្ចេញមកវិញក៏ពេលយប់ដែរ។ យប់ហើយងងឹត បើកមួយយប់ទល់ភ្លឺបានដល់ចំណតរថយន្តអាហ្នឹងគេដោះ គេលែងមុខហើយបានខ្ញុំឃើញថា នៅតាម នៅទឹកដីវៀតណាម។ ហើយបានគេជូនទៅតាមឡានហ្នឹងមកទៀតមក រហូតមកតាមកាណូតមកដល់ មិនដឹងកន្លែងណាកន្លែងណី មកដល់កាណូតកាណូតបើករហូត ដល់មកដល់ច្បារអំពៅបានគេដោះលែងខ្ញុំត្រឹមហ្នឹង គេឲ្យទៅ ត្រឡប់មកផ្ទះវិញ។

[១០:៥៦:០២]

**ស៖** កាលពីម្សិលមិញម៉ោង០៩:០៨នាទី លោកឆ្លើយទៅលោកមេធាវី កូប៉េ ថាលោកត្រូវបានគេបានដោះលែង ហើយគេប្រាប់លោកថាត្រូវកែប្រែខ្លួន ហើយកុំឲ្យប្រឆាំងនឹងគេទៀត។ អ៊ីចឹងពេលដែលលោកនិយាយថា "ប្រឆាំងនឹងគេទៀត"នេះ គេហ្នឹងសំដៅលើអ្នកណាដែរ ពេលគេដោះលែងលោកគេប្រាប់លោកអ៊ីចឹង?

**ឆ៖** អានេះគឺខ្ញុំមើលទៅក្នុងលិខិតដោះលែង គេដាក់ក្នុងលិខិតដោះលែងហ្នឹង គេដាក់សរសេរ អីចឹង។

**ស៖** <>លិខិតហ្នឹងចេញមកពី<ការិយាល័យ>ណាដែរ?

**ឆ៖** លិខិតហ្នឹងគេដាក់កងទ័ព ចេញពីកងទ័ពអី ខ្ញុំអត់បានច្បាស់ ទាល់មើលលិខិតហ្នឹងបានដឹង ដូចកងទ័ពខ្មែរយើងទេ តាមមើលក្នុងលិខិតហ្នឹង។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ តើនៅពេលណាមួយ នៅពេលដែលគេចាប់ខ្លួនលោក ហើយគេឃុំខ្លួនលោកនោះ <តើ>លោកមានសិទ្ធិ<>ការពារ<ខ្លួន>លោក <ប្រឆាំងនឹងការចោទប្រកាន់មកលើរូបលោកទេ?> លោកមានសិទ្ធិទទួលបានមេធាវី ហើយនិងការជំនុំជម្រះអីត្រឹមត្រូវដែរ ឬទេ ឬក៏គេចាប់លោក ហើយលោកគ្មានសិទ្ធិអីតតាំងហ្នឹងគេទាល់តែសោះ?

**ឆ៖** ចំពោះដែលគេចាប់ខ្ញុំហ្នឹងគឺ គេអត់មានឲ្យមានមេធាវី អត់ឲ្យមានអីទាំងអស់ គឺគេទៅដល់ គេចាប់ដាក់គុកតែម្តង។

[១០:៥៨:២៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអរគុណលោក សួស ធី។ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះ ដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី លោកមេធាវីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សួស ធី វិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១០:៥៩:៥១]

សវនាការជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខស-២១។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ឡើងមកកាន់បន្ទប់សវនាការ និងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសហការជាមួយនឹងខាងអនុរក្សមន្ទីរឃុំឃាំងទទួលសាក្សីពីអនុរក្សមន្ទីរឃុំឃាំង និងអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនផងដែរ អង្គជំនុំជម្រះតម្រូវឲ្យមានអនុរក្សមន្ទីរឃុំឃាំងមួយរូបអង្គុយនៅក្បែរសាក្សី នៅក្នុងអំឡុងពេលដែលសាក្សីរូបនេះផ្តល់សក្ខីកម្ម។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី? លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណលោកប្រធាន។ សូមជម្រាបប្រសាសន៍លោកប្រធានថា ខ្ញុំឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច។

[១១:០២:៥៩]

**ស៖** បាទ អរគុណ។ ហើយក្បាលមីក្រូហ្វូន លោកមិនបាច់សម្រួលទេ ខាង អេ.វី ហ្នឹង គេបាន គេអ្នកសម្របសម្រួល ដើម្បីឲ្យមានកម្ពាតគ្នារវាងការឆ្លើយតប និងការសួរ ដើម្បីឲ្យអ្នកបកប្រែ បកប្រែភាសាហ្នឹងបានច្បាស់លាស់ ហើយបានត្រឹមត្រូវ។ បើមិនអ៊ីចឹងទេ វាបន្ទាន់គ្នាពេក មិនអាចបកទាន់ទេ។ អ៊ីចឹងហើយបានជាយើងតម្រូវឲ្យមានបច្ចេកទេសនេះឡើង។ ហើយលោកកើតនៅថ្ងៃខែឆ្នាំណា លោក កាំង ហ្កេកអ៊ាវ លោកចាំទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំកើតនៅថ្ងៃ១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២។

**ស៖** ទីកន្លែងកំណើតរបស់លោក ៗនៅកើតនៅទីកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំកើតនៅភូមិពៅវើយ ឃុំពាងបាង ស្រុកស្ទោង ខេត្ត

កំពង់ធំ។

**ស៖** បាទ អរគុណ។ ហើយលោក កាំង ហ្កេកអ៊ាវ សព្វថ្ងៃនេះ តើលោកនៅកំពុងតែអនុវត្តទោសពន្ធនាគារនៅពន្ធនាគារខេត្តកណ្ដាល ពិតមែនដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពិតមែនរឿងនេះ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ កាំង គី។ ម្ដាយបង្កើតរបស់ខ្ញុំ មាស គឹមសៀវ។

**ស៖** បាទ អរគុណ។ ហើយភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ភរិយារបស់ខ្ញុំបាទឈ្មោះ ឈឹម សុផល ហៅ រ៉ុំ។ ខ្ញុំមានកូនបួននាក់។

[១១:០៥:០០]

**ស៖** បាទអរគុណ។ ហើយលោក កាំង ហ្កេកអ៊ាវ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោក ហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២នេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន របាយការណ៍នេះពិតជាត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយលោក កាំង ហ្កេកអ៊ាវ បច្ចុប្បន្ននេះ តើលោកកាន់មានជំនឿខាងសាសនាអ្វីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយអំពីសាសនា ខ្ញុំបញ្ជាក់ថា ខ្ញុំគោរពកោតខ្លាចពុទ្ធនិយម ខុងជឺនិយម និងគ្រិស្ដនិយម។ ប៉ុនបើនិយាយអំពីការកាន់សាសនាណាមួយ ដើម្បីទៅបដិសេធសាសនាផ្សេងទៀត គឺអត់ទេ។

**ស៖** ប៉ុន្តែបច្ចុប្បន្ននេះ តើលោកប្រតិបត្តិសាសនាអ្វីច្បាស់លាស់? ក្នុងចំណោមសាសនាដែលលោកមានហ្នឹង តើចម្បងបំផុតនៃសាសនាដែលលោកប្រតិបត្តិហ្នឹង តើលោកប្រតិបត្តិសាសនាអី?

កុំអាលទាន់! កុំអាលទាន់!

[១១:០៦:៣៤]

**ឆ៖** ខ្ញុំអាចជម្រាបលោកប្រធានថា ខ្ញុំគ្មានសាសនា ឬក៏អត់កាន់សាសនាមួយណាច្បាស់លាស់ទេ គឺគោរពលទ្ធិពុទ្ធនិយម គោរពលទ្ធិខុងជឺនិយម និងគោរពលទ្ធិគ្រិស្តនិយម ក៏ប៉ុន្តែសាសនា គឺខ្ញុំអត់។ ពីព្រោះពុទ្ធសាសនា ជម្រាបលោកប្រធាន ខ្ញុំបានឆ្លើយនៅក្នុងសវនាការហូរហែមកហើយ ថាខ្ញុំអត់បានបួស ហើយពុទ្ធសាសនាដែលខ្ញុំស្ទុះទៅមិនរួចនឹងគេ គឺរឿងឲ្យលះបង់គ្រឹហាវាស ទៅបួស ហើយខ្ញុំបួសម៉េចកើត បើខ្ញុំចង់បានប្រពន្ធ។ ឯចំណែកខុងជឺនិយម វាជារឿងនេះទេ ជារឿងពុទ្ធ នៃទស្សនវិជ្ជា។ ដល់ក្រោយមកជាមួយនឹងគ្រិស្តនិយម។ ខ្ញុំគិតថា គ្រិស្តនិយម ខ្ញុំបានសម្រេចចិត្តពីឆ្នាំ១៩៧៣ ថាចង់ពិសោធមើល តើគ្រិស្តនិយមវាយ៉ាងម៉េច បានជាអឺរ៉ុបខាងកើត កុម្មុយនីស្តចូលមិនចុះ។ ដូច្នេះខ្ញុំតាមដានរហូតមក ដល់ថ្ងៃ០៦ មករា ១៩៨៦ ខ្ញុំទទួលពិធីជ្រមុជ។ ប៉ុន្តែតាំងពីនោះមក ខ្ញុំតាមដានគ្រិស្តនិយមរហូត។ ហើយខ្ញុំអត់បាននេះ ទទួលពិធីចាក់ប្រេងតាំងជាប៉ាស្ទ័រ ជាគ្រូគង្វាលនៅនេះទេ។

ដូច្នេះខាងគ្រិស្តនិយមនេះ ជាចុងក្រោយហើយ។ បានថាឥឡូវនេះ ខាងគ្រិស្តនិយមក៏ខ្ញុំមិនប្រាថ្នាធ្វើខ្លួនទៅជាគ្រូគង្វាល ខ្ញុំតាំងខ្លួនដូច តេង ស៊ាវភីង អ៊ីចឹង។ បានទទួលពិធីជ្រមុជ បានចូលបក្សកុម្មុយ-នីស្តដូចគ្នា ក៏ប៉ុន្តែជាគ្រិស្តនិយមសម្ងាត់។ ឯចំណែកពុទ្ធសាសនា ក៏អ៊ីចឹង។ ខ្ញុំម៉ែឪ ជាពិសេសខ្មោចជីតាខ្ញុំខាងម្ដាយ ជាអ្នកជឿគោរពព្រះពុទ្ធសាសនាយ៉ាងជ្រាលជ្រៅ។ ឯចំណែកឪពុកខ្ញុំបន្សល់ទុកកេរដំណែលខាងខុងជឺនិយមឲ្យខ្ញុំច្រើនដែរ។

ដូច្នេះសរុបមក ខ្ញុំសូមប្រកាសថ្ងៃនេះថា បើនិយាយពីសាសនា ខ្ញុំអត់កាន់សាសនាណាមួយទេ គឺជាមនុស្សដែលអត់ជឿ -- អត់កាន់សាសនា ក៏ប៉ុន្តែមានជំនឿលើសាសនា។

[១១:០៩:០២]

**សៈ** បាទឥឡូវនេះ វាពាក់ព័ន្ធនឹងនីតិវិធីធ្វើសម្បថចំពោះមុខអង្គជំនុំជម្រះទេ ដោយសារអង្គជំនុំជម្រះស្ដាប់លោកផ្ទាល់នាពេលនេះ ថាបច្ចុប្បន្ននេះលោកមិនមានសាសនាទេ ថាតើលោកអាចប្រកាសជាសាធារណៈនូវជំហររបស់លោកក្នុងការបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ក៏ដូចជាសាធារណជនជាតិ និងអន្តរជាតិនាពេលនេះថា អ្វីដែលលោកនឹងឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ គឺជាចម្លើយពិត គឺលោកអាចឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងពាក់ព័ន្ធជាមួយនឹងរឿងហេតុទាំងឡាយ ដែលភាគីនឹងសួរពាក់ព័ន្ធជាមួយនឹងលោកនៅក្នុងអង្គហេតុនៃកំពុងធ្វើសវនាការនេះប៉ុណ្ណោះ។ តើលោកអាចធ្វើអ៊ីចឹងបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្ម័គ្រចិត្តនឹងធ្វើដោយពេញចិត្តបំផុត។ ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនិងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

**សៈ** បាទ អរគុណលោកសាក្សី។ ហើយតទៅនេះ យើងប្រាប់អំពីករណីយកិច្ចនិងសិទ្ធិរបស់លោកនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ ហើយអំពីករណីយកិច្ច អង្គជំនុំជម្រះសូមរំឭកដល់សាក្សី ភាគីនិងសាធារណជនជ្រាបថា លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច រយៈពេលកន្លងទៅនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចផ្តន្ទាទោសគាត់ដាក់ពន្ធនាគារអស់មួយជីវិត ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលបានប្រព្រឹត្តនៅទីក្រុងភ្នំពេញ និងនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុង១៧ មេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ៧៩។ ហើយតាមអំណាចស្ថាពរចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ នៅក្នុងវិសាលភាពនៃអង្គហេតុឧក្រិដ្ឋកម្មទាំងពីរដែលបានផ្តន្ទាទោសចំពោះសាក្សី បានចូលជាស្ថាពរហើយ ហើយនិងកំពុងអនុវត្តទោស។ សាក្សី ត្រូវឆ្លើយតបទៅនឹងសំណួររបស់ភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក ទោះបីជាសំណួរ ឬការឲ្យលោកសាក្សីរៀបរាប់ អត្ថាធិប្បាយនាំឲ្យចម្លើយតប ឬអត្ថាធិប្បាយរៀបរាប់ហ្នឹង គឺដាក់ពិរុទ្ធភាពលើខ្លួនឯងក៏ដោយ ពីព្រោះនៅក្នុងក្របខ័ណ្ឌនៃអាជ្ញាអស់ជំនុំ។

[១១:១១:៤២]

ហើយលោក កាំង ហ្កេកអ៊ាវ ក្នុងឋានៈជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះលោកត្រូវតែឆ្លើយតបរាល់សំណួរដែលសួរ ឬការឲ្យលោកអត្ថាធិប្បាយរៀបរាប់ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យចម្លើយតប ឬអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ឬអត្ថាធិប្បាយដែលក្រៅវិសាលភាពនៃអង្គហេតុ និងឧក្រិដ្ឋកម្មពីរដែលបានផ្តន្ទាទោសចំពោះលោកបានចូលជាស្ថាពរហើយ ហើយដែលអង្គជំនុំជម្រះបានរំឭកជម្រាបលោកអម្បាញ់មិញនេះ។

ហើយលោក កាំង ហ្កេកអ៊ាវ ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹងបានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

អំពីសិទ្ធិ ទោះបីលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តន្ទាទោសគាត់នៅក្នុងសំណុំរឿង០០១បានចូលជាស្ថាពរហើយក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមិនអាចដកហូតទាំងស្រុងនូវសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីរូបនេះបានដែរ ដែលអាចកើតឡើងពាក់ព័ន្ធនឹងអង្គហេតុផ្សេងៗទៀត ដែលមិនត្រូវបានវិនិច្ឆ័យទោសនៅក្នុងសំណុំរឿង ០០១។

[១១:១២:៥៦]

ហើយអង្គជំនុំជម្រះក៏សូមជម្រាបសួរភាគី និងសាធារណជនជ្រាបផងដែរថា អង្គជំនុំជម្រះបានសួរបញ្ជាក់សាក្សីរូបនេះរួចហើយ ពីតម្រូវការរបស់គាត់នៃសូមជំនួយពីមេធាវីប្រឹក្សាសាក្សីសម្រាប់គាត់ តែលោក កាំង ហ្គេកអ៊ាវ បានបដិសេធ។

ហើយលោក កាំង ហ្គេកអ៊ាវ ក្នុងឋានៈជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកមានសិទ្ធិអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយរៀបរាប់ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងចំពោះសំណួរ ឬការអត្ថាធិប្បាយរៀបរាប់ណាដែលនាំឲ្យដាក់ពិរុទ្ធភាព ដែលនៅក្រៅវិសាលភាពនៃអង្គហេតុនៃឧក្រិដ្ឋកម្មទាំងពីរ និងដែលបានផ្តន្ទាទោសលោកចូលជាស្ថាពរ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ហើយសំណួរចុងក្រោយ សួរថា តើលោក កាំង ហ្គេកអ៊ាវ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក នេះនៅក្នុងសំណុំរឿង០០៣ ឬក៏០០៤ ដែរឬទេ? ហើយប្រសិនបើមាន ធ្វើៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា? លោកចាំដែរឬទេ?

[១១:១៤:១២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំពោះសំណុំរឿង០០៣ ខ្ញុំបានធ្វើម្តង ជាមួយនឹងចៅក្រម យូ ប៊ុនឡេង និង ហ្សីជីរិច ហ្វិចប្លង់ ហ្នឹងលើកដំបូង។ ហើយដល់ក្រោយមក ខាងចៅក្រមស៊ើបអង្កេតអន្តរជាតិ បូឡែនឌ័រ បញ្ជូនអ្នកសួរចម្លើយជំនួសម្នាក់ឲ្យហៅខ្ញុំមកសួរនៅនេះ។ សួរបាន៣ថ្ងៃ ខ្ញុំឈឺ ខ្ញុំសូមត្រឡប់ទៅពេទ្យតាខ្មៅវិញ អ៊ំនែ! ពន្ធនាគារតាខ្មៅវិញ។ ដូច្នេះនៅលើកក្រោយនេះ ខ្ញុំធ្វើបានតែ៣ថ្ងៃទេ។

**សៈ** បាទ អរគុណ។ ហើយមុនពេលចូលមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោក

បានពិនិត្យមើល ឬបានអានទូវកំណត់ហេតុដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត ឬជាមួយអ្នកស៊ើបអង្កេត និង/ឬក៏ការិយាល័យសហចៅក្រស៊ើបអង្កេតហ្នឹង សម្រាប់សំណុំរឿង០០៣ ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់បានអានល្អិតទេ ព្រោះអាងលើខ្លួនខ្ញុំចាំ នូវអ្វីដែលខ្ញុំបាននិយាយ។ ដូច្នេះខ្ញុំអត់បានអានទេ ក៏ប៉ុន្តែខ្ញុំចាំ ហើយទទួលខុសត្រូវថា ខ្ញុំនឹងឆ្លើយអត់ខុសពីនោះប៉ុន្មានពេកទេ ខុសបន្តិចបន្តួចជាពាក្យសម្តី ប៉ុនគោលគំនិតនៅដដែល។

[១១:១៦:០០]

**ស៖** អ៊ីចឹងតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបានហ្នឹង លោកអាចបញ្ជាក់ច្បាស់លាស់ថែមទៀតបានដែរទេ ថាចម្លើយសក្ខីកម្ម កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ឬក៏បានពិនិត្យមើល ដើម្បីរំឭកការចងចាំនោះ វាត្រឹមត្រូវ វាសមស្រប ស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានធ្វើជាមួយនឹងចៅក្រម សហចៅក្រមស៊ើបអង្កេត ក៏ដូចជាអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីពេលមុន នៅទីនេះនុ៎ងដែរឬទេ? វាសមស្របវាស៊ីសង្វាក់គ្នាដែរឬទេ ដែលលោកបានមើលត្រួសៗនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់បានមើលទេឯកសារដែល ថូម៉ាស សរសេរ ក៏ប៉ុន្តែខ្ញុំគិតថា ព្រោះខ្ញុំអាងលើខ្ញុំចាំ។ ដូច្នេះគឺខ្ញុំមិនបានអាន ព្រោះខ្ញុំអាងលើខ្ញុំចាំ។

**ប្រធានអង្គជំនុំ៖**

បាទ មិនអីទេ បញ្ហានេះគ្រាន់តែសួរបញ្ជាក់ ដើម្បីឲ្យប្រាកដថា អ្វីដែលមានការរៀបចំនោះ គឺមានការចងចាំ។ សំខាន់ គឺចាំនូវអ្វីដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ដែលវាតែងតែពាក់ព័ន្ធជាមួយនឹងសួរសំណួររបស់ភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះ ដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះផ្អែកលើមូលដ្ឋាននោះ ដើម្បីសួរដេញដោលចំពោះលោកជាសាធារណៈនៅក្នុងសវនាការនេះប៉ុណ្ណោះ។

ហើយដើម្បីអនុវត្តតាម ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីកាំង ហ្កេកអ៊ាវ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៤ថ្ងៃនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:១៨:១០]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ជម្រាបសួរលោក កាំង ហ្កេកអ៊ាវ ខ្ញុំឈ្មោះ ខេល លីសាក់។ ខ្ញុំនឹងធ្វើការសាកសួរលោកទៅលើបញ្ហាមួយចំនួនក្នុងរយៈពេលពីរបីថ្ងៃខាងមុខនេះ។ កាលពីលើកមុន លោកបានមកក្នុងសាលសវនាការនេះ នៅខែមេសា ២០១២ គឺ៤ឆ្នាំមុន ក្រោយពេលដែលលោកបានបញ្ចប់សក្ខីកម្មរបស់លោក។ គឺបានន័យថា ក្រោយពេលដែលលោកចាកចេញពីសាលសវនាការនេះ នួន ជា បានលើកឡើងអំពីសក្ខីកម្មរបស់លោកនៅតុលាការនេះ។ គឺគាត់បាននិយាយច្រើនអំពីលោក ប៉ុន្តែគាត់មិនបានឆ្លើយតបទៅនឹង<សំណួរ ក្រោយពេលគាត់ធ្វើសេចក្តីថ្លែងការណ៍>នោះទេ។ ប៉ុន្តែឥឡូវនេះខ្ញុំសូមអាននូវអ្វីដែល<គាត់>បាននិយាយ ហើយនិងផ្តល់ឱកាសឲ្យលោក ដើម្បីឆ្លើយតបទៅនឹងអ្វីដែលគេនិយាយនោះ។ ឥឡូវនេះខ្ញុំនិយាយអំពីកំណត់ត្រាថ្ងៃ១៨ ខែ៤ ឆ្នាំ២០១២ ម៉ោងប្រាំបួន<ដប់បីនាទី>ព្រឹក។ លោក នួន ជា បាននិយាយដូចតទៅនេះ នៅព្រឹកនោះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំចង់ជម្រាបដល់ប្រជាជនកម្ពុជាថា ខ្ញុំមិនដែលទទួលខុសត្រូវចំពោះការដំណើរការនៅមន្ទីរស-២១នោះឡើយ។ អ្វីដែល ឌុច បានចោទប្រកាន់ចំពោះខ្ញុំ គឺជារឿងមិនពិតប្រាកដ ហើយជារឿងអយុត្តិធម៌បំផុតសម្រាប់ខ្ញុំ។ ខ្ញុំមិនដែលបញ្ជា ខ្ញុំមិនដែលទទួលបានឯកសារពី ឌុច ឡើយ ហើយខ្ញុំក៏មិនដែលជាមេដឹកនាំរបស់ ឌុច ដែរ។" សូមបញ្ចប់ការដកស្រង់។

លោកសាក្សី ដូច្នេះឥឡូវនេះខ្ញុំសូមផ្តល់ឱកាសជូនលោក ដើម្បីឆ្លើយតបទៅនឹងអ្វីដែល នួន ជា បានលើកឡើងកាលពីព្រឹកនោះ។ សូមអញ្ជើញ!

[១១:២០:២៧]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ការបដិសេធរបស់ ពូនួន ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលមែនទែន។ ខ្ញុំមិនស្មានថាវាដល់អ៊ីចឹងសោះ។ មន្ទីរស-២១ ក៏ដូចជាមន្ទីរនគរបាលទាំងអស់នៅក្នុងរបបកម្ពុជាប្រជា -- នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា វាស្ថិតនៅក្រោមការដឹកនាំរបស់បក្សកុម្មុយ-

នីស្តកម្ពុជា វាស្ថិតនៅក្រោមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ថាខ្លាំងត្រូវតែកម្ទេច វាចេញនៅឆ្នាំ១៩៧១ ដោយមហាសន្និបាតលើកទី៤របស់បក្ស។ មហាសន្និបាតហ្នឹងហើយ ដែលគេចាត់តាំងរូបខ្ញុំឲ្យធ្វើជាប្រធានមន្ទីរនគរបាលភូមិភាគពិសេស ហើយមន្ទីរនគរបាលភូមិភាគពិសេសហ្នឹង វាស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់សមាជិកមជ្ឈិមម្នាក់គឺ វន វ៉េត ដែលជាសមាជិកការិយាល័យនយោបាយមជ្ឈិមបក្ស។ ដោយហេតុនេះហើយ ដែលនៅពេលសវនាការលើកមុន សក្ខីកម្មខ្ញុំលើកមុន លោកមេធាវី សុន អរុណ សួរថា ឥឡូវសាក្សីលោកនិយាយមើល តើលោកនៅជាមួយនឹងក្រសួងការពារប្រទេស (ក្រសួងការពារប្រទេសហ្នឹងសំដៅ សុន សេន) តើក្រសួងការពារប្រទេសណែនាំខ្ញុំយ៉ាង -- លោកយ៉ាងម៉េច? ខ្ញុំឆ្លើយថា ស-២១ នេះវាចាត់តាំងឡើយដោយអំណាចមាត្រា៨នៃលក្ខន្តិកៈបក្ស។ សូមបញ្ជាក់ថា មេធាវី សុន អរុណ សួរខ្ញុំបញ្ហានេះពីរដង បីដង នៅចុងក្រោយបំផុត វគ្គចុងក្រោយបំផុត ក៏នៅតែសួរខ្ញុំបញ្ហានេះទៀត។ ខ្ញុំនៅតែឆ្លើយ ថាមន្ទីរស-២១ វាចាត់តាំងឡើងក្រោមអំណាចមាត្រា៨នៃលក្ខន្តិកៈបក្ស។ ហើយបានខ្ញុំបបួល សុន អរុណ ថាមេធាវីឥឡូវយើងត្រូវគ្នា យើងនាំគ្នាសុំអនុញ្ញាតតុលាការបញ្ចាំងមាត្រា៨នៃលក្ខន្តិកៈបក្សដាក់លើអេក្រង់ ហើយខ្ញុំសូមអានជូនប្រជាជនកម្ពុជាលោកជ្រាប ប្រជាជនសាកលលោក លោកជ្រាប។ សុន អរុណ ថាមិនបាច់ទេ។

នេះបញ្ហានេះគឺវាអ៊ីចឹង។ បានគាត់ថា បងនួន ពូនួន គាត់បដិសេធបញ្ហានេះ ខុសហើយ។ ក្នុងបក្សកុម្មុយនីស្តកម្ពុជា អ្នកណាមិនគោរពបក្ស អ្នកណាដែលធ្វើការអីក្រៅពីលេខា ហើយនិងអនុលេខាបក្សសម្រេច។ នេះការចាត់តាំងរបស់កុម្មុយនីស្តកម្ពុជា គឺវាអ៊ីចឹង។ ដូច្នេះការបដិសេធរបស់ ពូនួន គ្មានន័យ។

[១១:២៤:០៥]

**ស៖** យើងនឹងនិយាយបន្តទៀតអំពី នួន ជា នៅក្នុងពេលដែលយើងសាកសួរគ្នានេះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមដោយឲ្យលោកបង្ហាញនូវទិដ្ឋភាពទូទៅអំពីការចូលរួមរបស់ នួន ជា នៅស-២១ គឺខ្ញុំនិយាយអំពីការចូលរួមទូទៅ គឺថាតាំងពីមុនពេលដែល សុន សេន ទៅសមរភូមិបូព៌ា ក៏ដូចជានៅក្រោយពេលដែល សុន សេន បានទៅសមរភូមិនៅភូមិភាគបូព៌ា។ ដូច្នេះខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីតួនាទីរបស់ នួន ជា នៅ<ស-២១>ក្នុងរយៈពេលទាំងមុន និងក្រោយពេល សុន សេន ទៅសមរភូមិនោះ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ដំបូងខ្ញុំសូមនិយាយអំពីរចនាសម្ព័ន្ធខាងចាត់តាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

របស់មជ្ឈិមបក្ស។ រចនាសម្ព័ន្ធខាងចាត់តាំងរបស់មជ្ឈិមបក្ស ពូនួន គាត់ជាអនុលេខាធិការមជ្ឈិមបក្ស ផង ហើយជាសមាជិកការិយាល័យនយោបាយមជ្ឈិមបក្សទៀត។ សមាជិកការិយាល័យនយោបាយមជ្ឈិមបក្ស នៅបក្សកុម្មុយនីស្តកម្ពុជាមិនដែលប្រើពាក្យហ្នឹងទេ។ គេប្រើពាក្យ "គណៈប្រចាំការ" គេប្រើពាក្យ "៨៧០"។ ឥឡូវនេះ ដោយនិយាយដល់ពាក្យនេះ ពេលនេះខ្ញុំសូមនិយាយថា៨៧០ នរណាខ្លះ? ការិយាល័យនយោបាយមជ្ឈិមបក្សអ្នកណាខ្លះ។ ការិយាល័យនយោបាយមជ្ឈិមបក្ស ទី១មាន ប៉ុល ពត , ទី២ ពូនួន, ទី៣ អៀង សារី, ទី៤ សុន សេន, ទី៥ វន វេត, ទី៦ សុន សេន, ទី៧ ខៀវ សំផន។ មើល ខ្ញុំរាប់អំមិញដូចជាលើសម្នាក់។ ទី១ ប៉ុល ពត, ទី២ ពូនួន, ទី៣ អៀង សារី, ទី៤ វន វេត, ទី៥ សុន សេន, ទី៦ ខៀវ សំផន។ នេះការិយាល័យនយោបាយមជ្ឈិមបក្ស។

[១១:២៧:១១]

ខ្ញុំសូមបញ្ជាក់មួយម៉ាត់ទៀតនូវពាក្យដែលខ្ញុំនិយាយអំមិញ។ ការិយាល័យនយោបាយមជ្ឈិមបក្សនេះ បើនៅក្នុងបក្សផ្សេងទៀត ជាពិសេសបក្សចិនដែលខ្ញុំឧស្សាហ៍បានអានឯកសារចំហរបស់គេនោះ។ គេនិយាយចំហថា ការិយាល័យនយោបាយមជ្ឈិមបក្ស។ ឯចំណែកបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំមិនដែលឮ សុន សេន គាត់និយាយពាក្យថា "ការិយាល័យនយោបាយមជ្ឈិមបក្ស" ទេ។ គាត់និយាយតែ "គណៈប្រចាំការ" ឬក៏ "៨៧០"។ ហើយខ្ញុំសូមបន្ថែមមួយម៉ាត់ទៀតទៅចុះ ដើម្បីឲ្យឃើញវាទំនាស់ផ្ទៃក្នុងនៅក្នុងនេះ។ បើពួកអតីតអ្នកតស៊ូ គេច្រើនហៅការិយាល័យនយោបាយមជ្ឈិមបក្សថា "ពួកបញ្ញាជន" ឬក៏ហៅថា "ពួកភ្នំពេញ"។ បានហៅថារចនាសម្ព័ន្ធខាងចាត់តាំងវាអ៊ីចឹង។

ពីខែ៣ ឆ្នាំ១៩៧៦ ដែលខ្ញុំបានចាត់តាំងជាប្រធាន ស-២១ រហូតដល់ថ្ងៃ១៥ សីហា ១៩៧៧ ពិតមែនខ្ញុំមិនដែលបានជួប ពូនួន ផ្ទាល់ៗមាត់ទេ អត់សោះ។ នេះមិនបាច់និយាយពី ប៉ុល ពត ទេ។ ប៉ុល ពត ខ្ញុំឃើញគាត់តែនៅពេលដែលឧទ្ទេសនាមឯកសារ ចម្ងាយ១០ម៉ែត្រពីគ្នា ហើយនិងពិធីបុណ្យ១៧ មេសា ចម្ងាយពីខ្ញុំទៅប៉ុល ពត ប្រហែលជា១០ម៉ែត្រជាង អើយើងនិយាយប៉ុននុំងទៅចុះ ពន្លើសបន្តិច។

ដូច្នេះជាក់ស្តែងក្នុងរយៈកាលនេះ ខ្ញុំអត់មានជួប ពូនួន ដោយផ្ទាល់មាត់ទេ ក៏ប៉ុន្តែ សុន សេន គាត់យកទៅនិយាយ បងនួន អ៊ីចេះ, បងប៉ុល អ៊ីចុះ។ អចិន្ត្រៃយ៍អ៊ីចេះ ៨៧០អ៊ីចុះ វាមានហូរហែ។ ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្តែងមួយ អានេះវាជាប៉ះពាល់ដល់ក្រុមគ្រួសារខ្ញុំតែម្តង។ ប្អូនថ្លៃខ្ញុំឈ្មោះ កៅលី តុងហ្គួត ត្រូវចាប់មក។ បញ្ជូន -- គេចាប់នៅកំពង់ធំនោះទេ ហើយវាលួចសរសេរសំបុត្រផ្ញើមកដល់ខ្ញុំ។ ខ្ញុំឲ្យសំបុត្រនោះទៅ សុន សេន។ ដល់ខ្ញុំជូនសំបុត្រនោះទៅ សុន សេន ស្រាប់មួយសន្ទុះ ខ្ញុំ

ឃើញគេបញ្ជូនប្អូនខ្ញុំបង្កើត ហើយនិងប្អូនថ្លៃខ្ញុំ មកដល់ស-២១។ ហើយពេលហ្នឹង សុន សេន គាត់ប្រាប់ថា ទុកប្រើទៅ កុំអាល។ ហើយដល់ក្រោយមកទៀត សុន សេន គាត់ប្រាប់ខ្ញុំថា បងនួន ឲ្យមិត្តសួរចម្លើយទៅ។ ខ្ញុំដឹង ពាក្យថា សុន សេន "បងនួន ឲ្យមិត្តសួរចម្លើយហ្នឹង" ខ្ញុំដឹង ខ្ញុំដឹងថាឲ្យខ្ញុំចាប់។ ខ្ញុំសួរដោយមិនចាប់។ ដល់ក្រោយមកអាប្អូនថ្លៃខ្ញុំនេះ វាធ្វើកំហុស។ ខ្ញុំថា អ្នកទុកមិនបានទេ ត្រូវតែចាប់។

[១១:៣១:១០]

នេះរឿងដែលខ្ញុំឮ ជារឿងមួយជាក់ស្តែង ហើយខ្ញុំចាំអត់ភ្លេចទេ ពីរឿង សុន សេន ត្រូវតែស្នើយោបល់ បងនួន ឬ បងប៉ុល ជាពិសេស បងប៉ុល និងបងនួននេះ ពីរនាក់។ លោកមើលក្នុងឯកសារបក្ស ប្រហែលជាឯកសារខែ ១២ ខែ៣អីហ្នឹង មែនឯកសារថ្ងៃ១៥ មើល!មើល! មិនមែនឯកសារថ្ងៃ ១០ ខែ១០ទេ។ ក្នុងឯកសារនេះ និយាយអំពីរបបប្រធានពីរ គឺប្រធានមួយ អានេះគាត់អត់បញ្ជាក់ច្បាស់ក្នុងឯកសារណា។ របបប្រធានពីរគឺមួយ ត្រូវដឹងទាំងអស់គ្នា មួយមិននៅ មួយទៀតអាចចាត់ការបាន។ នេះខាងឯកសារ វាបញ្ជាក់អ៊ីចឹង។ រួចខាងជាក់ស្តែង ដែលប្រើប្រាស់ ហើយទាក់ទងដល់ផ្ទាល់ខ្លួនខ្ញុំ ហើយដែលខ្ញុំមិនភ្លេចគឺរឿងហ្នឹង។ បងនួន, បងសុន សេន ថា "បងនួន គាត់ឲ្យមិត្តសួរទៅ"។ ហើយដល់ក្រោយថ្ងៃ១៥ សីហា ១៩៧៧ ដែលបង សុន សេន គាត់ទទួលបញ្ជាឲ្យទៅសមរភូមិ ខ្ញុំនៅធ្វើការជាប់ជាមួយបងនួន, បងនួន ចុះមក។ ហ្នឹងហើយបានជាខ្ញុំជម្រាបចៅស៊ើបអង្កេតកាលនៅសម័យស៊ើបអង្កេតនោះ។ កាលនោះ ម៉ាកសែល ឡឺម៉ុងដ៍ និង យូ ប៊ុនឡេង ថា មិនមែនខ្ញុំឡើងថ្នាក់ទេ គឺនួន ជា គាត់សម្រុតខ្លួនមកជួបខ្ញុំ។ ដូច្នេះស-២១នេះ មហាជនធម្មតាគេហៅថា "មន្ទីរនគរបាលមជ្ឈិម" ព្រោះវាទទួលការគ្រប់គ្រងណែនាំបញ្ជាពីអចិន្ត្រៃយ៍មជ្ឈិមបក្ស និយាយឲ្យចំទៅទៀតគឺការិយាល័យនយោបាយមជ្ឈិម ឬក៏៨៧០ហ្នឹង។ ហើយភស្តុតាងជាក់ស្តែង ខ្ញុំសូមជូនពីរហ្នឹង។

[១១:៣៣:៣២]

**ប្រធានអង្គជំនុំ៖**

បាទៗ អរគុណ។ ឥឡូវនេះដល់ពេល បាទឥឡូវនេះដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ។ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុង

បន្ទប់សនវការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

ហើយដូចគ្នានេះដែរ គឺបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់រង់ចាំរៀបចំសម្រាប់សាក្សី ដែលនៅពីក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅកន្លែងផ្តល់សក្ខីកម្ម នៅវេលាម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកសាក្សី!

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណលោកប្រធាន។ សូមអនុញ្ញាតបញ្ជាក់បន្ថែមបញ្ហាបី ដែលខ្ញុំព្រឹកមិញនិយាយច្រឡំមួយ ហើយនិងភ្លេចនិយាយពីរ។ ដែលខ្ញុំនិយាយច្រឡំ គឺមហាសន្និបាតមជ្ឈិមបក្ស ដែលខ្ញុំរាយការណ៍ជូនលោកព្រះរាជអាជ្ញាថា ជាមហាសន្និបាតលើកទី៤ តាមពិតខ្ញុំច្រឡំទេ គឺមហាសន្និបាតលើកទី៣។ នេះបញ្ហាទី១ ដែលខ្ញុំសូមបញ្ជាក់ថែម កែតម្រូវពីមតិដែលខ្ញុំបានរាយការណ៍ជូនព្រឹកមិញ។ ទី២ ខ្ញុំសូមនិយាយអំពីរឿងដែលខ្ញុំអត់ទាន់បាននិយាយ គឺរឿងឯកសារដែលនិយាយអំពីវត្តមាន ពួនួន នៅក្នុងការចាត់ចែងរឿងស-២១។ ចម្លើយរបស់ឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត មកពីកងពល១៦៤។ ខ្ញុំជូនជាសេចក្តីសង្កេតដល់សហចៅក្រមស៊ើបអង្កេតថា គ្រប់តែចំណារ សុន សេន ចារទៅជូនខាងលើ គឺសំដៅប៉ុល ពត ដោយ សុន សេន សេរសេរថា “គោរពជូនបង”។ ដោយឡែកឯកសារនេះ សុន សេន គាត់សរសេរថា “គោរពជូនបងនួន ផ្ទាល់”។ ខ្ញុំបញ្ជាក់ថា ដែល “គោរពជូនបងនួន ផ្ទាល់” នេះគឺ សុន សេន ចារទៅក្នុងពេលដែល ប៉ុល ពត អវត្តមាន ដោយប្រាប់ថាឈឺ ហើយឲ្យ ពួនួន ទទួលភារៈជានាយករដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មន្ត្រីស្ដីទី។ ដូច្នេះនេះជាភស្តុតាងមួយ ដែលបញ្ជាក់ថា ការងារនេះ វាមាន បងនួន ជាប់ជាមួយនឹង ប៉ុល ពត តាមគោលការណ៍ប្រធានពីរ។

[១៣:៣៣:២៨]

ឯកសារមួយទៀត និយាយអំពីការ ចំណារលើឈ្មោះ ចំណារលើសេចក្ដីសារភាពរបស់ឈ្មោះ ម៉ុក សំអុល ហៅ ហុង មកពីក្រសួងសង្គមកិច្ច ផ្នែកជំងឺគ្រុនចាញ់។ ចំណារហ្នឹង ពេលដែលសហចៅក្រមស៊ើបអង្កេតសួរខ្ញុំ មុនដំបូងខ្ញុំឆ្លើយថា ចំណាររបស់ សុន សេន។ ដល់ក្រោយមកសហចៅក្រមស៊ើបអង្កេតសួរខ្ញុំទៀត យូរខែក្រោយមក ខ្ញុំថា អត់ទេ ចំណារ ពូនួន។ ដូច្នេះភស្តុតាងទាំងពីរនេះ វាបញ្ជាក់ថា ការងារទាំងអស់ សុន សេន ជាអ្នកចេញមុខក៏ដោយ មិនចេញមុខក៏ដោយ ក៏មាន បងនួន នៅក្នុងនុំងជាអ្នកគ្រប់គ្រងតាមគោលការណ៍ប្រធានពីរ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។ សូមចប់។

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកសាក្សី។ ក្រោយនេះ យើងខ្ញុំនឹងលើកយកឯកសារមួយចំនួនមកសួរលោក។ <លោកស្គាល់ឯកសារទាំងអស់នោះ>ហើយ <ប៉ុន្តែ>ក៏មានឯកសារថ្មីមួយដែរ <ដែលប្រហែលជា>លោក<មិនទាន់បាន>ពិនិត្យមើលឯកសារនេះ<ទេ។ យើងនឹងពិនិត្យឯកសារនោះទាំងអស់គ្នា>។ ខ្ញុំសូមឱ្យលោកបញ្ជាក់ចំណុចមួយ ពាក់ព័ន្ធនឹងរឿងដែលលោកជម្រាបមកយើងព្រឹកនេះ លោកថាមានមនុស្សប្រាំមួយនាក់ ដែលជាសមាជិកការិយាល័យនយោបាយមជ្ឈិមបក្សនៅភ្នំពេញ។ ខ្ញុំចង់សួរថា ហេតុម៉េចបានជាលោករាប់ ខៀវ សំផន ចូលនៅក្នុងក្រុមប្រាំមួយនាក់នេះដែរ ដោយមិនរាប់បញ្ចូលនូវ តាម៉ុក និង សោ ភឹម ផង?

[១៣:៣៥:៣៨]

**ឆ៖** ហាត់ណាស់ សូមទោស ដកដង្ហើមតិចសិន។ អរគុណ ខ្ញុំសូមចាប់ផ្ដើមឆ្លើយ។ តាម៉ុក និង សោ ភឹម ជាមនុស្សនៅក្នុងចំណោមបុគ្គលទាំងប្រាំពីររូប ដែលស្ថិតនៅក្នុងសមាសភាពមួយដែលគេហៅថា "គណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស"។ ខ្ញុំបានរាប់ជូនសហចៅក្រមស៊ើបអង្កេតតាំងពីដើមទីមក។ អចិន្ត្រៃយ៍មជ្ឈិមបក្សមានទី១ ប៉ុល ពត, ទី២ បងភឹម (សោ ភឹម), ទី៣ បងម៉ុក, ទី៤ អៀង សារី, ទី៥ វន វ៉េត, ទី៦ សុន សេន អ្ហា!ភ្លេចនរណាទៀតហើយ។ មើល ទី១ ប៉ុល ពត, ទី២ បងនួន (ពូនួន) ទី២ បងនួន ទេ, ទី៣ បងភឹម, ទី៤ បងម៉ុក, ទី៥ អៀង សារី, ទី៦ វន វ៉េត និងទី៧ សុន សេន។ ដូច្នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រាំពីរនាក់នេះនៅក្នុងអចិន្ត្រៃយ៍មជ្ឈិម។ ដោយឡែកនៅក្នុងអចិន្ត្រៃយ៍មជ្ឈិមនេះ គឺពីរនាក់ អត់នៅក្នុងការិយាល័យនយោបាយមជ្ឈិមបក្សទេ គឺបងភឹម និង បងម៉ុក។ ដោយឡែក បងខៀវ សំផន គាត់មិនទាន់ជាសមាជិកការិយាល័យនយោបាយមជ្ឈិមបក្សទេ អ្ហ៎ាសូមទោស មិនមែនជាគណៈកម្មាធិការមជ្ឈិមបក្សទេ។ នេះគិតតាមពី១ឆ្នាំ ពីមហាសន្និបាតឆ្នាំ៧៥, ៧៦ រហូតដល់មហាសន្និបាតឆ្នាំ៧៨នេះ។ ដំបូងគាត់អត់នៅក្នុងអចិន្ត្រៃយ៍មជ្ឈិមបក្សទេ តែគាត់ជាសមាជិកការិយាល័យនយោបាយ។ ខ្ញុំហត់ណាស់ សូមសម្រាកបន្តិច ហើយសឹមខ្ញុំរាប់រៀបភស្តុតាងដែលនិយាយអំពីសមាជិកការិយាល័យនយោបាយទាំងប្រាំមួយនាក់ហ្នឹង។ សូមទោស ហត់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកសាក្សី ប្រសិនណាជាលោកអាចឆ្លើយបាន លោកប្រាប់មកថា លោកឆ្លើយបាន។ ហើយបើលោកហត់ឆ្លើយមិនបានទេ លោកគ្រាន់តែប្រាប់ថា លោកនឿយហត់ ឆ្លើយមិនទាន់បានទេ សម្រាកបន្តិចសិន ឬក៏យ៉ាងណា ពីព្រោះយើងចង់យល់ឲ្យបានច្បាស់។ <វាពិបាកយល់ណាស់នូវអត្ថន័យនៃពាក្យដែលលោកនិយាយម្តងហើយម្តងទៀតថា "ខ្ញុំហត់ណាស់" នោះ។>

[១៣:៣៨:៣៥]

**លោក ឌេល លីសាក់៖**

យើងខ្ញុំព្យាយាមសួរពីរបីសំណួរទៀត ហើយខ្ញុំសួរសំណួរជាក់លាក់តែម្តង។

**លោក កាំង ហ្គេកអ៊ាវ៖**

ខ្ញុំដកដង្ហើមឲ្យស្រួលបន្តិចទេ។ រួចដល់កាលណាខ្ញុំស្រួល ខ្ញុំលើកដៃ ខ្ញុំនិយាយតទៅទៀត។ សូមកុំថែមសំណួរមកទៀត ខ្ញុំបង្ហើយសំណួរនេះ។

**ឆ៖** ដូច្នេះខ្ញុំសូមបន្ថែមភស្តុតាងដែលបញ្ជាក់ថា បងខៀវ សំផន ស្ថិតនៅក្នុងការិយាល័យនយោបាយមជ្ឈិមបក្ស ដែលគេហៅថា “គណៈប្រចាំការ” ឬគេហៅថា “គណៈ៨៧០” នោះ។ ទី១ នៅពេលសម័យស៊ើបអង្កេត--

**ប្រធានអង្គជំនុំ៖**

ឌុចៗ កុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ៊្គីសសេ៖**

សូមអរគុណលោកប្រធាន។ អំមិញនេះខ្ញុំចាំបន្តិចដែរ មុននឹងធ្វើការកត់សម្គាល់នេះ។ ខ្ញុំចង់និយាយកាលតាំងពីព្រឹកមិញមកម្ល៉េះ ក៏ប៉ុន្តែដើម្បីឲ្យច្បាស់លាស់ទាំងអស់គ្នា ដើម្បីកុំឲ្យចម្លើយហ្នឹងវែងពេក ហើយយើងអាចផ្ដោតទៅលើអ្វីមួយបានឲ្យច្បាស់នោះ។ កាលពីព្រឹកមិញនេះយើងបានស្ដាប់ ការស្ដាប់នូវសំណុំរឿង០០២/១ហើយៗ សាក្សីនេះគាត់បាន រូបនេះ គាត់បានសិក្សាពីសំណុំរឿងបានច្រើន ហើយអង្កាល់ដែលនៅក្នុងសម័យអង្គហេតុនោះ គាត់មិនដឹងរឿងទេ មិនដឹងរឿងរ៉ាវទាំងអស់នេះទេ។ ហើយអង្កាល់ដែលគាត់មកផ្ដល់សក្ខីកម្មនោះ គឺគាត់ធ្វើការអត្ថាធិប្បាយច្រើនណាស់ ដែលគាត់ធ្វើអត្ថាធិប្បាយទៅលើអង្គហេតុជាច្រើនដែលគាត់មិនបានដឹងពីកាលសម័យនោះទេ។

អ៊ីចឹងយើងត្រូវបែងចែកឲ្យច្បាស់ថា តើកាលសម័យអង្គហេតុនោះ គាត់ដឹងរឿងរ៉ាវដែរ ឬក៏មិនដឹង? ហើយឬក៏គាត់ដឹងក្រោយមកទេ ដោយសារគាត់អានបានច្រើនទៅ គាត់ដឹងរឿង។ អ៊ីចឹងយើងត្រូវដឹងអំពីប្រភពនៃចំណេះដឹងគាត់ឲ្យបានច្បាស់លាស់ តើគាត់កំពុងតែនិយាយក្នុងឋានៈជាសាក្សី ឬក៏ក្នុងឋានៈជាអ្នកជំនាញ? អ៊ីចឹងយើងត្រូវបែងចែកចំណុចនេះឲ្យបានច្បាស់លាស់។ ហើយបើតាមចម្លើយរបស់គាត់កាលពីព្រឹកមិញនេះ វាធ្វើឲ្យខ្ញុំចង់សួរទៅអង្គជំនុំជម្រះឲ្យបែងចែកត្រង់ចំណុចនេះឲ្យច្បាស់ កុំឲ្យភាគីសួរទៅគាត់ឆ្លើយក្នុងឋានៈជាអ្នកជំនាញផង ជាសាក្សីផង លោកប្រធាន។

[១៣:៤១:១៩]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំនឹងសួរសំណួរលម្អិតទៅកាន់សាក្សីពាក់ព័ន្ធនឹង ខៀវ សំផន នៅពេលក្រោយ ហើយខ្ញុំចង់ឲ្យគាត់ពន្យល់ទៅនឹងអ្វីដែលគាត់បានលើកឡើងព្រឹកមិញនេះ។ <យើងនឹងចូលដល់ចំណុចនោះដោយលម្អិតពេញលេញតែម្ដង> លោកស្រីមេធាវី<នឹងមានភាពកក់ក្ដៅ។> គាត់គឺជាសាក្សី ហើយជាប្រធានមន្ទីរសន្តិបាល ជាប្រធានមន្ទីរសន្តិសុខ<នៅក្នុងកម្ពុជាប្រជាធិបតេយ្យ>។ គាត់ស្គាល់ថាអ្នកណាជាអ្នកណានៅក្នុងរបបនោះ <ហើយគាត់ដឹងថា អ្នកណាមានតួនាទីអ្វី>។ ខ្ញុំនឹងសួរគាត់លម្អិត ហើយលោកស្រីវិញគឺថា លោកស្រីនឹងមានឱកាសសួរមកកាន់គាត់<នៅពេលដល់វេនលោកស្រី>។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ <ការជំទាស់របស់ខ្ញុំគឺ>ស្របជាមួយនឹងសហការីរបស់ខ្ញុំ លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រីមេធាវី ហ្គីសសេ។ <ខ្ញុំគិតថា វាសំខាន់ខ្លាំងណាស់ ដែល>ចាប់តាំងពីពេលដំបូងមកសាក្សីគួរតែឆ្លើយថា តើការដឹងរបស់គាត់នាពេលនោះ គាត់ដឹងត្រឹមប៉ុនណា។ យើងដឹងហើយថា គាត់បានផ្ដល់ភស្តុតាងយ៉ាងច្រើនដែលថាអ្នកណាជាសមាជិកនៃគណៈអចិន្ត្រៃយ៍។ ហើយបើគាត់ចង់និយាយបន្ថែមដោយសារថានៅក្នុងឆ្នាំ១៩៧៧ គាត់ថា ប៉ង់ បានប្រាប់គាត់ថាអ៊ីចឹង មិនជាអ្វីទេ។ <>ក៏<ប៉ុន្តែ បើសិនជា>គាត់<>ប្រើប្រាស់ចំណេះដឹងរបស់គាត់ចេញពីប្រភពសៀវភៅ ដេវីដ ឆេនដ៍ល័រ ក៏<គ្រប់ទម្រង់ទាំងអស់នៃប្រភពព័ត៌មានទីពីរ ឬក៏ក្នុងសំណុំរឿង>ហ្នឹង វាជាបញ្ហា។ អ៊ីចឹងជាសំណូមពររបស់ខ្ញុំ ជាសំណូមពរដ៏ទទូច សូមឲ្យបង្គាប់ទៅឲ្យ ទៅដល់សាក្សីតាំងពីដើមដំបូង ឲ្យប្រាប់តែពីការដឹងរបស់គាត់នាសម័យកាលនោះ។ កុំលើកឡើងពីការទើបតែនឹងដឹងចេញពីសៀវភៅ ឬក៏ចេញពីសំណុំរឿងទៅបានហើយ។

[១៣:៤៣:២៦]

**លោក ឌេល លីសាក់៖**

លោកប្រធានមិនមានការបញ្ជាក់ថា គាត់ដឹងពីសៀវភៅនោះទេ។ គាត់បានរាយការណ៍ទៅដល់<>សមាជិកនៃគណៈអចិន្ត្រៃយ៍។ <>គាត់<ជាសាក្សីតែម្នាក់គត់នៅក្នុងតុលាការនេះ> ដែល<ជា>អ្នក<>រាយការណ៍ផ្ទាល់ទៅគណៈអចិន្ត្រៃយ៍។ <ការដែលស្នើឡើងថា គាត់មិនមានចំណេះដឹងក្នុងរឿងនេះ គឺជាការគួរឲ្យអស់សំណើច> ហើយដល់វេនមេធាវីការពារក្ដីទាំងពីរនេះ គឺថាគាត់មានឱកាសនឹងសួរផ្ទុញមកសាក្សីវិញ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមទោស សម្រាប់ខ្ញុំវាហាក់ដូចជាថា> តាំងពីព្រឹកមិញមកទល់ពេលនេះ <>សាក្សី<នេះតែងតែ>បានឆ្លើយថា<> ការដឹងរបស់គាត់នេះ<>តាមរយៈ<>ប្រភព<មកពី>ណា<ហើយ>។ <គាត់បានបញ្ជាក់សេចក្ដីថ្លែងការណ៍ជាបន្តបន្ទាប់។ ដូច្នេះវាពិតជាក់ស្ដែងណាស់ថា ចំណេះដឹងរបស់គាត់បានមកពីសេចក្ដីថ្លែងការណ៍ទាំងអស់នោះ។ ខ្ញុំចង់និយាយថា បើលោកសួរទៅគាត់នៅក្រោយសំណួរទាំងអស់ថា "តើលោកដឹងរឿងនោះមកពីណា?" នេះពិតជាមិនមែនជាវិធីដែលអាចអនុវត្តបាននោះទេ។> កន្លងមកនេះខ្ញុំឃើញថា ដូចមិនទាន់មានបញ្ហាអ្វីទេ។ មេធាវីការពារក្ដី ដល់វេនគឺថាលោកលោកស្រីអាចនឹងសួរមកកាន់បញ្ជាក់សាក្សីបាន <ក្នុងករណីដែលគាត់មិនបានបញ្ជាក់ថា តើគាត់បានប្រភពនោះមកពីណា។> ប៉ុន្តែចាប់តាំងពីពេលចាប់ផ្ដើមមកដល់ពេលនេះ <គាត់តែងតែនិយាយជាញឹក

ញាប់ថា “ខ្ញុំបានឮរឿងនេះពីទីនេះ ពីទីនោះ”>។

[១៣:៤៤:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:០១]

**ប្រធានអង្គជំនុំ៖**

បាន អរគុណ។ ហើយអ៊ីចេះ យើងដោះស្រាយបញ្ហានេះដូច្នេះ បញ្ហាយើងគិតថា វាទំនងជាពិបាកក្នុងការគ្រប់គ្រងបែងចែកឲ្យច្បាស់លាស់ ហើយនិងជ្រះស្រឡះ រវាងអ្វីដែលការយល់ដឹងរបស់គាត់បានធ្វើការកត់សម្គាល់ ធ្វើការសង្កេត ធ្វើការមានបទពិសោធន៍ផ្ទាល់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់ឆ្លងកាត់ ហើយនិងបទពិសោធន៍កន្លងមកទៀត ដែលគាត់ឆ្លងកាត់ ក្នុងឋានៈគាត់ជាជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០១ ក៏ដូចជាធ្វើសាក្សីពាក់ព័ន្ធជាមួយនឹងសំណុំរឿង០០២/០១កន្លងមក ឬក៏នៅក្នុងសំណុំរឿងដទៃទៀតហ្នឹង វាជាបញ្ហាលំបាកមួយ។ ប៉ុន្តែយ៉ាងហោចណាស់ ក៏សូមអាចភាគីដែលយល់ដឹងពីបញ្ហានេះ ហើយសូមបញ្ជាក់ពីប្រភពព័ត៌មានបន្ថែម ដែលគាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះផង ដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់លើបញ្ហានេះ ថាតើគាត់យល់ដឹងពីបញ្ហានេះ កាលៈទេសៈណា នៅក្នុងសម័យណា។ ហើយបើសិនជាគាត់កម្រិតត្រឹមតែការយល់ដឹង ការឃើញ ការឮ ការកត់សម្គាល់ ការបំពេញមុខងាររបស់គាត់ នៅក្នុងពិសោធន៍ដែលគាត់បានអនុវត្តនៅក្នុងឋានៈជាប្រធានមន្ទីរសន្តិសុខ ស-២១ ក្នុងរបបកម្ពុជាប្រជាធិប-តេយ្យទេ អានោះគឺជាការត្រឹមត្រូវហើយ ក្នុងឋានៈជាសាក្សី។

[១៣:៤៨:១៣]

ហើយបញ្ហាទី២គឺអង្គជំនុំជម្រះសូមជួយរំឭកដល់លោកសាក្សី លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ថា អ៊ីចេះ ដោយសារតែយើងបារម្ភអំពីបញ្ហាសុខភាពរបស់លោក ដែលមានបញ្ហាហត់ ហើយការប្រឹងប្រែងឆ្លើយ គឺការអរគុណរបស់អង្គជំនុំជម្រះដែលសង្ឃឹមថា រឿងរ៉ាវអ្វីៗដែលលោកបានប្ដេជ្ញាចំពោះមុខអង្គជំនុំជម្រះ ថានឹងនិយាយតែការពិតនោះ គឺអង្គជំនុំជម្រះគិត និងសង្ឃឹមថា នឹងបានជាប្រយោជន៍នៅក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ ចំពោះសក្ខីកម្មរបស់លោក។ ប៉ុន្តែបើជាការល្អនោះ គឺគួរតែប្រើប្រាស់នៅក្នុងការស្តាប់ចម្លើយ -- អ៊ំ! ស្តាប់សំណួរ ហើយនិងឆ្លើយតប នៅក្នុងកម្រិតដែលសំណួរដែលសួរទៅបានហើយ ដើម្បីឲ្យទី១ ចំសំណួរ។ ទី២ គឺលោកអាចកាត់បន្ថយនូវការប្រឹងប្រែងឆ្លើងតប

នេះ វាធ្វើឲ្យសុខភាពលោកពិបាក ហត់ក្នុងការឆ្លើយតប ព្រោះសក្ខីកម្មរបស់លោកនឹងផ្តល់រហូតដល់ ១០ថ្ងៃ -- ដល់៩ថ្ងៃឯណោះ។ ហើយនេះគ្រាន់តែជាសម្រួលទេ។ ហើយបញ្ហាបញ្ជាក់បន្ថែមទៀត ទំនង ជាភាគីនឹងអាចខ្លីៗ លើកលែងតែសំណួរដែលភាគី ឬអង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើអត្ថាធិប្បាយ អា ហ្នឹង សូមលោករៀបរាប់អត្ថាធិប្បាយទៅតាមបែបអត្ថាធិប្បាយរៀបរាប់ដូចសំណួរអ៊ីចឹង អាហ្នឹងបាន ត្រឹមត្រូវ។ ប៉ុន្តែសំណួរនៅទីនេះ បើយើងប្រើប្រាស់សំណួរឆ្លើយតបខ្លីៗ ហើយបើសំណួរសេសសល់ លោកមិនអាចទាន់ឆ្លើយបាន ប្រហែលជាទំនងភាគីម្ចាស់សំណួរនឹងសួរលោកបន្ថែមទៀតហើយ។ បើ យើងគិតថា ធ្វើដូច្នេះ នឹងអាចសម្រួលទាំងដំណើរការនៃការស្តាប់ផង ហើយទាំង ពិសេសគឺលោកដែល មានបញ្ហាសុខភាពហ្នឹង អាចឆ្លើយតបនឹងសំណួររបស់ភាគីបាន។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅថ្ងៃបន្តបន្ទាប់មកទៀត ខ្ញុំនឹងសួរសំណួរជាក់លាក់ទៅកាន់លោកអំពី ខៀវ សំផន ហើយថាតើលោកដឹង<ដោយរបៀប>ណា។ ប៉ុន្តែឥឡូវនេះខ្ញុំចង់ឲ្យលោកផ្តោតសំខាន់ទៅលើកិច្ចប្រជុំ លើក ទី១ ដែលលោកបានជួបប្រជុំជាមួយ នួន ជា។ លោកបានលើកឡើងព្រឹកមិញនេះ ថាគឺនៅពេល ដែល សុន សេន ត្រូវបានចាកចេញទៅកាន់សមរភូមិ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ លោកជួបប្រជុំជាមួយនឹង នួន ជា ដំបូងនៅពេលណា? នៅកន្លែងណា? អ្នកណាខ្លះមានវត្តមាន?

[១៣:៥១:០៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ថ្ងៃនោះ គឺថ្ងៃ១៥ ខែសីហា ១៩៧៧។ បើតាមខ្ញុំចាំ ថ្ងៃនោះ មិត្តប៉ង់ ហៅខ្ញុំទៅធ្វើការជាមួយបង។ គាត់អត់បញ្ជាក់បងណាទេ។ ទៅដល់គាត់នាំខ្ញុំឡើងទៅ ជិះម៉ូតូសំដៅទៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ហើយឡើងទៅជាន់លើ។ ដល់ទៅ ទៅជួប បងនួន នៅទី នោះ។ ធម្មតាធ្វើការជាមួយមេ តែពីរនាក់ទេ គឺខ្ញុំទល់នឹងគាត់។ ថ្ងៃហ្នឹងហើយដែលខ្ញុំជួប បងនួន ពូនួន ជាលើកទី១។ ទៅដល់អត់មាននិយាយច្រើនទេ ពូនួនប្រាប់ខ្ញុំថា “មិត្តខៀវ ទៅសមរភូមិហើយ មិត្តមក ធ្វើការជាមួយនឹងខ្ញុំ។” នេះខ្លឹមសារសង្ខេបតែប៉ុណ្ណឹងឯង ដែលយើងជួបគ្នាជាលើកដំបូង គឺថ្ងៃហ្នឹង។

**ស៖** តើការជួបប្រជុំនេះ មានតែលោក និង នួន ជា ទេឬ ឬក៏មានអ្នកដ៏ទៃទៀតដែរ?

**ឆ៖** ការដែលមេហៅខ្ញុំទៅធ្វើការទាំងបងខៀវ សំផន សុំទោស ទាំងបងសុន សេន ហើយឬក៏បងនួន ជា ខ្ញុំទៅជួបតែពីរនាក់ទល់គ្នាទេ មួយនឹងមួយ។ ខ្ញុំមានសៀវភៅកំណត់ហេតុមួយទៅ សម្រាប់ចារ កត់ត្រានូវអ្វីដែលគាត់ណែនាំ របៀបវារៈដែលគាត់ប្រជុំគ្នានឹងខ្ញុំថ្ងៃនោះ ហើយនិងស្អីដែលគាត់ណែនាំ ខ្ញុំចារ ខ្ចីៗ យកទៅអនុវត្ត ដឹកនាំអនុវត្ត។ ដូច្នេះគ្មាននរណាជាទី៣ ចូលទេ។

**ស៖** ខ្ញុំមានចំណាប់អារម្មណ៍ចំពោះកិច្ចប្រជុំនេះ នៅក្នុងកិច្ចប្រជុំលើកទី១ ជាមួយ នួន ជា នេះតើ នួន ជា គាត់បានដឹងថា ស-២១ <ជាអ្វីទេ>? <តើគាត់មានបានស្នើសុំឲ្យលោកពន្យល់ថា>ស-២១ <ជា>អ្វី<ទេ>?

[១៣:៥៣:៥៩]

**ឆ៖** ថ្ងៃណោះ និយាយអំពីសម្តីរបស់ ពូនួន មកចំពោះខ្ញុំ និយាយខ្លីតែប៉ុណ្ណឹង "មិត្តខៀវ ទៅសមរភូមិហើយ មិត្តមកធ្វើការជាមួយនឹងខ្ញុំ។" ពាក្យថា "មកធ្វើការជាមួយនឹងខ្ញុំ" វាមានន័យគ្រប់គ្រាន់នូវការអនុវត្តដែលយើងខ្ញុំធ្វើក្រោមបញ្ជារបស់ បងខៀវ ហើយ បងខៀវ ធ្វើការក្រោមបញ្ជាគាត់រួចទៅហើយ។ ដូច្នេះគឺនិយាយឲ្យចប់ទៅ គឺគាត់ដឹង។

**ស៖** តើកិច្ចប្រជុំជាលើកទី១នេះ មានរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំអត់បានផ្ទៀងនាឡិកាទេ ក៏ប៉ុន្តែបើតាមចាំ មិនយូរ ខ្ញុំធ្វើការជាមួយ បងនួន មិនដែលយូរទេ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ នៅក្នុងកិច្ចប្រជុំលើកទី១នេះ គឺថាលោកមិនបានចំណាយពេលរហូតទៅដល់រាប់ម៉ោង ដើម្បីពន្យល់ទៅកាន់ នួន ជា ថាស-២១គឺជាអ្វីនោះទេ។ តើអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** អរគុណ។ ខ្ញុំអត់មានចំណាយពេលរាប់ម៉ោងទេ។ ធ្វើការ ពូនួន យ៉ាងច្រើនត្រឹមតែប្រាំដណ្តប់ *មីនុត* យ៉ាងច្រើនបំផុតផុតលេខហើយ ភាគច្រើន ៧តែ១០*មីនុត*។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅប្រធានមួយដែលត្រូវចំណាយពេលច្រើនបន្តិចជាមួយនឹងលោក គឺបញ្ហាសំខាន់ៗនៅក្នុងសវនាការយើងសព្វថ្ងៃនេះ ជាពិសេសពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើអតីតមន្ត្រី និងទាហានរបប លន់ នល់។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ទាហាន លន់ នល់ មន្ត្រីលន់ នល់ និងនគរបាល លន់ នល់ គឺជាគោលដៅនៃការចាប់ខ្លួន និងការសម្លាប់ពីសំណាក់ពួកខ្មែរក្រហមដែរឬក៏យ៉ាងណា នៅ<>ក្រោយថ្ងៃ១៧ មេសា ១៩៧៥ មក?

[១៣:៥៦:៣៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំសូមជម្រាបអំពីប្រវត្តិខ្ញុំបន្តិច ១៧ មេសា ខ្ញុំនៅអមលាំងទេ អត់មានភារកិច្ចធ្វើអីទេ។ ថ្ងៃ២០ មិថុនា ១៩៧៥ ទើបឃើញមេហៅខ្ញុំមករៀន។ ដល់រៀនហើយ ថ្ងៃ១៥ សីហា ដដែល ដូចអា១៥ សីហា ដែលមេទៅពីនេះហ្នឹង។ គាត់ហៅខ្ញុំពីរនាក់ ណាត ទៅឧទ្ទេសនាមថាបក្សឱ្យកកើតមន្ទីរសន្តិបាល ហើយមន្ទីរសន្តិបាលហ្នឹងមាន ណាត ប្រធាន ខ្ញុំអនុប្រធាន។ ហ្នឹង ហើយក្រោយមក ខ្ញុំក៏ចាប់ផ្តើមការងារ មិនមានការងារធ្វើការជាមួយ ណាត ទេ អាមន្ទីរនគរបាលហ្នឹង គេមានរួចរបស់គេទៅហើយ។ ខ្ញុំ មេឱ្យដើរប្រមូលឯកសារពីផ្ទះអ្នកធំ មានផ្ទះលន់ នល់ ផ្ទះវ៉ាន់ ស (រដ្ឋមន្ត្រីក្រសួងគិញនោះ) ជាដើម យកប្រមូលទុកនៅនឹងស-២១ហ្នឹង។ ឯកសារហ្នឹងនៅទាំងអស់។ ហើយដល់ពាក់កណ្តាលខែ ១០ បានបញ្ចូលខ្ញុំឱ្យទៅសួរចម្លើយ។ ដូច្នេះអារឿងចាប់ទាហាន ចាប់រាជការអីៗ គេធ្វើរួចអស់ទៅហើយ។ ខ្ញុំចូលទៅហ្នឹងចាប់សួរចម្លើយ បានទាន់ពួករោងចក្រ ប៉ុន្មាននាក់ហ្នឹង។ រោងចក្រ គេហៅរោងចក្រក-១០ ធ្វើក្រដាស។ ក្រដាសហ្នឹងយកក្រដាសចាស់ទៅធ្វើក្រដាសថ្មី ប៉ុនខ្ញុំង។ ហើយចំណែកទាហាន មន្ត្រីរាជការរបស់ លន់ នល់ ឋានានុក្រមរបស់សង្ឃ ព្រះសង្ឃពុទ្ធសាសនាហ្នឹង គេសម្រិតសម្រាំងរួចអស់ទៅហើយ នៅភ្នំពេញជាពិសេស។ ដូច្នេះរឿងហ្នឹង វារឿងគេទេ ក៏ប៉ុន្តែចាប់រឿងថ្មី។ ដូច្នេះសូមបញ្ជាក់ប៉ុណ្ណឹង។

[១៣:៥៨:៥០]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមឱ្យលោកផ្តោតជាក់លាក់ ដោយសារថាលោកបានផ្តល់កិច្ចសម្ភាសន៍ជាច្រើនដងរួចមកហើយ។ លោកប្រធាន គឺខ្ញុំសុំអាន<>កំណត់ហេតុ<នៃកិច្ចសម្ភាសន៍របស់សាក្សីនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០២ គឺឯកសារ>E3/529, ERN អង់គ្លេស 00329130, ខ្មែរ 00095693, បារាំង 00327360 ដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះ។ នេះជាអ្វីដែលគាត់បានឆ្លើយ សូមដកស្រង់៖ "ក្រោយថ្ងៃរំដោះ ខ្ញុំបានឃើញប្រជាជននៅតាមផ្លូវ និងរថយន្តចតនៅតាមផ្លូវ។ ក្រោយមកខ្ញុំបានឮថា គណៈកម្មាធិការឃុំជាអ្នកសម្រេចជ្រើសរើស និងបែងចែកប្រជាជន ហើយនិងយកពួកគេយកទៅសម្លាប់ចោល។ ពួកគេមានទាំងទាហាន និងមន្ត្រីប៉ូលិសផងដែរ។" បញ្ចប់ការដកស្រង់។ លោកសាក្សី សំណួររបស់ខ្ញុំ ថាតើគណៈឃុំមួយណា ដែលបាននិយាយថានេះ? ហើយតើលោកបានស្តាប់ឮ<ដោយរបៀបណា ដែលថា>គណៈឃុំ<មួយចំនួននោះបែងចែកមនុស្ស ហើយ>យកទាហាន និងមន្ត្រីនគរបាលយកទៅសម្លាប់ចោល? តើលោកដឹងប្រភពព័ត៌មាននេះពីណាមកដែរ?

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា។ ខ្ញុំដំបូងសូមគោរព ក៏បញ្ជាក់ថា សម្ដីនេះជាសម្ដីខ្ញុំឆ្លើយ មែន ពិត។ និយាយអំពីគណៈឃុំនេះ គឺអង្កាល់នោះ ខ្ញុំនៅអមលាំងនៅឡើយទេ។ ទាល់តែថ្ងៃ២០ មិថុនា ទើបខ្ញុំចេញពីអមលាំងមកភ្នំពេញ នៅពេលគេជម្លៀសប្រជាជនទុំង អង្កាល់នោះខ្ញុំសូមនិយាយឲ្យត្រង់ ទៅ ឲ្យច្បាស់ទៅ អ្នកដែលសុំខ្ញុំទៅនេះ គឺបង ម៉ម ណៃ។ ទៅពិនិត្យ ក្រែងលោឃើញបងប្អូនរបស់គាត់ ត្រូវគេជម្លៀសទៅ នឹងអាលសុំយកមករក្សាទុក ចិញ្ចឹមនៅនឹងម-១៣ហ្នឹងតទៅទៀត។ ដូច្នេះហើយ បានជាខ្ញុំដឹង ថាកន្លែងគេជួបជុំគ្នា គេសម្រិតសម្រាំងជ្រើសរើស គឺគណៈឃុំអមលាំង។ នេះគឺសូម បញ្ជាក់ប៉ុណ្ណឹង។

[១៤:០២:០០]

**ស៖** តើធ្វើដូចម្ដេចបានជាលោកដឹងថា មានការសម្រិតសម្រាំងនៅឃុំអមលាំង?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំនិយាយអំមិញ ដូចជាច្បាស់ដែរ គឺបងម៉ម ណៃ ខ្ញុំជឿថាព្រះរាជអាជ្ញានៅចាំហើយ បងម៉ម ណៃ។ បងម៉ម ណៃ ហ្នឹងគាត់មានបងប្អូននៅភ្នំពេញ ដល់ គេជម្លៀសទៅ គាត់ដឹងរឿងជម្លៀស ហើយគាត់សុំខ្ញុំទៅមើលនឹងកន្សែងសំ កន្លែងដែលគេជ្រើសរើស នុំង។ គេកត់ឈ្មោះជ្រើសរើសអ្នកណាខ្លះអីអ្នកណាខ្លះ គាត់ក្រែងឃើញបងប្អូនគាត់ទៅហ្នឹង គាត់សុំ យកមករក្សាទុក ឲ្យរស់ជីវិត។ ហ្នឹងបានខ្ញុំដឹង។ ខ្ញុំអត់អំពល់វរល់អីទេ។

**ស៖** សូមអរគុណលោកសាក្សី ដែលបានបញ្ជាក់ចំណុចនេះ។ កងពល៧០៣ តើលោកដឹងអំពី តួនាទីរបស់កងពល៧០៣ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងការសម្លាប់អតីតមន្ត្រី និងទាហាន លន់ នល់ ដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា តួនាទីរបស់កងពល៧០៣ នៅក្នុងការចាប់ ទាហាន និងមន្ត្រីអី ខ្ញុំអត់បានដឹងជាផ្លូវការពី ណាត មកទេ។ ដែលខ្ញុំដឹងពីក្មេងៗទៅវិញ ពីរឿងជម្លៀស ប្រជាជន។ នៅពេលធ្វើជីវទស្សន៍ មានក្មេងម្នាក់ថ្នាក់អនុសេនាធំ ឈ្មោះ ម៉ាន មិនដឹងជាស្អី ម៉ាន ទេ ភ្លេចបាត់ទៅហើយ។ វានិយាយថា ពេលជម្លៀសហ្នឹងដេញចេញមិនដេញ បាញ់។ ប៉ុន្តែបាញ់ហ្នឹងបញ្ឆិត ៗលើក្បាលទេ អត់ឲ្យត្រូវ ដើម្បីឲ្យប្រជាជនចេញ។ ហើយម្នាក់ទៀត – សឹម ម៉ាន ក្មេងដែលខ្ញុំនិយាយ ហ្នឹង សឹម ម៉ាន (ចាម) – ហើយមានម្នាក់ទៀតឈ្មោះ យូ ប៉េងគ្រី មកនិយាយហូរហែប្រាប់ខ្ញុំខ្លះពីរឿង សម្ដេចសង្ឃ ហួត តាត មានស្រីច្រើន។ ខ្ញុំថា ឱ! សម្ដេច ហួត តាត គឺនៅក្នុងកណ្ដាប់ដៃកងពល៧០៣ ហើយ។ នេះជាការសន្និដ្ឋានរបស់ខ្ញុំ ដោយឮសម្ដី យូ ប៉េងគ្រី និយាយអ៊ីចេះ។

[១៤:០៥:០៥]

ដូច្នេះ ហើយក្រោយមកទៀត ក្មេងៗនៅ៧០៣ និយាយជាទូទៅពីរឿងខាងទាហាន លន់ នល់ មានកសាងកងកុម្ម៉ង់ដូពិសេសមួយ ដឹកនាំដោយ ហែម កេតដារ៉ា បោះគ្រាប់បែកពីលើផ្ទះទៅលើពួកកងទ័ព។ ដូច្នេះកងទ័ពដេញចាប់ ៗបានទាំង ហែម កេតដារ៉ា រឹបអូសបានទាំងអាវុធបីឡាន អា.កាត់កាត់បានន័យថា បីឡានអាកង់បួន។ ដូច្នេះវាឮ មិនមែនជាផ្លូវការទេ ពីក្មេងៗវាប្រាប់ខ្ញុំ ក្នុងឋានៈខ្ញុំជារងរបស់ ស-២១។

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកអំពីចម្លើយមួយចំនួនដែលលោកបានផ្តល់ គឺកំណត់ហេតុស្តាប់ចម្លើយ<របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត> ឯកសារE3/429 ដែលមានលេខERN ភាសាខ្មែរ00403909, ភាសាអង់គ្លេសមានលេខ <403920> *(ស៊ីក)* ដល់ 21, បារាំងមានលេខ 0040 3932 ដល់33។ នេះគឺជាអ្វីដែលលោកបានឆ្លើយ ហើយខ្ញុំសូមធ្វើការដកស្រង់ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសួរលោកទាក់ទងទៅនឹងចម្លើយទាំងអស់នេះ។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំដឹងថា ក្រោយថ្ងៃ១៧ មេសា ទាហានត្រូវបានគេកម្ទេចជាប្រព័ន្ធ។ ចំណុចនេះត្រូវបានប្រាប់មកខ្ញុំដោយ <ខឹម> <ពីន> ដែលជាលេខាកងពលធំ៧០៣ ហើយនិងដោយ ហ៊ី ដែលជាអនុរបស់ខ្ញុំ។ បន្ទាប់ពីពេលរំដោះ ទាហានត្រូវបានគេស្វែងរក ហើយអ្នកខ្លះបានរត់គេច។ ប៉ុល ពត, វន វេត និង សុន សេន ត្រូវបានជូនដំណឹងអំពីបញ្ហានេះ ហើយពួកគាត់បានឱ្យ <ខឹម ពីន> តាមដានសភាពការណ៍។ គាត់ប្រាប់ខ្ញុំថា ឧទាហរណ៍ដូចជា ឧត្តមសេនីយ៍ ជា គឹមអេង និងឧត្តមសេនីយ៍ ឈឹម ឈួន បានរាយការណ៍ប្រាប់គាត់អំពីការចុះចូល ហើយនិងត្រូវបានកម្ទេចបន្ទាប់មក។ គាត់ប្រាប់ខ្ញុំអំពីឧត្តមសេនីយ៍ ដេង ឡាយ៉ុម ផងដែរ"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះលោកសាក្សីអ្វីដែលខ្ញុំចង់អានឱ្យលោកស្តាប់នេះ គឺជួយរំឭកដល់ការចងចាំរបស់លោក ប៉ុន្តែខ្ញុំចង់ដឹងថា តើ <ពីន> ដែលក្លាយជាមេបញ្ជាការកងពល៧០៣ ហ្នឹង តើ <ពីន> ហ្នឹងគាត់ប្រាប់អ្វីដល់លោកខ្លះ អំពីហេតុការណ៍ដែលកើតឡើងចំពោះទាហាន លន់ នល់ នោះ?

[១៤:០៨:២៧]

**ធ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ដំបូងខ្ញុំសូមបញ្ជាក់ ខឹម ពីន មិនមែន ខឹម ពិន ទេ ខឹម ពីន។ ខឹម ពីន នេះហើយនិងប្រពន្ធខ្ញុំនៅស្រុកឃុំជាមួយគ្នា ហើយដោយគាត់ជាអនុលេខាប្រាំពីរ -- ដើមឡើយគាត់ជាអនុលេខា៧០៣ អត់កងពលធំទេ កងពលតូច។ ដូច្នេះគាត់និយាយនេះក្នុងមនោសញ្ចេតនា ជាអ្នកបដិវត្តន៍ដូចគ្នា ជាសមាជិកបក្សដូចគ្នា ហើយក៏មានជំនឿជឿទុកចិត្តរាប់អានគ្នាក្នុង

ឋានៈគាត់ ហើយនិងប្រពន្ធខ្ញុំនៅស្រុកភូមិជាមួយគ្នា។ គាត់ប្រាជ្ញអំពីក្រោយថ្ងៃ១៧នេះ ទាហានវាជ្រួលច្របល់ៗ។ ដល់ទៅ ដឹងដល់ ប៉ុល ពតៗ ប្រើ ខឹម ពីន ឲ្យទៅរៀបចំសភាពការណ៍ហ្នឹងឲ្យស្រួលបួលហ្នឹងឡើងវិញ។ បងពីន ទៅដល់ មើល៍! នរណាឲ្យទាហាន -- មើល៍! នរណាឲ្យយុទ្ធជនចាប់ទាហាន? មើលពួកយុទ្ធជនណា? ពួកណាខ្លះចាប់ទាហាន? ដល់គាត់ឡូឡាអ៊ីចឹង យុទ្ធជនរត់ប្រាយអស់ទៅ បានគេមក គោះជើងឧត្តមសេនីយ៍ ជា គឹមអេង មកដល់គោះជើង គោរព! ខ្ញុំឧត្តមសេនីយ៍ ជា គឹមអេង តិចទៀត ឈឹម ឈួន មកគោរពខ្ញុំ។ ឧត្តមសេនីយ៍ ឈឹម ឈួន ហើយ បងពីន គាត់ធ្វើដៃ អ៎!ៗ អញ្ជើញៗ។ ដល់ទៅយក ជា គឹមអេង ហើយនិង ឈឹម ឈួន ទៅបាត់ ជាសម្ងាត់ទៅ។ ដូច្នេះសភាពការណ៍ដែលទាហានជ្រួលជ្រើមដោយសារពួកយុទ្ធជនចាប់ទាហានចំហៗនោះ ក៏បានអស់ទៅ។ ឯចំណែករឿង ដេង ឡាយ៉ុម ដូចជាខ្ញុំមិនចាំច្បាស់។ អាចថ្ងៃនុ៎ង ដេង ឡាយ៉ុម ទៅគោរពគាត់ដែរដឹង ខុសក៏មិនដឹងដែរ ខ្ញុំវង្វេងហើយត្រង់ណេះ។ ដូច្នេះ សូមបញ្ជាក់បញ្ហាហ្នឹង។

[១៤:១១:០២]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយជូនដល់សាក្សី គឺឯកសារ E3/832។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ឯកសារនេះជូនដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលលោកទើបតែបានទទួលនេះ គឺជាឯកសារចុះថ្ងៃទី០៤ មិថុនា ឆ្នាំ១៩៧៥ គឺជាឯកសាររបស់សមមិត្ត ពីន នៅភូមិភាគពិសេស បានកំណត់អត្តសញ្ញាណរបស់ទាហានលន់ នល់ ចំនួន១៧នាក់ ដែលបក្សសម្រេចកម្ទេច។ ដូច្នេះខ្ញុំចង់សួរថាតើ ពីន មួយហ្នឹងគឺជា ពីន ដែលលោកទើបតែនិយាយហ្នឹងឬ? <តើមានកងពលធំមួយណាដែល ណាត និង ពីន ចេញមកនោះ នៅតែជាផ្នែករបស់>ភូមិភាគពិសេសនៅក្នុងខែមិថុនា ឆ្នាំ៧៥ ទេ?<>

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំមិនទាន់នឹកឃើញថា ពីន ណាភូមិភាគពិសេស ខ្ញុំស្គាល់ ពីន ម្នាក់មែន ខឹម ពីន។ ដើមឡើយជាអនុលេខា៧០៣ ដល់ក្រោយដែលបង្កើតស-២១ បក្សដក

ណាត មកឲ្យដំឡើង បងពីន ឲ្យឡើងធ្វើជាលេខា ហ្នឹងខ្ញុំស្គាល់មួយហ្នឹង។ ឯចំណែក ពីន ភូមិភាគពិសេស ខ្ញុំអត់ដឹង អត់ដែលឃើញ។ ដូច្នេះខ្ញុំជឿថាឯកសារនេះ អាចជាឯកសារនិយាយសំដៅយោងទៅបងពីន ៧០៣ ហ្នឹងឯង។

[១៤:១៣:៣៤]

**ស៖** ខ្ញុំចង់សួរលោកបញ្ជាក់បន្តិច ថាតើកងពលដែលក្រោយមកក្លាយជា៧០៣ហ្នឹង តើកងពលហ្នឹងធ្លាប់ស្ថិតនៅក្រោមភូមិភាគពិសេសដែរឬទេ?

**ឆ៖** អរគុណ។ សំណួរនេះច្បាស់ហើយ ស្រួលឆ្លើយ។ ភូមិភាគពិសេសហ្នឹង វាមានពីរកំណាត់។ តាមពិតភូមិភាគពិសេសហ្នឹង វារួមទាំងភ្នំពេញ មុន១៧មេសា វារួមទាំងភ្នំពេញ ភូមិភាគពិសេសខាងជើង និងភូមិភាគពិសេសខាងត្បូង។ ភូមិភាគពិសេសខាងត្បូងនេះ មានស្រុកបួន គឺស្អាង, កោះធំ, លើកដែក និងកៀនស្វាយ។ កងពល១២ ដែលមាន ណាត ជាលេខា ហើយ ពីន អនុលេខានេះស្ថិតនៅភូមិភាគពិសេសខាងត្បូង។ ដូច្នេះ ពីន ៧០៣ នេះគឺក្រោយមកបានវាមានឈ្មោះ ៧០៣។

**ស៖** ដូច្នេះសូមលោកពិនិត្យមើលទៅលើឈ្មោះទាំង១៧ ដែលមាននៅក្នុងឯកសារនេះ។ គឺឯកសារនិយាយថា មនុស្ស១៧នាក់ ត្រូវបក្សពិនិត្យមើល ហើយបក្សសម្រេចថាកម្ទេចចោល។ ដូច្នេះខ្ញុំចង់សួរ ថាតើលោកមានស្គាល់មនុស្សណាម្នាក់ ក្នុងចំណោមទាំង១៧ នៅក្នុងបញ្ជីនេះទេ?

**ឆ៖** ទាំង១៧នាក់នេះ បើតាមខ្ញុំមើលមួយត្រួស ហើយក៏ប្រហែលជាមិនឈានទៅណាដែរ ខ្ញុំអត់មានស្គាល់អ្នកណាទេ។

**ស៖** សូមអរគុណលោកសាក្សី។ លោកបានបញ្ជាក់ថា ក្រោយខែមិថុនា ឆ្នាំ៧៥ លោកបានមកដល់ភ្នំពេញ ហើយលោកមានភារកិច្ចមួយ គឺស្វែងរកឯកសាររបស់ លន់ នល់។ ហើយលោកចាំទេលោកបានទទួលការចាត់តាំងឲ្យប្រមូល ឬក៏ឲ្យស៊ើបអង្កេតអំពីប្រវត្តិរបស់ទាហាន ឬក៏មន្ត្រីលន់ នល់ ដែលបោះទីតាំងនៅក្នុង<ស្រុកបារាយណ៍> ខេត្តកំពង់ធំដែរឬទេ? តើលោកចាំថា លោកមានភារកិច្ចបែបនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំដើរប្រមូលនេះ ប្រមូលឯកសារ គឺរបស់ងាប់។ យកពីសេនាធិការខ្លាំង យកពីសង្កាត់ មើល៉ ចាត់ការទូទៅនៃកងយោធពលខេមរជាតិ ដែលគេហៅថាហ្គុយ.ហ្សេ.អា.អា ហ្នឹង។ ពីផ្ទះ វ៉ាន់ ស ពីផ្ទះ លន់ នល់, លន់ នល់ ខ្ញុំទៅរើផ្ទះហ្នឹង ខ្លួនឯង។ រកបានឯកសារមួយចំនួនដែរ។ ដូច្នេះទៅប្រមូលរបស់ងាប់ទេ អត់មានប្រមូលនេះទេ។ ឯចំណែកបេសកកម្មខ្ញុំ

អត់មានចេញក្រៅក្រុងទេ។ អត់មានចេញក្រៅក្រុងភ្នំពេញទេ។

[១៤:១៧:៥២]

**ស៖** តើព័ត៌មានអ្វីដែលលោកបានប្រមូល ឬក៏ឯកសារអ្វីដែលលោកបានប្រមូល? <តើគេយកឯកសារនោះទៅប្រើប្រាស់ដើម្បីធ្វើអ្វី?> ហើយពេលលោកប្រមូលបាន តើលោកប្រគល់ឯកសារ ឬក៏ផ្តល់ព័ត៌មានហ្នឹងទៅដល់អ្នកណាដែរ?

**ឆ៖** ឯកសារដែលខ្ញុំប្រមូលបាន ខ្ញុំរក្សាទុកនៅស-២១ ដើម្បីជាប្រភពព័ត៌មានដែលខ្ញុំស្រាវ-ជ្រាវតទៅទៀត។ ឯចំណែកការងារសំខាន់ខ្លះ ឯកសារសំខាន់ខ្លះ ខ្ញុំផ្តល់ជូនទៅមេ។ ទៅប្រមូលពីផ្ទះលន់ នល់ របស់ដែលខ្ញុំយល់ថា សំខាន់នោះ ផែនទី ដែលអាមេរិកាំងគូរ ប្រហែលជាអាមេរិកាំងគូរ អំពីបន្ទាយទាហាននៅភាគខាងត្បូងវៀតណាម ទាហានអាធីវ គឺ នោះ។ ហ្នឹងខ្ញុំចាំមួយ របស់ហ្នឹងមួយ ហើយខ្ញុំផ្តល់ទៅមេ មិនដឹងស្អីខ្លះទៀតទេ ប៉ុន្តែសំខាន់ដែលខ្ញុំនៅចាំ អាហ្នឹង។ ឯចំណែកពីផ្ទះលន់ នល់ នោះ ខ្ញុំយកមកទុកសម្រាប់ការចេះដឹងខ្លួនឯង គឺប្រមូលដែល លន់ នល់ គាត់សរសេរ។ ពាក្យថា “ដំណើរខ្មែរថ្មី” ហើយដែលបារាំងគេថា “ឡឺ ណោអូ ខ្មែរវីស៍” លន់ នល់ គាត់សរសេរមួយចំហៀងខ្មែរមួយចំហៀងបារាំង។ ខ្ញុំយកទៅទុកសម្រាប់ជាឯកសារខ្លួនឯង។ ហើយនិងទៅប្រមូលពីទីស្នាក់ការគណបក្សរបស់ លន់ នល់ ដូចគណបក្សសាធារណរដ្ឋអ៊ីចេះមិនដឹង។ យកទុកឯកសារហ្នឹង យកទៅទុកទៀត។ ដូច្នេះសម្រាប់ការជាយល់ដឹងផ្ទាល់។ ឯចំណែកទៅប្រមូលនៅប៉េហ្ស៊ី អ្នកគេហៅថា ប៉េហ្ស៊ី ប្រជាជនសាមញ្ញ គេហៅ ប៉េហ្ស៊ី។ ប៉ូលិស នៃស្អី ហើយបើភាសាបច្ចេកទេសគេកាលហ្នឹង គេហៅថា អគ្គនាយកដ្ឋានប៉ូលិសជាតិ។ អាហ្នឹងខ្ញុំបានអាល់ប៊ុមពីរ អំពីនាយប៉ូលិស ហើយនិងនាយប៉ូលិសរងហើយយកទៅទុកនៅនុ៎ង។

**ស៖** ខ្ញុំសូមបង្ហាញលោកនូវឯកសារមួយទៀត ហើយក៏ខ្ញុំសុំអនុញ្ញាតពីលោកប្រធានផងដែរដើម្បីផ្តល់ឯកសារ E3/1052។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ផ្តល់ឯកសារនេះទៅដល់សាក្សី។

[១៤:២០:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌែល លីសាក់៖**

**ស៖** សូមលោកពិនិត្យមើលទៅលើឯកសារនេះ ហើយប្រាប់ខ្ញុំមកវិញ ថាតើលោកស្គាល់ឯក-

សារនេះដែរទេ? ថាតើវាជារបាយការណ៍ដែលលោករៀបចំនៅក្នុងឆ្នាំ១៩៧៥ ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះ ជាឯកសារដែល ណាត ឲ្យខ្ញុំដកស្រង់ "០៣" នេះគឺ ណាត។ ឲ្យខ្ញុំដកស្រង់អំពីឯកសារដែលខ្ញុំប្រមូលបាន ដើម្បីតាមចាប់មនុស្សប៉ុន្មាននាក់ គាម ទត, ង៉ូវ វ៉ា ជាដើម។ ឯកសារនេះមានបីផ្ទាំង បីសន្លឹក ប៉ុន្តែសហចៅក្រមស៊ើបអង្កេត គោលបំណងខ្ញុំគឺចង់បញ្ជាក់ថា ស-២១ គ្មានសិទ្ធិ ខ្ញុំ និយាយឲ្យត្រង់ទៅ ខ្ញុំគ្មានសិទ្ធិទារចាប់មនុស្សទេ។ ឯកសារនេះ លោកឲ្យមកខ្ញុំតែមួយទេ ទាំងអស់មានបី ដូចជាបី។ រួចបានខ្ញុំសរសេរទៅ ណាត "ចាប់ឬមិនចាប់ស្រេចបងវិភាគចុះ"។ ដូច្នេះ ចង់បញ្ជាក់ជូនចៅក្រមស៊ើបអង្កេត ថាខ្ញុំអត់មានសិទ្ធិចាប់ទេ តែ ណាត គាត់ធ្លាប់ចាប់។ សូមបញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** ខ្ញុំគិតថា<វាច្បាស់ហើយអ៊ីចឹង។> ប្រសិនបើលោកមើលនៅជួរចុងក្រោយបំផុត គឺថា "ចាប់ឬមិនចាប់អាស្រ័យលើបងអ្នកវិភាគ <និងសម្រេច>"។ ដូច្នេះខ្ញុំចង់សួរថា ហេតុអ្វីបានជាក្នុងហ្នឹង គេសរសេរ គេហៅ ណាត ថា "បង០៣"?

[១៤:២២:៥៦]

**ឆ៖** ទម្លាប់យុទ្ធជនខ្មែរកាលជំនាន់នោះ គេហៅ មេធំបំផុតនោះ យកឈ្មោះលេខកងទៅដាក់។ ដូចខ្ញុំហ្នឹង អ្នកខ្លះគេហៅ ស-២១។ មេខ្ញុំ សុន សេន ហៅខ្ញុំ "ស-២១" ឯង។ មិត្តប៉ង់ ក៏អ៊ីចឹង ហៅៗខ្ញុំ "ស-២១" ឯង។ ឯចំណែកយុទ្ធជននៅក្នុងស-២១ ហៅខ្ញុំ "បងឯកើត" ហៅមិត្តហ៊ី "បងឯលិច" គេហៅអ៊ីចឹង។ ឯចំណែក ណាត នេះទម្លាប់ទាំងអស់ហ្នឹង ហៅ "បង០៣" ពីព្រោះកងពល៧០៣ លុបអា៧ ខាងដើមចេញទៅ នៅសល់០៣។ គាត់នេះ ០៣។

**ស៖** ដូច្នេះនៅពេលដែល បងណាត គាត់ឈប់ធ្វើជាលេខាកងពល៧០៣ អ៊ីចឹងគេឈប់ហៅគាត់ថា "បង០៣" ហើយមែនទេ?

**ឆ៖** "០៣" នេះគេហៅ បើតាមខ្ញុំដឹង តាំងពីបក្សដកគាត់ចេញពីស-២១ អត់មានកូនចៅកាន់នឹងដៃទេ។ ដូច្នេះខ្ញុំមិនដឹងថាមានអ្នកណាហៅគាត់ "០៣" ទៀត ឬមិនហៅមិនដឹងទេ ក៏ប៉ុន្តែបក្សដកចេញ ផុតពីស-២១ទៅ គាត់ទៅនៅសេនាធិការ។ ក្រោយមកដកពីសេនាធិការ ទៅខាងក្រសួងការបរទេស។

**ស៖** របាយការណ៍ដែលលោកសរសេរផ្ញើរជូន បងណាត គឺនិយាយអំពីមនុស្សពីរនាក់ ដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានក្លែងប្រវត្តិរូប ដោយក្លែងថា ពួកគេជាកម្មករ។ ដូច្នេះខ្ញុំចង់សួរថា តើមនុស្សទាំងពីរនាក់ហ្នឹង គាត់មានតួនាទីអ្វីដែរ នៅក្នុងរបបមុននោះ?

[១៤:២៥:២០]

**ឆ៖** នៅក្នុងរបបមុន គឺឆ្នាំ៧០ គាម ទត នេះជាសាស្ត្រចារ្យភាសាខ្មែរ។ នៅពេលដែលគាត់រៀននៅវិទ្យាស្ថានជាតិគរុកោសល្យ គាត់យកជើងពួក លន់ នល់ សម្បើមណាស់។ គ្នាតិចបំផុតដែលគាត់ប្រមូលបានហ្នឹង ស៊ីញេញត្តិមួយសុំឲ្យព្រះនរោត្តម សីហនុ ចាប់ ខៀវ សំផន។ ក៏ប៉ុន្តែ គាម ទត នេះធ្លាប់ធ្វើជានាយកវិទ្យាល័យកំពង់ធំ។ សូមបញ្ជាក់ថា រយៈកាលនុ៎ង ណាត គាត់នៅធ្វើប្រធានរោងចក្រអគ្គិសនីកំពង់ធំ រោងចក្រអគ្គិសនីកម្ពុជាហ្នឹង។ ដូច្នេះរឿងរ៉ាវប្រវត្តិ គាម ទត, ណាត ដឹង។ ឯចំណែក អាប៉ុនឌីន នេះជាមួយដំណាលខ្ញុំ តែជាប់បាក់ឌុបក្រោយខ្ញុំទេ។ ដល់ក្រោយមក វាចេញទៅធ្វើគ្រូ វាអែបអបគេ វាបានឡើងទៅជានាយកវិទ្យាល័យកំពង់ឆ្នាំង។ ហើយដល់ក្រោយមកទៀត ក្រោយរដ្ឋប្រហារ លន់ នល់ វាទៅជាគណៈកម្មាធិការសន្តិសម្ព័ន្ធ។ ហ្នឹងដែលខ្ញុំរើបានឯកសារហ្នឹង វាឃើញអាហ្នឹង។ ឯចំណែក ណាត ក្រោយឆ្នាំ១៩៧៧នេះ អ៎សុំទោស! ក្រោយ១៧ មេសា ១៩៧៥ នេះគាត់ខ្វាត់ខ្វែង រកគូដណ្តឹងចាស់របស់គាត់។ ដល់ក្រោយគាត់ប្រាប់ខ្ញុំថា គាត់ឃើញនៅបារាយណ៍ ឈ្មោះនាង ងួន គឹមហៀង។ ដោយការខ្វាត់ខ្វែងហ្នឹងហើយ បានទៅជួប បងទត ហើយនិង អាឌីន នេះនៅភូមិផ្តៅជុំ ហើយក្លែងប្រវត្តិរូបថាកម្មករនុ៎ង។

**ស៖** ឥឡូវនេះខ្ញុំសូមអានឲ្យលោកស្តាប់នូវសេចក្តីកម្មមួយចំនួន ដែលលោកផ្តល់នៅឆ្នាំ២០១២ និយាយអំពីមនុស្សទាំងអស់នេះ គឺនៅ គឺថ្ងៃទី២៦ មីនា ២០១២ គឺឯកសារ E1/53.1 គឺជាសេក្តីកម្មនៅម៉ោង<១៤:១៩ ដល់><១៤:២០> នៅពេលរសៀល។ លោកបាននិយាយបង្ហាញអំពីអត្តសញ្ញាណរបស់បុគ្គលទាំងពីរនេះ ហើយលោកបាននិយាយដូចទៅនេះ គឺបានន័យថា បន្ទាប់ពីលោកបង្ហាញរួចហើយ។ "ហេតុដូច្នេះហើយ បានជា ណាត ចង់ចាប់ខ្លួនមនុស្សទាំងអស់នេះ យោងទៅតាមគោលនយោបាយរបស់បក្ស។" ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកគឺថា តើគោលនយោបាយបក្សហ្នឹងគឺជាអ្វី? ថាតើគោលនយោបាយបក្សហ្នឹងយ៉ាងម៉េចដែរ ដែលតម្រូវឲ្យចាប់បុគ្គលទាំងអស់នេះ?

[១៤:២៩:០១]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា គោលនយោបាយរបស់បក្សនេះ ខ្ញុំនិយាយព្រឹកមិញមួយម៉ាត់រួចមកហើយ។ ឥឡូវខ្ញុំសូមនិយាយពាក្យនេះឡើងវិញ គោលនយោបាយនេះចេញនៅឆ្នាំ

១៩៧១ ក្នុងមហាសន្និបាតលើកទី៣របស់បក្ស ឲ្យតែខ្មាំងត្រូវតែកម្ទេច។ ឯចំណែកគោលនយោបាយមួយទៀត នៅឆ្នាំ១៩៧៣ដែរ ហើយខ្ញុំបាននិយាយច្រើនដែរ តែឥឡូវនេះខ្ញុំសូមនិយាយម្តងទៀត។ ឆ្នាំ ១៩៧៣ ឯកសារទង់បដិវត្តសរសេរថា “វណ្ណៈពិសេស”។ វណ្ណៈពិសេសហ្នឹងមានពីរនៅស្រុកខ្មែរ ទី១គឺ ភិក្ខុសង្ឃពុទ្ធសាសនា ជាអ្នកដើរបំពុលប្រជាជនអំពីទ្រឹស្តីកម្មផល។ ក៏ប៉ុន្តែពុទ្ធសាសនាខ្មែរល្អ មិនដូច ពុទ្ធសាសនានៅកន្លែងផ្សេងទៀតទេ។ ពាក្យកន្លែងផ្សេងហ្នឹង គឺគាត់ចង់សំដៅនៅទីបេ។ ព្រះសង្ឃខ្មែរ ជាកូនកសិករ ដោយកសិករខ្មែរល្អ ព្រះសង្ឃខ្មែរក៏ល្អទៅដែរ។ នេះនិយាយពីវណ្ណៈពិសេសត្រឹមប៉ុណ្ណឹង។ ដោយឡែក គាត់និយាយវណ្ណៈពិសេសទី២ គឺទាហាន និងប៉ូលិស។ ពួកនេះ វាកាន់កាំភ្លើងខ្មាំងដើរទៅ សម្លាប់ប្រជាជន។ នេះជាការញែកខាងទស្សនៈ ក៏ប៉ុន្តែដល់អនុវត្តជាក់ស្តែង គេមកអនុវត្តក្រោយ១៧ មេសា ដែលគេមានកម្លាំងទូទាំងប្រទេសហើយ។

**ស៖** ជាពិសេសពាក់ព័ន្ធទៅនឹងមនុស្សទាំងពីរនាក់នៅក្នុងរបាយការណ៍របស់លោកគឺ គាម ទត និង ង៉ូវ វ៉ា ហ្នឹង ចង់សួរថាហេតុអ្វីបានជាពួកគាត់ពីរនាក់ហ្នឹង ត្រូវបានចាត់ទុកថាជាខ្មាំង?

[១៤:៣១:៥៩]

**ឆ៖** ង៉ូវ វ៉ា ខ្ញុំមិនស្គាល់ទេ។ ង៉ូវ វ៉ា ខ្ញុំមិនស្គាល់ទេ។ ខ្ញុំនិយាយអំមិញ គាម ទត និង តាប់ ប៊ុន ឌីន។ ង៉ូវ វ៉ា ខ្ញុំមិនស្គាល់ទេ ក៏ប៉ុន្តែ ណាត និយាយថាបងប្អូនក្រុម -- ក្រុង ខាងក្រុង។ នេះៗបងប្អូនខាង ក្រុង ឲ្យព័ត៌មានថាធ្លាប់ចេញចូលផ្ទះ លន់ នល់, បូរ៉េត, ប៉ាន់ សុធី ញឹកញាប់ណាស់។ ខាងក្រុង មិន មែនក្រុមទេ គឺកម្លាំងបង្កប់របស់មិត្តសុខ ស៊ិន តារា ហៅសុខ លេខាក្រុងភ្នំពេញ។ នេះគេចាត់ទុកជា ខ្មាំង។

**ស៖** សូមអរគុណលោកសាក្សី។ ក្នុងឆ្នាំ៧៥ នៅពេលដែលគេស្វែងរកមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ នោះ តើអ្នកដែលព្យាយាមលាក់មន្ត្រីរដ្ឋការ ឬក៏ទាហាន លន់ នល់ ហ្នឹង តើមានអីកើតឡើង ចំពោះពួកគាត់ដែរ?

**ឆ៖** សូមអរគុណ។ ខ្ញុំអត់មានដំណឹងអីច្បាស់លាស់ទេ។ អ្នកដែលលាក់ពួកមន្ត្រីរាជការហ្នឹង អត់ដឹងទេ។ គ្រាន់តែដឹងថា ជម្លៀសទៅ គេបែងចែក ហើយយកអ្នកណាដែលស្រប គេសម្រិតសម្រាំង យកទៅផ្ញើនឹងផ្ទះកសិករខ្មែរ នៅជនបទ។ ហើយអ្នកដែលគេបែងចែកហើយ ទុកឲ្យរស់ហ្នឹង គេហៅ ប្រជាជន១៧មេសា។

[១៤:៣៤:១៩]

**ស៖** ឥឡូវនេះខ្ញុំចង់អាននូវសម្រង់មួយចំនួនទៀត<ដែលលោកបានឆ្លើយ> គឺជាឯកសារ E3/429 គឺជាកំណត់ហេតុស្តាប់ចម្លើយ ក.ស.ច.ស គឺឯកសារE3/429 ខ្មែរមានលេខ00403909, អង់គ្លេសមានលេខ 00403921 និងបារាំងមានគឺលេខ 00403933។ ខ្ញុំសូមដកស្រង់ នេះជាចម្លើយរបស់លោក៖ "ប្រសិនបើគេរកឃើញថា អ្នកណាម្នាក់ក្នុងអាជ្ញាធរព្យាយាមលាក់ទាហាន លន់ នល់ ប្រាកដណាស់ថាគាត់ត្រូវបានគេដាក់ទណ្ឌកម្ម ឧទាហរណ៍ដូចជាចាប់ខ្លួន និងសម្លាប់។ ប៉ុន្តែខ្ញុំមិនដែលឃើញឯកសារនិយាយអំពីបញ្ហានេះទេ។ ប៉ុន្តែខ្ញុំចាំថា ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧៦ សុន សេន បានទូរស័ព្ទមកខ្ញុំ ហើយប្រាប់ខ្ញុំថា គាត់បានស្តាប់ឮថា សមមិត្តអឿន ជាលេខាកងពលធំ៣១០ បានលាក់បំពួនឧត្តមសេនីយ៍ នូ <ថូ> ខ្ញុំឆ្លើយថា មិនពិតទេ ព្រោះខ្ញុំដឹងថា ឧត្តមសេនីយ៍រូបនេះត្រូវបានគេសម្លាប់នៅក្នុងខេត្តកោះកុង គឺសម្លាប់ដោយ បង<សឿង> ដែលជាបញ្ជាការភូមិភាគបស្ចិម"។ ដូច្នេះខ្ញុំសូមទោសបើសិនបើខ្ញុំអានឈ្មោះឧត្តមសេនីយ៍ហ្នឹងខុស។ ដូច្នេះ តើលោកចាំទេថា លោកបាននិយាយជាមួយ សុន សេន? ហើយខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកដឹងថា ឧត្តមសេនីយ៍រូបនេះត្រូវបានគេសម្លាប់នៅក្នុងខេត្តកោះកុង?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ឧត្តមសេនីយ៍រូបនេះពិតជាលោកអានខុសហើយ នូ ថូៗ។ ហើយមេបញ្ជាការទ័ពនោះដែលចាប់ នូ ថូ សម្លាប់នោះឈ្មោះ សឿង – បងសឿង។ ហើយដំណឹងនេះខ្ញុំបានពីប្រពន្ធខ្ញុំ។ សូមបញ្ជាក់ថា ប្រពន្ធខ្ញុំនេះជាប្រធានមន្ទីរកាត់ដេរនៅភូមិភាគបស្ចិម ពីដើមជាប្រធានមន្ទីរកាត់ដេរភូមិភាគនិរតី ប៉ុន្តែដល់បែងចែកភូមិភាគជាពីរទៅ គាត់ទៅភូមិបស្ចិម។ ហើយ បងសឿង ហ្នឹងមេទ័ព មានការរាប់អានជិតស្និទ្ធជាមួយប្រពន្ធខ្ញុំ។ ដូច្នេះរឿងគាត់ចាប់ឧត្តមសេនីយ៍ នូ ថូ បានហ្នឹងវាបែកការណ៍មកដល់ប្រពន្ធខ្ញុំ ហើយប្រពន្ធខ្ញុំយករឿងហ្នឹងមកនិយាយប្រាប់ខ្ញុំ។ ហើយដល់ បងខៀវ បងសុន សេន គាត់សួរខ្ញុំថាឮថា អាអឿន វាលាក់ នូ ថូ? ខ្ញុំថាអត់ទេបង នូ ថូ បងសឿង កម្ទេចហើយ។ នេះខ្ញុំនិយាយតាមភាសាពិត ដែលវាពិត ខ្ញុំចងចាំបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសហការជាមួយនឹងអនុរក្សមន្ទីរឃុំឃាំង នាំសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងនិយាយអំពីអតីតមន្ត្រីរដ្ឋការ និងទាហានលន់ នល់។ លោកនៅចាំឈ្មោះមនុស្សម្នាក់ដែលជាភូឈ្លយខេត្ត អាចថាជាចៅហ្វាយក្រុងរងភ្នំពេញ ឬក៏ខណ្ឌដូនពេញ។ អាចខ្ញុំអានឈ្មោះគាត់ខុស គឺគាត់ឈ្មោះ សោ ផុន តើលោកដឹងទេ? បាទ សូ ផុន លោកដឹងអំពីស្ថានភាពរបស់គាត់ទេ ក្រោយថ្ងៃ១៧ មេសា ៧៥?

[១៥:០០:៤២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំចាំរឿងនេះ។ មនុស្សនេះឈ្មោះ ស ភន រង អភិបាលខណ្ឌដូនពេញនារបប លន់ នល់។ ចម្លើយដែលទាក់ទងនឹងឈ្មោះ ស ភន ឆ្លើយដោយឈ្មោះម្នាក់ដែលរត់ពីភ្នំពេញទៅអមលាំង ទៅរកម៉ែឪវានៅឯណោះ។ វាឈ្មោះ ម៉ារ៉ាឌី មិនដឹងស្អី ម៉ារ៉ាឌី ទេ។ ខ្ញុំយកឯកសារសេចក្តីរាយការណ៍របស់ ម៉ារ៉ាឌី នេះយកទៅជូនមេខ្ញុំ សុន សេន។ ឯកសារហ្នឹង វាធ្លាក់ទៅដល់ សុន សេន, ប៉ុល ពត។ ដល់វ៉ៃឈ្នះភ្នំពេញ សុន សេន កាលនោះក៏ប្រើ ណាត ដែលជាដៃស្តាំរបស់គាត់ ខាងនេះនុ៎ង ទៅចាប់បានឈ្មោះ ស ភន ហ្នឹង យកមកសួរចម្លើយ។ គេសួរ ស ភន ហ្នឹងនៅនឹងភូមិគ្រឹះរបស់ស្តេចក្រុមព្រះ ស៊ីសុវត្ថិ មុនីរ៉េត អាហ្នឹងកន្លែងឃុំឃាំងពិសេស បុគ្គលពិសេសរបស់គេ

នៅនុំងឯង។ ខ្ញុំទៅអើតឃើញ ស ភន មួយភ្លែត ណាត នាំទៅ ឲ្យស្គាល់គុកពិសេសរបស់គេ។ អង្កាល់នោះខ្ញុំត្រូវបានតែងតាំងអនុប្រធានស-២១ហើយ។ តែមួយភ្លែតហ្នឹង ក៏ចប់ទៅ។ ហើយធម្មតាទេ មន្ទីរនគរបាល តែគេចាប់ហើយ គេមិនដែលដោះលែងទៅវិញទេ។

**ស៖** តើលោកបានឃើញ ស ភន នៅក្នុងបន្ទប់ឃុំឃាំងនៃគុកពិសេស<នៅភូមិគ្រឹះមុនីរ៉េត> នេះទេ?

**ឆ៖** ខ្ញុំឃើញ។ ណាត នាំខ្ញុំទៅបង្ហាញ តែអត់មានសួរទេ មិនមែនភារកិច្ចខ្ញុំផងកាលណោះ នៅភារកិច្ចរបស់មិត្តហ៊ា។

[១៥:០៣:២៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនទាន់មានការបកប្រែជាភាសាអង់គ្លេសទេ។ តើលោកមានស្តាប់ឮការបកប្រែជាភាសាអង់គ្លេសទេ? ខ្ញុំអត់ឮ ឥឡូវយើងព្យាយាមម្តងទៀត។

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំនឹងព្យាយាមសួរម្តងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំសូមអានឲ្យលោកស្តាប់នូវសក្ខីកម្មដែលលោកបានឆ្លើយនៅចំពោះមុខតុលាការ នៅថ្ងៃទី២២ មេសា ២០០៩។ នេះគឺឯកសារ E3/524 ជាសក្ខីកម្មដែលបានឆ្លើយនៅម៉ោង ១៥:២៥<>នាទី។ សូមដកស្រង់៖ "ណាត បានយកខ្ញុំទៅគុកពិសេសនេះម្តងទៀត។ គុកពិសេសនេះ គឺសម្រាប់អ្នកដែលមកពីកំពង់ឆ្នាំង។ វាគឺជាភូមិគ្រឹះមួយរបស់សម្តេច ស៊ីសុវត្ថិ មុនីរ៉េត គឺនៅតាមបណ្តោយផ្លូវ<នរោត្តម> នៅខាងត្បូងធនាគារជាតិ។ ណាត បានយកខ្ញុំទៅទីនោះ ហើយខ្ញុំបានឃើញ ស ភន នៅទីនោះ អង្គុយហើយកំពុងតែសរសេរចម្លើយសារភាព។" បញ្ចប់ការដកស្រង់។ តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី ដែលថាលោកបានឃើញ ស ភន កំពុងអង្គុយសរសេរចម្លើយសារភាពនៅក្នុងភូមិគ្រឹះនោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំទៅឃើញមែន ឃើញដូចខ្ញុំ នៅក្នុងសេចក្តីរាយការណ៍ហ្នឹង ក៏ប៉ុន្តែខ្ញុំឆ្ងល់ យកគុកពិសេសហ្នឹង មនុស្សមកពីកំពង់ឆ្នាំងយ៉ាងម៉េច ខ្ញុំ ឬមួយខ្ញុំនិយាយច្រឡំនៅក្នុងពេល ខ្ញុំមិនច្បាស់។

តាមពិតដូចជាមិនមានរឿងអីទាក់ទងនឹងកំពង់ឆ្នាំងទេ គុកពិសេសរបស់ ណាត។

[១៥:០៦:២៥]

**ស៖** ខ្ញុំសួរអ៊ីចេះទៅចុះ ថាតើមានមនុស្សប៉ុន្មាននាក់ដែលគេឃុំនៅគុកពិសេសនេះ? ហើយថា តើអ្នកដែលគេឃុំឃាំងនៅគុកពិសេសនេះ ក្រៅពី ស ភន នេះគឺជាអ្នកណាដែរ?

**ឆ៖** អរគុណ។ ខ្ញុំទៅជួបតែ ស ភន មួយភ្លែតហ្នឹងឯង ហើយចេញមកវិញឃើញ មិត្តហ៊ី គេកំពុងអង្គុយលើបង់ មើលអ្នកឃាមបណ្ដើរ អានឯកសារសារភាពបណ្ដើរ។ ដូច្នេះមិនដឹងអ្នកណានៅនុ៎ងខ្លះទេ។

**ស៖** នៅក្នុងអំឡុងពេលនោះ គឺលោកបានលើកឡើងអំពីការសួរចម្លើយ<មន្ត្រីរដ្ឋការ ឬ> ទាហាន លន់ នល់។ នៅពេលដែលលោកសួរចម្លើយអតីតមន្ត្រីរដ្ឋការ ឬក៏ទាហាន លន់ នល់ នោះ តើគោលបំណងនៃការសួរចម្លើយនេះ ដើម្បីអ្វីដែរ?

**ឆ៖** ខ្ញុំដូចអត់មានបានសួរចម្លើយផ្ទាល់លើទាហាន លន់ នល់ ណាម្នាក់ទេ បើតាមខ្ញុំចាំ។ ឥឡូវសូមលោកមេត្តាអានសេចក្ដីសារភាពហ្នឹង ឲ្យបានមុខក្រោយបន្តិច ទៅមុខបន្តិច ទៅក្រោយបន្តិច។

**ស៖** នៅក្នុងពេលលោកផ្ដល់សក្ខីកម្មក្នុងសវនាការរបស់លោកនៅថ្ងៃទី២៨ មេសា ២០០៩ គេបានបង្ហាញចម្លើយសារភាពមួយរបស់ ស ភន ដែលលោកបង្ហាញថា មានចំណាររបស់លោកសរសេរនៅលើចម្លើយសារភាពនេះ។ ខ្ញុំសូមដកស្រង់៖ "គោលបំណងរបស់យើង គឺចង់ស្វែងរក<ទីតាំងរបស់>ក្រុម<នោះ ឈ្មោះរបស់ពួកគេ និងការពិពណ៌នាពីរូបរាងកាយរបស់ពួកគេ> តើពួកគេប៉ុន្មាននាក់ទៅបរទេសហើយ? ហើយប៉ុន្មាននាក់ទៀតស្ថិតនៅក្នុងប្រទេសនៅឡើយ? ហើយតើអ្នកទាំងអស់នោះគឺជាអ្នកណា?" នេះគឺជាចំណារដែលលោកបានសរសេរនៅលើចម្លើយសារភាពដែលលោកបានឆ្លើយនៅថ្ងៃទី២៨ មេសា ២០០៩ នៅម៉ោង១៥:២៣ <ដល់ម៉ោង១៥:២៧> គឺឯកសារ E3/5794។ តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី? <តើលោកនៅចាំថា>លោកបានផ្ដល់មតិពាក់ព័ន្ធទៅនឹងការសួរចម្លើយមនុស្សជាក់លាក់មួយចំនួន<ទេ>? តើ<លោកចាំថាបានធ្វើអ៊ីចឹងទេ ហើយថាតើ>គោលបំណងរបស់លោកស្វែងរកព័ត៌មាន<>មន្ត្រីនៃរបប លន់ នល់ <ដើម្បីអ្វី>?

**ឆ៖** អរគុណ។ ហ្នឹងជាគោលបំណងពិត នៃការដឹកនាំសួរចម្លើយជំនាន់នុ៎ង។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីមើលនូវឯកសារE3/3652<> បាទសូមការ

អនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់លេខឯកសារម្តងទៀត ដូចជាបកប្រែពីរដងខុសគ្នា។

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន គឺឯកសារE3/3652 នេះគឺជាចម្លើយសារភាព ឬក៏ជារបាយការណ៍ពាក់ព័ន្ធទៅនឹងអ្នកទោសម្នាក់ឈ្មោះ ឡាំង ព្រឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះអនុញ្ញាត!

**លោក ឌេល លីសាក់៖**

ហើយយើងខ្ញុំក៏សូមការអនុញ្ញាតដាក់បញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រផងដែរ។

[១៥:១១:00]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយការអនុញ្ញាតនេះគឺជាទូទៅ ប្រសិនបើលោកចង់ធ្វើដូច្នេះ គឺអង្គជំនុំជម្រះអនុញ្ញាតតែម្តង លើកលែងតែមានការជំទាស់តវ៉ាពីភាគីផ្សេងទៀត ដែលអង្គជំនុំជម្រះនឹងសម្រេចតាមករណីជាក់លាក់ ជាក់ស្តែងមួយចំនួន។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹងសូមចាក់បញ្ចាំងនៅលើអេក្រង់កុំព្យូទ័រ នៅទំព័រក្របមុខ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តើលោកនៅចាំឯកសារនេះទេ? ជាពិសេស តើលោកនៅចាំថា អ្នកណាជាអ្នកចុះហត្ថលេខានៅខាងក្រោម ជ្រុងខាងស្តាំនៃទំព័រនេះដែរទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ អ្នកដែលចុះហត្ថលេខានៅខាងក្រោម ជ្រុងខាងស្តាំនេះគឺ ណាត។ ណាត ហ្នឹងមានឈ្មោះ សែម ហើយខ្ញុំបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតហើយ ណាត ប្រែឈ្មោះ សែម នៅពេលសមរភូមិអ្នកលឿង នៅពេលដែលវរសេនាធំរបស់គាត់ម្នាក់ស្លាប់ទៅ នៅសមរភូមិអ្នកលឿងនោះគាត់ក៏យកឈ្មោះ សែម របស់សពហ្នឹង យកមកដាក់ខ្លួនគាត់។ ប៉ុន្តែមានមនុស្សតិចណាស់ដែលហៅ

ណាត ថា សែម។ មានតែ បងពីន មួយទេ ក្រៅពីនោះ បង០៣ ទាំងអស់។

[១៥:១៣:០០]

**ស៖** ហើយនៅខាងក្រោមបន្ទាប់ពីហត្ថលេខារបស់ ណាត មានកំណត់សម្គាល់មួយ បើលោកមើលទៅឯកសារនេះទៅ លោកឃើញមានឈ្មោះនៅក្នុងឯកសារនេះ ដែលគេមានដាក់នៅក្នុង សរសេរដាក់ក្នុងប្រអប់ ហើយក៏មានឈ្មោះដែលគេគូសបន្ទាត់ពណ៌នៅខាងក្រោមផង។ ហើយមានការចារថា "ឈ្មោះក្នុងប្រអប់បានចាប់ខ្លួនហើយ"។ អ្នកដែលអូសបន្ទាត់ពណ៌ពីខាងក្រោម គឺថា<ស្នើសុំ>ចាប់ខ្លួន។ ហើយឈ្មោះដែលគេគូសបន្ទាត់ពីខាងក្រោមមួយទៀត គេថា "ត្រូវតែស្វែងរកចាប់ខ្លួន"។ តើលោក<ចាំពី>ប្រព័ន្ធ<នេះទេ? តើនេះជាអ្វី>ដែល ណាត បានប្រើប្រាស់ឬ នៅពេលគាត់ធ្វើជាប្រធានមន្ទីរសន្តិសុខក្នុងការដំណើរការសន្តិសុខនោះ?

**ឆ៖** ខ្ញុំមិនទាន់ចូលកាន់ការនៅនឹងនោះទេ។ ពេលហ្នឹង គឺខ្ញុំកំពុងតែរត់ទៅដើរប្រមូលឯកសារ។ ដូច្នេះបើសិនជាខ្ញុំឆ្លើយ វាទៅជាសេចក្ដីសន្និដ្ឋាន។ ប៉ុន្តែអារឿងសេរីក្នុងរឿងចាប់មនុស្ស ណាត សេរីបន្តិច។

**ស៖** លោកសាក្សី ខ្ញុំមិនចង់ឲ្យលោកឆ្លើយស្មានៗទេ <ដូច្នេះ ខ្ញុំនឹងសួរសំណួរច្បាស់ៗទៅលោក>។ សូមលោកមើលចំណារដែលសរសេរដោយដៃនៅត្រង់ក្របទំព័រមុខ គឺនៅជ្រុងខាងលើ ខាងឆ្វេង។ យើងខ្ញុំនឹងផ្ដល់ឯកសារថតចម្លងទៅលោកមួយ ហើយមានកែវពង្រីកដែរ ហើយក៏បញ្ចាំងនៅលើអេក្រង់។ នៅជ្រុងខាងឆ្វេង ខាងលើនោះ គឺថាមានៗគេចារអ៊ីចឹងដែរ។ សូមលោកពិនិត្យមើលត្រង់ប្រអប់ខាងក្រោមនេះ។

**ឆ៖** អរគុណ ខ្ញុំមើលឃើញហើយ។

**ស៖** តើលោកដឹងថា អក្សរសរសេរដោយដៃនេះ ជាអក្សររបស់អ្នកណាដែរ?

**ឆ៖** សូមបញ្ជាក់អក្សរហ្នឹង បើតាមខ្ញុំធ្លាប់ឃើញគឺអក្សររបស់មេខ្ញុំ។ គាត់ឈ្មោះ ខៀវ – សុន សេន គឺបងសុន សេន។

[១៥:១៦:១៤]

**ស៖** ហេតុផលដែលខ្ញុំសួរបញ្ជាក់អំពីឯកសារនេះ គឺថាលោកបានលើកឡើងថា លោកបានចូលរួមពាក់ព័ន្ធ គឺថានៅពេលមួយនោះ សួរចម្លើយកម្មករមកពីរោងចក្រក្រដាស។ ហើយអ្នកដែលជាប់ឃុំឃាំងទាំងនេះ គឺមកពីរោងចក្រក្រដាស ក-៥។ ក្នុងនោះមានមនុស្សទាំងអស់១៤នាក់។ ហើយនៅក្នុង

របាយការណ៍របស់ ណាត ដែលបញ្ជាក់ថា គឺជាអ្នកជំទាស់ ហើយដែលត្រូវបានចាប់ខ្លួន។ សំណួរខ្ញុំសួរថាតើលោកមានបានចូលរួមសួរចម្លើយដែរទេ ក្រោយពេលរបាយការណ៍នេះចេញមក ក្រោយមានការចាប់កម្មករមកពីរោងចក្រក្រដាសជាបន្តបន្ទាប់មកទៀតនោះ?

**ឆ៖** អរគុណ។ ខ្ញុំបានសួរមែន ក្នុងចំណោមកម្មករមកពីរោងចក្រក្រដាស។ រោងចក្រក្រដាសនោះដូចឈ្មោះ ក-១០ ទេអី ឬ ក-៥?

**ស៖** តើលោក<ចាំ>ទេថា អ្នកទាំងអស់នេះត្រូវបានគេ<>កំណត់អត្តសញ្ញាណរកឃើញថាជាអតីតទាហាន លន់ នល់ ដែរឬ?

**ឆ៖** បើតាមខ្ញុំចាំ ខ្ញុំសួរបានប៉ុន្មាន ដូចម្នាក់ទេ ឈ្មោះវា អាផាត កម្មកររោងចក្រ។ ពួកនេះបើតាមខ្ញុំចាំដែរ មិនមែនជាសំដៅទាហានចាស់ទេ គឺវាដុតបំផ្លាញរោងចក្រនេះ មិនឱ្យដំណើរការបាន។ រោងចក្រនេះនៅចាក់អង្រែ។

**ស៖** អ្នកដែលលោកបានសួរចម្លើយហ្នឹង គឺលោករកឃើញថា មិនមែនជាអតីតទាហាន លន់ នល់ ទេ ត្រឹមត្រូវដែរឬទេ?

[១៥:១៨:៥៥]

**ឆ៖** ត្រឹមត្រូវ។

**ស៖** ឥឡូវនោះយើងផ្តោតទៅលើអំឡុងពេលដែលស-២១ ចាប់ផ្តើមដំណើរការ។ តើលោកអាចប្រាប់តុលាការបានទេថា អ្នកទោសគឺជាអ្នកណាដែរ ដែលគេនាំយកមកស-២១នៅដើមដំបូងនាខែតុលា ឆ្នាំ១៩៧៥នោះ? ហើយតើអ្នកទោសទាំងអស់នេះ មកពីខាងណាដែរ?

**ឆ៖** អរគុណ។ អ្នកទោសទាំងអស់នេះ ភាគច្រើន ៗតែចាប់មកខាងតំបន់២៥។ តំបន់២៥ ដូចខ្ញុំបានជម្រាបហើយ គឺស្រុកស្អាង កោះធំ លើកដែក កៀនស្វាយ ជាតំបន់សកម្មភាពចាស់របស់កងពល ១២ របស់ ណាត។

**ស៖** ហើយអ្នកទោសដែលមកដំបូងៗនៅស-២១នោះ តើអ្នកទោសទាំងអស់នេះ ត្រូវបានគេបញ្ជូនមកពីគុកដទៃទៀតដែរ ឬក៏អត់ទេ ដូចជាគុកតាខ្មៅជាដើម? ឬក៏ថាអ្នកទោសទាំងអស់នេះ ទើបតែត្រូវបានគេចាប់ខ្លួនទេ ឬក៏ទាំងពីរតែម្តង?

**ឆ៖** បើតាមខ្ញុំចាំ អ្នកទោសនៅតាខ្មៅ គេកម្ទេចដាច់ដោយឡែក។ សូម្បីតែខែ៣ ដែល ណាត ត្រូវបក្សដកចេញពីប្រធាន ស-២១ ក៏ដោយ ក៏ ណាត នៅតែមានសិទ្ធិចូលមកមើលការបង្ហើយការងារ

ចាស់ ដឹកនាំ មិត្តហ៊ី បង្ក្រើយការងារចាស់។ ឯចំណែកអ្នកដែលចាប់មកក្រោយ ផ្សេង។ គេយកមកដាក់នៅ អង្គាល់នោះ ដំបូងកន្លែងសួរចម្លើយ គឺនៅនឹងត្រង់កាច់ជ្រុងផ្លូវលេខ អ្ហឹ!ប៉ុន្មានទេ វង្វេងហើយ។ ក្រោយកន្លែងស-២១ថ្មីនេះបន្តិច។ ហើយដល់ក្រោយមក បានខ្ញុំបញ្ចូលទៅក្នុងសាលានុ៎ង។ ហើយដល់ក្រោយមក មានផ្លាស់ម្តងទៅប៉េហ្ស៊ី។ ហើយត្រឡប់ប៉េហ្ស៊ី មកនៅកន្លែងចាស់វិញទៀត បាន ណាត ចេញទៅ។ ដូច្នេះសូមបញ្ជាក់សរុបឡើងវិញ ក្រោយពេលដែល ណាត ត្រូវបក្សដកចេញពីស-២១ លែងឲ្យធ្វើប្រធាន ក៏ប៉ុន្តែបក្សនៅអនុញ្ញាតឲ្យ ណាត មានសិទ្ធិមកបង្ក្រើយការងារចាស់ឲ្យហើយ ឲ្យជ្រះស្រឡះ មួយរយៈ។

[១៥:២២:២៤]

**ស៖** ខ្ញុំចង់ផ្តោតអំឡុងពេលដែល ណាត នៅធ្វើជាប្រធាន ហើយលោកគឺជាអនុប្រធានស-២១ ដដែល។ ជាពិសេសអំឡុងពេលខែតុលា ឆ្នាំ១៩៧៥ គឺពេលដែល ស-២១ ចាប់ផ្តើមដំណើរការជាលើកដំបូង។ ខ្ញុំសូមអានចេញពីសក្ខីកម្មរបស់លោកនៅថ្ងៃទី២២ ខែមេសា ២០០៩ ឯកសារ E3/524 នៅម៉ោង១៥:២៨ លោកបាននិយាយអំពីអំឡុងខែតុលា ឆ្នាំ៧៥ ហើយលោកបានលើកឡើងដូចតទៅ៖ "ណាត បញ្ជាឲ្យខ្ញុំឲ្យស្នាក់នៅក្នុងផ្ទះមួយ នៅផ្លូវលេខ<៤១៣ ឬ ៤៣១> ដែលជាផ្ទះរបស់<ឧត្តមសេនីយ៍ ខៀវ> គឹមអេង។ ខ្ញុំស្នាក់នៅទីនោះ ហើយក្រោយមក គេបានឲ្យខ្ញុំយកអ្នកទោសពីតាខ្មៅមកដាក់នៅផ្ទះនេះ ដើម្បីឲ្យកម្មាភិបាលរបស់ខ្ញុំសួរចម្លើយ។" បញ្ចប់ការដកស្រង់។ តើចំណុចនេះ វាជួយដល់រំឭកដល់ការចងចាំរបស់លោកទេ? <តើ>លោក<ចាំថា>បានទៅយកអ្នកទោសពីតាខ្មៅ យកមកដាក់ផ្ទះមួយនៅភ្នំពេញ ដែលលោកចាប់ដំណើរការជាលើកដំបូង<នោះទេ>?

**ឆ៖** មែន ពេលចាប់ដំណើរការលើកដំបូងនោះ ខ្ញុំត្រូវ ណាត ចាត់តាំងឲ្យទៅនៅផ្ទះ ជា គឹមអេង ឧត្តមសេនីយ៍ប៉េអឹមនោះ ក៏ប៉ុន្តែអ្នកទោសពង្រាយនៅក្រោយ នៅខាង មើល៍ ដូចខាងត្បូងផ្ទះនុ៎ង ហើយខ្ញុំឲ្យក្មេងៗចាប់ផ្តើមសួរ។ ជាពិសេស ក្មេងៗមកពីអមលាំងទេ របស់ខ្ញុំនោះ ចាប់ផ្តើមសួរនៅនុ៎ង។

[១៥:២៤:៣៤]

**ស៖** ហើយអ្នកទោសដំបូងៗដែលមកដល់ស-២១នោះ តើប៉ុន្មាននាក់ជាអតីតមន្ត្រីរដ្ឋការ និងទាហាន លន់ នល់? សូមលោកប៉ាន់ប្រមាណមើល ភាគច្រើនជាអតីតមន្ត្រីរដ្ឋការ និងទាហានលន់ នល់ ឬក៏ប្រហែលជាប៉ុន្មានភាគរយ?

**ឆ៖** មនុស្សដែលជាអ្នកទោសដែលខ្ញុំចាំ គឺភាគច្រើនជារោងចក្រក្រដាស ហើយនិងរោងចក្រអគ្គិសនីចាក់អង្រែ អ្ហែ!ផ្សារតូចមិនដឹង អគ្គិសនីចាក់អង្រែមិនដឹង។

**ស៖** ឥឡូវសូមលោកពិនិត្យមើលឯកសារមួយទៀត គឺជាបញ្ជីស-២១ដំបូងដែ គឺឯកសារ E3/1539។ បាទ យើងខ្ញុំសុំការអនុញ្ញាត ផ្ដល់ឯកសារជូនទៅសាក្សី ឯកសារ E3/1539។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំផ្ដល់ជូនទៅលោកនេះ លោកសាក្សី មានចំណងជើងថា "ឈ្មោះអ្នកទោសដែលស្លាប់នៅស-២១(គ)" ដែលក្នុងនោះមានអ្នកទោសជាង១៥៩នាក់ ភាគច្រើនគឺជាអតីតទាហាន លន់ នល់ ដែលមានបុណ្យស័ក្តិធំ តូចខុសគ្នា ដែលត្រូវបានសម្លាប់នៅចន្លោះថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៦ និងថ្ងៃទី៣០ មីនា ១៩៧៦។ សំណួររបស់ខ្ញុំដំបូង គឺតើមន្ទីរស-២១(គ)ហ្នឹង មានន័យថាម៉េចដែរ?

[១៥:២៧:៣៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** មន្ទីរស-២១(គ) អីៗហ្នឹង ខ្ញុំមិនដឹង។ និយាយឲ្យតាមពិត កាលដែលខ្ញុំគ្រប់គ្រងជារួម គឺមន្ទីរស-២១ហ្នឹង មានតែឯស្រែ គេហៅថា "ព្រៃស" ហើយនិងភ្នំពេញ។ ដល់(ក), (ខ), (គ), (ឃ) ខ្ញុំវង្វេង ហ្នឹងជម្រាបដោយត្រង់។ រួចកាលដែលខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអំមិញថា ក្រោយៗពេលដែល ណាត ដកចេញទៅ បក្សដកចេញទៅ ណាត មានសិទ្ធិមកបង្ហើយការងារចាស់។ មកដល់គាត់ចាត់តាំង មិត្តហ៊ី ឲ្យប្រតិបត្តិការ។ ដូច្នេះរឿងទាហានរឿងអី ខ្ញុំដូចជាអត់មានចូលមកដល់ដៃខ្ញុំទេ ព្រោះទាហានជាទូទៅ គឺគេកម្ទេច។

**ស៖** ខ្ញុំសូមសួរសំណួរពាក់ព័ន្ធ<មួយសំណួរ គឺ>គុកតាខ្មៅ។ លោកបានបញ្ជាក់ហើយ ថាលោកបានបញ្ជូនអ្នកទោសពីទីនោះមកកាន់ ស-២១។ តើ ស-២១ បន្តប្រើប្រាស់គុកតាខ្មៅដល់ពេលណាដែរ? <នៅក្នុងចម្លើយរបស់លោក នៅពេលខ្លះលោកនិយាយថា គេប្តូរកន្លែងនោះទៅជាក្រសួងសង្គមកិច្ច។ តើលោកចាំទេរយៈពេលប៉ុន្មានដែល>គុកតាខ្មៅត្រូវបានស-២១ ប្រើប្រាស់<>? ហើយតើគុកតាខ្មៅនេះ ត្រូវបានគេហៅឈ្មោះមួយទៀតថា មន្ទីរស-២១(គ) នោះដែរឬទេ?

**ឆ៖** ខ្ញុំឆ្លើយមិនរួចទេ អក្សរមន្ទីរស-២១(គ), (ឃ), (ង)អីហ្នឹង ប៉ុន្តែបើឯកសារដែលខ្ញុំឃើញ

មន្ទីរនៅតាខ្មៅនេះ ដូចជាគេហៅ មន្ទីរ៤៣ ឬ ៤៤ ទៅវិញទេ។

**ស៖** ខ្ញុំនឹងសួរលោកអំពីបញ្ជីនេះ ប៉ុន្តែឥឡូវ ខ្ញុំឲ្យលោកពិនិត្យមើលឯកសារមួយទៀត ក្រែងវាជួយលោកទៅដល់ការកំណត់ថា តើមន្ទីរស-២១(គ) ជាអ្វីដែរនោះ។ ឯកសារចង់ឲ្យលោកមើលនេះ គឺ E3/8493។ លោកប្រធាន សូមផ្តល់ឯកសារ E3/8493 នេះទៅឲ្យសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៣០:៥៩]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នេះគឺជាឯកសារចុះថ្ងៃទី១១ មេសា ១៩៧៦ បញ្ជីនេះមាននិយាយអំពីបញ្ជីអ្នកទោសប្រចាំថ្ងៃសរុបនៅ ស-២១។ ហេតុផលដែលខ្ញុំផ្តល់បញ្ជីនេះទៅឲ្យលោកពិនិត្យមើល គឺថាមានអ្នកទោសសរុបទាំងអស់សម្រាប់មន្ទីរស-២១(ក) លោកមើលទំព័រដំបូងទៅឃើញហើយ។ ឃើញថា មានអ្នកទោស ២៦២នាក់ នៅឯមន្ទីរស-២១(ក) ហើយ៣៩៦នាក់នៅឯមន្ទីរស-២១(គ) <សរុបទៅគឺមានអ្នកទោស ៦៥៨នាក់>។ សំណួររបស់ខ្ញុំសួរថាតើបញ្ជីនេះក្រោយលោកពិនិត្យមើលហើយ ជួយរំឭកដល់ការចងចាំរបស់លោកទេ? ដែលថា នៅពេលនោះ តើមន្ទីរ២១(ក) ជាអ្វី? មន្ទីរ២១(គ) ជាអ្វីដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសលោកព្រះរាជអាជ្ញា លេខនេះ បើតាមខ្ញុំចាំ តាមខ្ញុំចំណាំ គឺលេខ មិត្តហ៊ុ លេខ មិត្តហ៊ុ។ ដូច្នេះសរុបមក ដូចខ្ញុំបានរាយការណ៍ជម្រាបរឿងរ៉ាវនៅស-២១នេះ មានមួយចំនួន ខ្ញុំអត់ដឹងទេ។ ដូច្នេះបញ្ជីនេះក៏ស្ថិតនៅក្រៅការត្រួតពិនិត្យរបស់ខ្ញុំ ដែលដូចខ្ញុំបានជម្រាបព្រះរាជអាជ្ញា អំមិញអ៊ីចឹង គឺ ណាត ក្រោយពេលដែលបក្សដកទៅ គាត់នៅតែមានសិទ្ធិចូលមកស-២១ ដឹកនាំ មិត្តហ៊ុ បង្ហើយការងារចាស់។ នេះសិទ្ធិរបស់គាត់ដែល សុន សេន ឧទ្ទេសនាម។ ដូច្នេះរឿងនេះ (ក), (ខ), (គ) នេះ ជាពាក្យដែលគាត់ ហើយនិង មិត្តហ៊ុ សន្មតគ្នាទេ។ ដូច្នេះខ្ញុំមិនដឹងថា ស្អី(ក) ស្អី(ខ) ស្អី(ឃ)ទេ។ ដល់មករៀប ដែលខ្ញុំធ្វើការ កាន់កាប់កិច្ចការនេះជាប្រធានពិតប្រាកដ ខ្ញុំអត់ដែលប្រើទេ (ក), (ខ), (គ), (ឃ), (ង)។

[១៥:៣៣:៥៥]

**ស៖** ប្រសិនបើយើងមើលតាមឯកសារហ្នឹង ថាតើឯកសារហ្នឹងនៅមុនពេលដែលលោកផ្ទេរ

មកទីតាំងសាលារៀនទួលស្លែងហ្នឹងមែនទេ? គឺថាថ្ងៃទី១១ មេសា ៧៦ហ្នឹង ដែលថាមានអ្នកទោស <២៦២>នាក់នៅស-២១(ក) មាន៣៩៦<នាក់>នៅស-២១(គ)ជាដើមនុ៎ង? ដូច្នេះថាតើកាលបរិច្ឆេទហ្នឹង នៅមុនពេលដែលលោករើទីតាំង ឬក៏ក្រោយពេលដែលលោករើទីតាំងមកសាលាទួលស្លែងហ្នឹង?

**ឆ៖** ខ្ញុំចាប់ផ្ដើមកាន់កាប់កិច្ចការដំបូងគឺនៅនឹងផ្ទះ ជា គឹមអេង។ ក្រោយមកខ្ញុំត្រូវ ណាត រុញឱ្យទៅនៅខាងអគ្គនាយកដ្ឋានខាងប៉ូលិសជាតិ។ ក្រោយមកត្រឡប់មកទីតាំងចាស់ដដែលវិញ គឺម្ដុំផ្ទះ ជា គឹមអេង ជុំវិញផ្ទះ ជា គឹមអេង។ ដល់ក្រោយមក ខ្ញុំឃើញពិបាក ខ្ញុំសុំច្បាប់អនុញ្ញាតយកវិទ្យាល័យពញាយ៉ាតនេះ ធ្វើជាទីតាំងឃុំឃាំងអ្នកទោស។

**ស៖** ដូច្នេះខ្ញុំចង់សួរលោកថា តើលោកគិតថា កាលបរិច្ឆេទហ្នឹងនៅមុន ឬក៏ក្រោយ គឺកាលបរិច្ឆេទថ្ងៃ១១ មេសា ៧៦ហ្នឹង ថាតើវាមុនពេលដែលលោករើមកសាលារៀនហ្នឹង ឬក៏ក្រោយពេលដែលលោករើទីតាំងមកសាលារៀនហ្នឹង?

**ឆ៖** ខ្ញុំពិបាកនិយាយណាស់រឿងនេះ ព្រោះការងារនេះ គេធ្វើ។ គេអាចរំកិលកាលបរិច្ឆេទនេះទៅមុន ឬទៅក្រោយ។ រឿងមានបញ្ហាហ្នឹងមួយទៀតដែលនៅសេសសល់ដល់ឥឡូវ។ មិត្តហ៊ី ហើយនិង ណាត ហ្នឹង គេរំកិលកាលបរិច្ឆេទចុះហត្ថលេខាហ្នឹង ទៅមុន ឬទៅក្រោយ។ ដូច្នេះបញ្ហាពិបាកណាស់។

[១៥:៣៦:១៥]

**ស៖** យើងនឹងពិភាក្សាអំពីបញ្ជីនេះ នៅពេលក្រោយបន្តិចទៀត។ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ឱ្យលោកមើលទៅលើឯកសារ E3/1539 បញ្ជីអ្នកទោស<១៥៩>នាក់ ដែលត្រូវកម្ទេចនៅចុងខែមីនានោះ។ ខ្ញុំមានឈ្មោះមួយចំនួនដែលខ្ញុំចង់សួរលោក។ ដូច្នេះខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើឯកសារមុននេះ គឺឯកសារដែលខ្ញុំផ្ដល់ជូនលោករួចហើយ។ ហើយខ្ញុំចង់សួរលោកអំពីអ្នកទោសគឺលេខ៣៧ នៅក្នុងបញ្ជីនេះ។ តើលោកចាំទេ ថាមានវរសេនីយ៍<ទោ>មួយរូប សូមទោស ប្រសិនបើខ្ញុំមិនត្រូវ ឈ្មោះ បាន អ៊្វិចនិលពេជ្រ <> តើលោកចាំអ្វីខ្លះអំពីឈ្មោះមនុស្សដែលខ្ញុំអានឱ្យលោកស្ដាប់អំមិញនេះ?

**ឆ៖** បាន អ៊្វិចនិលពេជ្រ ខ្ញុំទៅជួប។ ណាត នាំខ្ញុំទៅជួប។ ណាត ឧទ្ទិសនាមប្រាប់ថា ជាឪពុកមាគាត់ ជាមេតស្សរ:ចាស់ ហើយដែលភ្ជាប់ខ្លួនមក ព្រះនរោត្តម សីហនុ ប្រទានងារជា ប៉ាន អ៊្វិចនិលពេជ្រ ពាក់ស័ក្តិ៤កន្លះ។ បំណង ណាត ខ្ញុំមិនដឹងយ៉ាងម៉េចទេ គាត់អត់ប៊ានិយាយអីច្បាស់លាស់ទេ។ ប៉ុន្តែបើតាមខ្ញុំស្មាន ចង់ឱ្យខ្ញុំជួបឃុបឃិតលាក់ទុកមនុស្សនេះឱ្យនៅរស់។ ខ្ញុំបានទៅជួប គាត់មានរៀបគ្រែមួយអីៗ។ ប៉ុន្តែទីតាំងដែលនាំខ្ញុំទៅនោះ មិនមែននៅក្បែរគុកទួលស្លែងឥឡូវនេះទេ ក្បែរទីតាំងវិទ្យា

ល័យពញាយ៉ាតនេះទេ គឺនៅឯអគ្គនាយកដ្ឋាននគរបាលជាតិ។ គាត់មានរៀបបន្ទប់មួយដោយឡែក មានគ្រែ មានកន្ទេលអី ដេកត្រឹមត្រូវ។ នេះដល់មកខ្ញុំមិនចាំ ដូចគ្មាននរណាសួរចម្លើយទេ ហើយប្រហែលជា ណាត ក៏មិនប៉ានទុកដែរ អាចឲ្យគេកម្ទេច។ រឿងនេះ ខ្ញុំដូចជាបានរាយការណ៍ជូនតុលាការដែរ ឬក៏មិនបានរាយការណ៍ មិនដឹងទេ ប៉ុន្តែមាន ខ្ញុំឃើញ គាត់នាំខ្ញុំទៅ។

**ស៖** ដូច្នេះដើម្បីឲ្យប្រតិចារឹកច្បាស់គឺថា បាន អ៊ូច ថាតើ បាន អ៊ូច ហ្នឹងជាសាច់ញាតិរបស់ ណាត មែនទេ?

[១៥:៣៩:២៥]

**ឆ៖** ត្រឹមត្រូវ។ បាន អ៊ូចនិលពេជ្រ។ តាអ៊ូច នេះជាឪពុកមា ណាត។ "និលពេជ្រ" នេះជាងារដែលសម្តេចព្រះនរោត្តម សីហនុ ប្រទានឲ្យ។

**ស៖** ឯកសារនេះគឺ E3/1539 បានបញ្ជាក់ថា គាត់ត្រូវបានកម្ទេចគឺនៅថ្ងៃ២៦ មីនា ឆ្នាំ ១៩៧៦។ ដូច្នេះខ្ញុំចង់សួរថា ហេតុអ្វីបានជា ណាត ព្រោះថាពេលនុ៎ង ណាត នៅជាប្រធានស-២១ នៅឡើយ ហេតុអ្វីជា ណាត មិនអាចជួយពូខ្លួនឯង <>ឲ្យគេសម្លាប់បាន?

**ឆ៖** មនុស្សនេះ តាអ៊ូច នេះឈ្មោះល្បី ថ្នាក់ដឹកនាំស្គាល់ តាអ៊ូច។ អ៊ីចឹងហើយបាន អាណាត មិនប៉ានទុក។

**ស៖** ហេតុអីបានជាគាត់ជាមនុស្សល្បី?

**ឆ៖** ពីដើមគាត់ជាមេឥស្សរៈ ដែលកាន់អារុធតស៊ូ ដល់ក្រោយមកចុះចូលជាមួយនឹងព្រះនរោត្តម សីហនុ។ ព្រះនរោត្តម សីហនុ ប្រទានងារឲ្យ។ ដូច ដាប ឈួន អ៊ីចឹង គាត់ឈ្មោះ ឈួន ប៉ុន្តែព្រះនរោត្តម សីហនុ ប្រទានងារឲ្យថា "ឈួនម្ចុលពេជ្រ"។ នេះបាន អ៊ូច គាត់ឈ្មោះតាអ៊ូច ព្រះនរោត្តម សីហនុ ប្រទានងារថា "និលពេជ្រ"។

**ស៖** មនុស្សបន្តទៀតនៅក្នុងបញ្ជីនេះ គឺខ្ញុំនឹងសាកសួរលោក គឺថាមានប្រហែលជា១២នាក់ ដែលមិនត្រូវបានគេចាត់ទុកថាជាមន្ត្រីរដ្ឋការ ឬក៏ទាហាននោះទេ ប៉ុន្តែពួកគាត់ត្រូវបានគេកំណត់ថាជាសាច់ញាតិ ឬក៏សមាជិករបស់ ឡុង បូរ៉េត គឺអតីតនាយករដ្ឋមន្ត្រីសម័យនោះ។ គឺប្រសិនបើលោកមើលទៅលើបញ្ជី គឺលេខ៤៤ ដល់៤៩។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ លេខ១៣៥ ដល់១៣៦, លេខ១៤៩ និងលេខ១៥៣ ដល់១៥៥។ ពួកគាត់ទាំងអស់នេះត្រូវបានគេបង្ហាញថាជាសាច់ញាតិ ឬក៏ជាសមាជិកគ្រួសាររបស់ ឡុង បូរ៉េត។ ខ្ញុំចង់សួរថាហេតុអ្វីបានជាសាច់ញាតិ ឬក៏សមាជិកគ្រួសារ

របស់ ឡុង បូរ៉េត ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ដែរនៅស-២១នោះ?

[១៥:៤២:៥៣]

**ឆ៖** ទី១ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំឃើញមែន ឈ្មោះនេះនៅក្នុងបញ្ជីស-២១ តែខ្ញុំឲ្យៗខ្ញុំឃើញមុខអ្នកណាម្នាក់ដែលមានត្រកូល "ឡុង" នោះ ខ្ញុំអត់ឃើញទេ។ ទី២ មនុស្សល្បីប៉ុន ឡុង បូរ៉េត គេកម្ទេចចោលមួយពូជ។ បើរត់មិនរួចទេ ខ្មោចអ៊ីចឹង។

**ស៖** ហើយប្រសិនបើលោកមើលទៅបញ្ជីលេខចុងក្រោយ គឺលេខ១៥៩វិញ លេខ១៥៩ នៅក្នុងបញ្ជីនេះគឺជាកូន<៤នាក់>របស់ ថាច់ ជា។ ខ្ញុំដឹងហើយ គឺថាលោកបានផ្តល់សក្ខីកម្មរួចមកហើយអំពីបុគ្គលនេះ ដូច្នេះខ្ញុំចង់ឲ្យលោកជម្រាបដល់តុលាការម្តងទៀត ថាតើ ថាច់ ជា គឺជាអ្នកណា? ហើយថាតើលោកស្គាល់ប្រពន្ធ និងកូនរបស់គាត់ទេ?

**ឆ៖** ថាច់ ជា ជាសាស្ត្រាចារ្យ ជំនាន់ទីប៉ុន្មាន ខ្ញុំមិនដឹងទេ ប៉ុនគ្រាន់តែដឹងថាមុនខ្ញុំ អាចស្រួលមិនស្រួលជំនាន់ទី១ផង។ ខ្ញុំជំនាន់ទី៦។ ឯចំណែកប្រពន្ធគាត់ ក៏ជាសាស្ត្រាចារ្យ។ ដល់ក្រោយមកមនុស្សនេះបានឡើងធ្វើជារដ្ឋមន្ត្រី -- រដ្ឋលេខាធិការក្រសួងសិក្សាធិការ។ ពេលនោះ កែវ សាំងគីម ធ្វើជារដ្ឋមន្ត្រី។ ហើយនៅបាតុកម្មរបស់និស្សិតនោះ មានមនុស្សម្នាក់ មិនដឹងជានិន្នាការនយោបាយអាម៉េចទេ ឈ្មោះ សា សុន នាំបាតុករសម្លាប់ កែវ សាំងគីម និង ថាច់ ជា ទៅ។ ខ្ញុំគ្រាន់តែចាប់អារម្មណ៍ថា សា សុន នេះមិនមែនខ្មែរក្រហមទេ មិនមែនជាអ្នកតស៊ូនៅក្រុងទេ មិនដឹងជានិន្នាការគេយ៉ាងម៉េចទេ។ ហើយដល់ក្រោយមក ថ្ងៃ១៧មេសា បក្សកុម្មុយនីស្តកម្ពុជាឈ្នះ ទៅចាប់យកប្រពន្ធ ហើយនិងកូនរបស់ ឡុង បូរ៉េត យកមក។ រឿង--

[១៥:៤៥:៣៨]

**ប្រធានអង្គជំនុំ៖**

យើងនិយាយពី ថាច់ ជា អំមិញ។ បាទៗ លោកច្រឡំ អាចច្រឡំទៅ ឡុង បូរ៉េត វិញ អំមិញ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះគឺថានៅពេលដែល ថាច់ ជា ត្រូវបានគេសម្លាប់ គឺសម្លាប់ឆ្នាំ៧៤ ថាតើគាត់ ពេលនោះគាត់ធ្វើការនៅក្រសួងអប់រំ មែនទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** បាទ មែន។

**សៈ** ហើយកូនគាត់ទាំងបួននាក់ដែលមាននៅក្នុងបញ្ជីសម្លាប់ហ្នឹង លោកដឹងទេថា កូនរបស់គាត់ទាំងបួននាក់ហ្នឹង មានអាយុប៉ុន្មានឆ្នាំដែរ?

**ផៈ** ខ្ញុំអត់ដឹងទេ។ ប្រពន្ធ ថាច់ ជា នេះខ្ញុំដូចជា ពេលដែលចូលទៅដល់ស-២១ ខ្ញុំអត់បានទៅមើលទៀតផង ប៉ុន្តែពីខាងក្រៅ ខ្ញុំឃើញ នាងនុំងដើរជាមួយនឹងប្តី ក្នុងឱកាសមួយដែល ថាច់ ជា យកភាពយន្តឯកសារមួយ យកទៅបញ្ចាំងនៅនឹង អ៊ី.អិន.ប៉េ នោះ នៅនឹងវិទ្យាស្ថានជាតិគរុកោសល្យនោះ។

**សៈ** តើប្រពន្ធរបស់ ថាច់ ជា ត្រូវបានគេឃុំនៅស-២១ដែរឬទេ? ហើយតើលោកអាចប្រាប់តុលាការបានទេថា មានអ្វីកើតឡើងចំពោះប្រពន្ធរបស់ ថាច់ ជា នោះ?

[១៥:៤៧:២៩]

**ផៈ** រឿងនេះ ប្រពន្ធ ថាច់ ជា នេះវាមានការប៉ះទង្គិចគ្នា រវាងខ្ញុំ និង ណាត។ ថ្ងៃមួយនោះក្មេង ៗ គេមកយក គេមកសុំយកប្រពន្ធ ថាច់ ជា យកទៅឲ្យពេទ្យរៀនវះកាត់។ ខ្ញុំថា អ្ហ៎កុំ! ដល់ភ្លាមនុំង ថ្ងៃនុំង ឬថ្ងៃក្រោយ មេហៅខ្ញុំទៅធ្វើការ តាមពិតអង្គាល់ខ្ញុំនៅជាអនុប្រធាន មេហៅទៅទាំងពីរៗ ទាំងខ្ញុំទាំង ណាត។ ដល់ទៅមិនដឹងជារឿងម៉េច វាស្រាប់តែ ណាត ហ្នឹង គាត់រាយការណ៍ថា ប្រពន្ធ ថាច់ ជា ហ្នឹង គាត់ឲ្យពេទ្យ គេយកទៅរៀនវះកាត់ហើយ។ ខ្ញុំថា អ្ហ៎! អត់ទេ ខ្ញុំប្រឆាំង។ ខ្ញុំបដិសេធមិនឲ្យយកទេ។ បាន ណាត គាត់ថា អត់ទេ គេយកទៅហើយ។ បានដល់ពេលនុំង មេស្តីឲ្យ ថាមិនត្រូវយកប្រពន្ធអ្នកល្បីអីចឹងទៅធ្វើអីអីចឹងទេ វាល្បី។ នេះរឿងប្រពន្ធ ថាច់ ជា គាត់ស្លាប់នៅក្នុងសភាពការមួយបែបហ្នឹង។ ឯចំណែកកូនបួននាក់នុំង ខ្ញុំឮតែគេនិយាយទេ។ មុននឹងទៅដេក អង្គាល់នៅជុំគ្នា ម៉ែវា កូនវាហ្នឹង ម៉ែវាកូន ហើយនិងកូននោះ មុននឹងទៅដេក អាកូននោះវាបឺតមាត់គ្នាអញ្ចិបៗអីចឹងហើយ បានវាចូលទៅដេក។ នេះរឿងដែលខ្ញុំដឹងពីរឿង ថាច់ ជា ប៉ុណ្ណឹងឯង ហើយនិងប្រពន្ធគាត់។

**សៈ** ខ្ញុំនឹងអានដើម្បីឲ្យលោកបញ្ជាក់បន្ថែមទៀត គឺអាននូវសក្ខីកម្មរបស់លោកនៅក្នុងការជំនុំជម្រះថ្ងៃ១៦ មិថុនា ២០០៩ គឺE3/5800 នៅម៉ោង<១៦:០៦នាទី>រសៀល <ចន្លោះម៉ោង១៥:៥៩នាទីដល់១៦:០៦នាទីរសៀល>។ លោកបានផ្តល់នូវសក្ខីកម្មដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ការវះកាត់ទៅលើមនុស្សរស់ គឺត្រូវបានធ្វើតាំងពីពេលដំបូងមកម្ល៉េះ។ នៅពេលដែលខ្ញុំនៅជាអនុ ខ្ញុំមិនហ៊ានដោះស្រាយបញ្ហាទេ។ ប៉ុន្តែខ្ញុំដឹងថា ប្រពន្ធរបស់ ថាច់ ជា ត្រូវបានគេប្រើប្រាស់ដើម្បីការរៀនសូត្រនោះ ហើយខ្ញុំបានអង្វរ ណាត ខ្ញុំស្នើសុំ ណាត <ដែលជិតស្និទ្ធជាមួយខ្ញុំថា> កុំឲ្យយកប្រពន្ធ ថាច់ ជា អី ឲ្យយកអ្នកផ្សេងទៅ។ ប៉ុន្តែនៅពេលដែលយើងទៅជួបថ្នាក់លើ គាត់អួតអំពីការយកប្រពន្ធ ថាច់ ជា ទៅ

ធ្វើការរៀនសូត្រវះកាត់នោះ។ ហើយនៅពេលនោះ ខ្ញុំដឹងថា ចេតនារបស់ថ្នាក់លើ គឺជាបញ្ជារបស់ថ្នាក់លើ ដើម្បីឲ្យប្រើប្រាស់អ្នកទោសដែលនៅរស់រានមានជីវិត ដើម្បីបណ្ដុះបណ្ដាលក្នុងការវះកាត់។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំគិតថា ប្រហែលជាអ្វីដែលខ្ញុំអានហ្នឹង ធ្វើឲ្យលោកនឹកឃើញឡើងវិញ លោកសាក្សី គឺថា លោកបានដឹងអំពីការប្រជុំនេះ ថាមេរបស់លោកហ្នឹង គឺអនុញ្ញាតឲ្យវះកាត់ទៅលើប្រពន្ធ ថាច់ ជា នោះ។

[១៥:៥១:០៤]

**ឆ៖** រឿងនេះ ដូចជាខ្ញុំបាននិយាយអំមិញអ៊ីចឹង។ ពេទ្យដែលមកសុំខ្ញុំយកទៅវះកាត់ហ្នឹង ខ្ញុំថា អត់ទេ យកប្រពន្ធអ្នកណាវិញផ្សេងទៀតទៅ។ អត់មានអង្វរ អត់មានអីទេ គឺខ្ញុំបញ្ជាទៅលើកូនចៅ។ ប៉ុន្តែដល់ក្រោយមកទៅជួបគ្នានៅមុខមេ ៗនិយាយអំមិញ ដូចខ្ញុំនិយាយអំមិញអ៊ីចឹង គាត់ថា "ទៅយកអីប្រពន្ធអាថាច់ ជា វាល្បី យកអ្នកណាផ្សេងទៀតទៅ ល្អជាង"។ ដូច្នេះតមកក្រោយទៀត ខ្ញុំដូចមិនទាន់មានអ្នកណាមកសុំខ្ញុំ យកអ្នកណាទៅវះកាត់ទេ នេះបើតាមខ្ញុំចាំ។ សរុបមក បើសិនជាយើងនិយាយថា មេអនុញ្ញាត ឲ្យយកប្រពន្ធអ្នកផ្សេងទៀត អាហ្នឹងជាគោលការណ៍មួយដែលយើងអាចទទួលស្គាល់បាន ក៏ប៉ុន្តែនិយាយថា ខ្ញុំទៅអង្វរ ណាត អត់ទេ ខ្ញុំហាមកូនចៅថា កុំយកទៅ យកអ្នកផ្សេងទៀតទៅ។ រួចរឿងនេះ វាធ្លាក់ទៅរឿងជជែកគ្នាមុខមេ ហើយមេស្ដីឲ្យ ណាត។ នេះគឺរឿងដែលខ្ញុំសូមបញ្ជាក់តាមការដែលខ្ញុំចងចាំ ហើយខ្ញុំនៅតែចងចាំអ៊ីចឹង។

**ស៖** ខ្ញុំមានសំណួរពីរបីបន្តទៀត ដូច្នេះខ្ញុំចង់សួរថា តើអ្នកណាជាមេ ដែលលោកនិយាយថា លោក ហើយនិង ណាត ទៅជួបមេហ្នឹង តើមេហ្នឹងជាអ្នកណាដែរ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! សាក្សីឆ្លើយ!

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** គឺលោក សុន សេន ហៅ បងខៀវ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ៊ីចឹងមានន័យថា សុន សេន មិនប្រឆាំងការវះកាត់មនុស្សនៅរស់នោះទេ គ្រាន់តែគាត់បន្ទោសថា មិនត្រូវប្រើមនុស្សដែលមានកេរ្តិ៍ឈ្មោះល្បីអ៊ីចឹងទេ។ តើអ៊ីចឹងមែនទេ?

[១៥:៥៣:២៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់សាក្សី! មិនទាន់ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** គាត់បន្ទោសអ៊ីចឹង ដូច្នេះយើងអាចទាញទៅសន្និដ្ឋានថាវាអ៊ីចឹង ជាគោលការណ៍គឺអ៊ីចឹង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ៊ីចឹងអ្វីដែល សុន សេន រិះគន់ហ្នឹង គឺគ្រាន់តែដោយសារតែយកប្រពន្ធរបស់មនុស្សល្បី ប៉ុន្តែមិនមែនគាត់រិះគន់ដោយសារការយកមនុស្សរស់ទៅវះកាត់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** មែន។

**ស៖** ហើយកូនបួននាក់របស់ ថាច់ ជា នេះ ហេតុអីបានជាគេសម្លាប់កូនទាំងបួននាក់របស់ ថាច់ ជា? ហេតុអ្វីបានជានៅស-២១ហ្នឹង គេសម្លាប់កូនទាំងបួននាក់នេះទៅវិញ?

**ឆ៖** ក្នុងការអនុវត្តជាក់ស្តែងក្រោយថ្ងៃ១៧ មេសា ឲ្យតែម៉ែឪទៅហើយ កូនទៅហើយ គេសម្លាប់។

**ស៖** តើលោកចាំទេ ប្រពន្ធរបស់ ថាច់ ជា មានអាយុប៉ុន្មានឆ្នាំដែរ នៅពេលដែលគាត់ត្រូវបានគេសម្លាប់នៅពេលដែលគេធ្វើការពិសោធន៍វះកាត់ខាងផ្នែកវេជ្ជសាស្ត្រនេះ?

[១៥:៥៥:២៦]

**ឆ៖** ខ្ញុំមិនបានមើលប្រវត្តិរូបនាងនុំងទេ ហើយក៏មិនដឹងឈ្មោះនាងហ្នឹងស្អីផង ហ្នឹងជម្រាបត្រង់។ បើតាមខ្ញុំស្មាន ធ្លាប់ឃើញអង្កាល់ពីនៅឆ្នាំ១៩៩៦ *(ស៊ីក)* ដែលយើងខ្ញុំរៀននៅនៃវិទ្យាស្ថានជាតិគរុកោសល្យឃើញនាងនុំងដើរ នាងនុំងអាចបងខ្ញុំបន្តិចបន្តួច។ នាងនុំងអាចបងខ្ញុំ ថាច់ ជា នុំងក៏គាត់បងខ្ញុំដែរ។

**ស៖** នៅក្នុងបញ្ជីនេះ គឺបញ្ជីអ្នកទោសដែលត្រូវសម្លាប់ចុងខែមីនា ៧៦ ប្រសិនបើលោកមើលលេខ៥១ដល់៥៣ គឺឯកសារ E3/1539 ហើយសូមបង្ហាញនៅលើអេក្រង់។ <បុគ្គលទាំងបីនាក់នេះ> គឺមានកូនសិស្ស<ម្នាក់> មានវរសេនីយ៍<ម្នាក់ និងនិស្សិតពេទ្យម្នាក់> ហើយគេបានរៀបរាប់<ថាជា> អ្នកដែលកាន់សាសនាកាតូលិក។ ដូច្នេះខ្ញុំចង់ដឹងថា តើវាមានអីសំខាន់ទាក់ទងទៅនឹងអ្នក<ទោស> ដែលកាន់សាសនាកាតូលិក? ហើយ<អ្វី>បាន<បញ្ហាសាសនាកាតូលិកនេះត្រូវបានគេកត់សម្គាល់នៅក្នុងបញ្ជី>សម្លាប់នៅស-២១នោះ?

លោកសាក្សីប្រហែលជាលោកនៅមានបញ្ជីនេះនៅឡើយ គឺបញ្ជីអ្នកទោស គឺឯកសារ E3/1539 ហើយខ្ញុំគិតថា លោកមាននៅក្នុងដៃរបស់លោកនៅឡើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជំទាស់ទៅនឹងសំណួរមួយនេះ ព្រោះយើងបានកំណត់រួចមកហើយថា ឯកសារនេះមិនមែនជាឯកសាររបស់សាក្សីទេ ហើយសាក្សីក៏មិនស្គាល់ឯកសារនេះដែរ ហើយក៏មិនទាំងស្គាល់ ស-២១(គ)ទៀត។ ដូច្នេះប្រហែលជាឯកសាររបស់ ណាត។ ដូច្នេះប្រសិនបើយើងសួរសាក្សី គឺហាក់ដូចជាឲ្យសាក្សីទាយស្មាន ហើយទាយស្មានអំពីចំណារដែលថា សាសនាកាតូលិក។ ដូច្នេះវាជារឿងដែលមិនសមស្រប។

[១៥:៥៨:១២]

**លោក ឌេល លីសាក់៖**

លោកប្រធាន សាក្សីគឺជាអនុប្រធានស-២១ នៅពេលនោះ។ ដូច្នេះគឺថាខ្ញុំអាចសួរអនុប្រធានរបស់មន្ទីរស-២១ គឺសួរថាហេតុអ្វីបានគេកំណត់អំពីអ្នកដែលមកពីសាសនាកាតូលិកជាដើមនោះ។ ដូច្នេះខ្ញុំគិតថា ជាការសមស្រប។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី នួន ជា ចំពោះសំណួរនេះ។ សំណួរនេះអាចសួរបាន ហើយសាក្សីចូរឆ្លើយតប ហើយមុននឹងឆ្លើយតប មន្ត្រីរដ្ឋបាលតុលាការទៅជួយសាក្សី ដើម្បីចង្អុលបង្ហាញនូវឯកសារជាក្រដាស ដែលនៅពីមុខគាត់ហ្នឹង ដើម្បីឲ្យគាត់បានពិនិត្យមើលជាមុនសិន មុននឹងគាត់ឆ្លើយតប។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមជម្រាបបន្តិច គឺយើងមើលលេខ៥១ដល់៥៣ នៅក្នុងបញ្ជីនេះ គឺឯកសារ E3/1539 គឺលេខ៥១ ដល់លេខ៥៣។ លោកដឹងទេ ហេតុអ្វីបានគេចាំបាច់បញ្ជាក់អំពីសាសនាកាតូលិក? តើវាមានសារៈសំខាន់អ្វីក្នុងការបញ្ជាក់អំពីបញ្ហាសាសនាកាតូលិកនេះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** តាមពិតរឿងនេះ ជារឿងដោយឡែកមួយដែលខ្ញុំមិនដឹង បញ្ហាហ្នឹងឲ្យចំទេ ក៏ប៉ុន្តែខ្ញុំដឹងរឿងផ្សេងទៀត។ ថ្ងៃមួយនោះ សុន សេន ហៅខ្ញុំទៅធ្វើការពីរនាក់ ណាត។ រឿងនេះដូចជាខ្ញុំបានឆ្លើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយនៅក្នុងសវនាការ។ ទៅដល់គាត់ថា នៅខាងតំបន់៣៣ ឬសាម ៣២ គេរកឃើញសេ.អ៊ី.អា។ សេ.អ៊ី.អា ហ្នឹងវាគ្រាន់តែជ្រមុជទឹកទេ រួចយើងតែខានប្រជុំបក្ស៦ខែ ដាច់ជីវភាពបក្សហើយ។ អាសេ.អ៊ី.អា ឲ្យតែជ្រមុជទឹកហើយហ្នឹងគឺនៅ សេ.អ៊ី.អា រហូត។ ខ្ញុំ អារម្មណ៍ខ្ញុំទទួលមិនបានទេ ក៏ប៉ុន្តែធ្វើម៉េចបញ្ហាខាងលើ។ ស-២១ ម៉េចក៏រកមិនឃើញ សេ.អ៊ី.អា នឹងគេ? គេរកឃើញណា៎។ ហើយគេសរសេរមកថា អត់មានវ៉ែ។ ដល់ទៅគាត់ដេញខ្ញុំ ហើយនិង ណាត ឲ្យត្រឡប់មកវិញសួរ គឺផ្ចង់អារម្មណ៍ទៅលើ សេ.អ៊ី.អា នេះម្យ៉ាង។

[១៦:០១:៣៦]

ម្យ៉ាងទៀត ដល់ក្រោយមកខ្ញុំឃើញរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បើកសិទ្ធិឲ្យមានជំនឿសាសនា និងបើកសិទ្ធិឲ្យមិនមានជំនឿសាសនា ប្រឆាំងនឹងសាសនាប្រតិកិរិយា។ នៅក្នុងសម័យស៊ើបអង្កេតលើរូបខ្ញុំ ចៅក្រមសួរ អាម៉េចសាសនាប្រតិកិរិយា? ខ្ញុំឆ្លើយអត់បានច្បាស់ទេកាលនុ៎ង។ ហើយដល់ក្រោយមកខ្ញុំចេះតែស្រាវជ្រាវ តើខាងកាតូលិកអស់ប៉ុន្មាន ខាងប្រូតេស្តង់អស់ប៉ុន្មាន? តាមខ្ញុំជួបលោកឪ ប៉ង់សូដ៍ នៅថ្ងៃ២៦ កក្កដា ២០១៣ហ្នឹង ខ្ញុំសួរទៅ គាត់មិនចង់ប៉ានឆ្លើយផង ថាដូចអស់ជាងបីដណ្តប់នាក់។ ក្នុងនុ៎ងគេចាប់អារម្មណ៍មែនទែន អេវ៉េគ ម្នាក់ឬក៏ ពែរ មិនដឹងទេ ឈ្មោះ ហ្សូលហ្សេសឆ្មាស្រឡះ។ រួចឥឡូវនេះ គេដាក់ប៉ាវ៉ាំសនៅភ្នំពេញ គេហៅថា ប៉ាវ៉ាំស សាំងហ្សូសេបរ៉េប បានន័យថា ជាស្ទី ព្រះសហគមន៍ សន្ត ឬសែប ហ្នឹង។ ដូច្នេះសាសនាកាតូលិកក៏ដោយ គេសម្គាល់ជាសាសនាប្រតិកិរិយា។ ឯចំណែកពួកខាងប្រូតេស្តង់ នៅរស់ បើតាមខ្ញុំតាមដានគឺនៅសល់តែម្នាក់ទេគឺ វិហារជីវិតថ្មី ឈ្មោះ កាំង ហ៊្កិចហួង នៅម្តុំពេទ្យរុស្ស៊ីបេង។ ដូច្នេះក្រៅពីនោះ ស្លាប់អស់។ មានឈ្មោះ ទេព អ៊ឹម ដែលជាខ្មែរ ហ្នឹងគឺសាសនាពីរហ្នឹង អាចគេចាត់ទុកជាសាសនាប្រតិកិរិយា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក នៅថ្ងៃពុធ ទី០៨ ខែមិថុនា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី។ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះហៅលោក មកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប និង កាំង ហ្កេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូប និងសាក្សីត្រឡប់ឲ្យចូលរួមនៅក្នុងសវនាការនៅថ្ងៃព្រឹកថ្ងៃស្អែក នៅវេលា ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយចំពោះសាក្សី កាំង ហ្កេកអ៊ាវ បង្គាប់ឲ្យនាំគាត់មកត្រឹមបន្ទប់ដែលរៀបចំទុកសម្រាប់សាក្សី និងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*